# ពន្លឺ

# នាវាត្រៃលោក

# និង

# នាវាត្រៃលក្ខណ៍

## វិបស្សនាបញ្ញាធម្មបរិយាយ



# ពន្លឺ

# នាវាត្រៃលោក
## និង
# នាវាត្រៃលក្ខណ៍

### ទបស្សនាបញ្ញាធម្មបរិយាយ



រៀបរៀងដោយ

**សិរិបញ្ញា ភក្ខុ ឱក ណៃម**

**នទីសមីច្ឆារាម (មហាពោធិ៍)**

**ព. ស. ២៥១០ គ. ស. ១៩៦៧**

**ចម្លងចេញនិងផ្សាយដោយ ហេង ជា**

Los Angeles, California, U.S.A

**កាច់ទំព័រតម្រូវ iPad ដោយ ថូត សាទ្យ**

Haut-Rhin France

១៣ រោច ខែពិសាខ ព. ស. ២៥៥៦

# ពាក្យប្រារព្ធ

បុព្វហេតុនាំឲ្យសៀវភៅនេះកើតឡើង ដោយអាស្រ័យហេតុ ២ យ៉ាងគឺៈ

១- ដោយអាស្រ័យអភូតហេតុនៃឧបាសក២រូប គឺឈ្មោះសញ្ញា១ ឈ្មោះវិញ្ញាណ១ ចូលទៅក្រាបថ្វាយបង្គំ ទូលសួរបញ្ហាធម៌ អំពីនាវាត្រៃលោក, នាវាត្រៃលក្ខណ៍ និង វិបស្សនាកម្មដ្ឋាន ចំពោះព្រះបញ្ញាអាភា សុំឲ្យលោកសម្តែងបំភ្លឺផ្លូវវិបស្សនាធុរៈ ជាមាគ៌ាដ៏ត្រង់ឆ្ពោះទៅកាន់មគ្គ ផល និព្វាន ដើម្បីទុកជាខវត្តិប្រតិបត្តិ សម្រាប់អ្នកវិបស្សនាយានិកតទៅ ។ ព្រះបញ្ញាអាភា បានសំដែងពន្យល់អំពីរឿងនោះយ៉ាង ទូលំទូលាយ តាំងអំពីដើមដរាបចប់ ។ កាលលោកសំដែងចប់ហើយ អ្នកសញ្ញា និងអ្នកវិញ្ញាណមានសេចក្តីជ្រះថ្លា ជាខ្លាំងដរាបបន្លឺឧទានវាចារថា ពិរោះណាស់ៗ ច្បាស់ណាស់ៗ ល្មមជា ខវត្តិប្រតិបត្តិបានហើយ ។

២- ដោយយល់ឃើញថា នាវាត្រៃលោក, នាវាត្រៃលក្ខណ៍ និង វិបស្សនាកម្មដ្ឋាននេះ អាចបានជាប្រទីបមួយសម្រាប់ជួយបំភ្លឺផ្លូវវិបស្សនាធុរៈមួយភាគយ៉ាងធំ ចំពោះអ្នករាប់អានព្រះពុទ្ធសាសនា ទាំងជាគោលធម៌អាចនាំដំណើរអ្នកបដិបត្តិ ឆ្ពោះទៅរក មគ្គ ផល និព្វាន បានទៀតផង ។ អាស្រ័យហេតុ ទាំងពីរខាងលើនេះ ទើបខ្ញុំមានកម្លាំងព្យាយាម រៀបរៀងរឿងនេះឡើង ដរាបបានសម្រេចជាសៀវភៅមួយឲ្យឈ្មោះថា

**នាវាត្រៃលោក, នាវាត្រៃលក្ខណ៍ និង វិបស្សនាបញ្ហាធម្មបរិយាយ ។**

ក្នុងផ្ទៃសៀវភៅនេះ ខ្ញុំតាំងជាពាក្យចោទឆ្លើយដូចជាមានមនុស្ស៣នាក់សាកសួរគ្នាគឺ អ្នកសញ្ញា១ អ្នកវិញ្ញាណ១ ព្រះបញ្ញាអាភា១ ។

ខ្ញុំសង្ឃឹមទុកថា លោកអ្នកអាន និង លោកអ្នកបដិបត្តិទាំងឡាយ ដែលអាននិងបដិបត្តិ ដោយប្រើវិចារណប្បញ្ញាប្រកបផង មុខជានឹងឃើញច្បាស់ នូវធម៌ពិត ធម៌មែន ដោយខ្លួនឯង ក្នុងរយៈកាលណាមួយពុំខានឡើយ ។

ខ្ញុំសូមអភ័យទោសអំពីសំណាក់លោកអ្នកប្រាជ្ញ ទាំងឡាយគ្រប់ប្រភេទ ទោះជាអ្នកប្រាជ្ញខាងផ្លូវវិបស្សនាធុរៈក្តី អ្នកប្រាជ្ញខាងផ្លូវគន្ថធុរៈក្តី បើអានទៅហើយ ឃើញមានវិបត្តិ ឬឆ្គាំឆ្គងត្រង់ន័យណាមួយ សូមមេត្តាកែតម្រូវឲ្យបានត្រឹមត្រូវល្អផង ដើម្បីជាកិច្ចអនុគ្រោះ ចំពោះព្រះពុទ្ធសាសនា ។ កាលខ្ញុំរៀបរៀងចប់សព្វគ្រប់ហើយ បានប្រគេនទៅភិក្ខុ **ទត្តត្ថេរប្បបញ្ញោ លុយ ទ្រឿន អរញ្ញវាសី** ភូមិភ្នំល្អុងឃុំព្រាល ស្រុករវៀង ខេត្តព្រះវិហារ ឲ្យជួយសរសេរសំណៅនិងពិនិត្យកែ លុះលោកសរសេរចប់ហើយ បានជូនទៅ លោក **អ៊ិន ឆាយ** សុំឲ្យលោកជួយលៃលក រកទីពឹងព្រះថេរៈអង្គណាមួយ ឯក្រុងភ្នំពេញ ជួយពិនិត្យកែសម្រួលឲ្យបានត្រឹមត្រូវល្អតាមពុទ្ធវាទ ។ លោក **អ៊ិន ឆាយ** បាននាំច្បាប់នេះទៅប្រគេន **ព្រះធម្មត្រៃលោកាចារ្យច័ន្ទ សាលី ធម្មធីរោ** វត្តបទុមវតីរាជវរារាម ភ្នំពេញ សុំឲ្យជួយពិនិត្យកែសម្រួល ។ ព្រះធម្មត្រៃលោកាចារ្យ បានទទួលដោយយកព្រះទ័យទុកដាក់ ជួយពិនិត្យសរសេរជាថ្មី ហើយកែសម្រួលគោលធម៌ ឃ្លាល្បះ និងអក្ខរាវិរុទ្ធ រហូតដល់ បានជារូបរាងសៀវភៅនេះ សម្រេចឡើង ។ តែនៅពុំទាន់អស់សេចក្តីសង្ស័យក្នុងចិត្ត ទើបបានប្រគេនព្រះ **ធម្មរោត្តម តុង ឈួន ចន្ទវជីរោ** បទុមវតីរាជវរារាម ភ្នំពេញ ឲ្យជួយពិនិត្យថែមទៀត និងជូនលោក **ប៊ូ ប៉ូ** (អតីតក្រុមជំនុំព្រះត្រៃបិដក ក្រសួងសាសនបណ្ឌិត្យ)

ឲ្យជួយពិនិត្យជាថ្មីម្តងទៀត ។ លោក ប៊ូ ប៉ូ ក៏បានជួយពិនិត្យដោយសព្វគ្រប់ ឃើញថាធម៌នេះមានអត្ថន័យទូលំទូលាយ ទាំងមានប្រយោជន៍ដល់អ្នកអាន អ្នកបដិបត្តិ ឲ្យភ្លឺស្វាង នាំចិត្តទៅរកសន្តិសុខ សន្តិភាពបានស្រួល ល្មមចារឹកបោះពុម្ពទុកជាធម្មប្រទីបមួយ ក្នុងពុទ្ធសាសនមណ្ឌល ។ ទើបបានចារសេចក្តីយល់ឃើញ នៅខាងមុខ ដូចមាននៅទំព័រ ខាងមុខ នេះស្រាប់ ។


**សិរិបញ្ញាភិក្ខុ ឱក ណៃម**

នទីសមីបារាម (មហាពោធិ៍)

ឃុំគង់នយ ស្រុកកណ្តាលស្ទឹង ខេត្រកណ្តាល




# សេចក្តីពិនិត្យ និង សេចក្តីយល់ឃើញ

ខ្ញុំបានពិនិត្យដោយម៉ត់ចត់ នូវសៀវភៅនាវាត្រៃលោក និង នាវា-ត្រៃលក្ខណ៍នេះ ចប់សព្វគ្រប់ហើយ យល់ឃើញថា សៀវភៅនេះ ត្រឹមត្រូវតាមត្រៃសិក្ខាទាំង៣ គឺសីល សមាធិ បញ្ញា និង ត្រឹមត្រូវ តាមបាលីឧទ្ទេសក្នុងគម្ពីរវិសុទ្ធិមគ្គថាៈ

សីលេ បតិដ្ឋាយ នរោ សប្បញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដន្តិ ។

នរជនអ្នកឃើញភ័យក្នុងវដ្តៈ ជាអ្នកមានបញ្ញាចាស់ក្លា មានព្យាយាម ដុតកម្តៅចកិលេស កាលបើបានស្ថិតនៅក្នុងសីលវិសុទ្ធិហើយ គប្បី ចំរើននូវចិត្តវិសុទ្ធិ និងបញ្ញាគឺទិដ្ឋិវិសុទ្ធិទៀត ទើបអាចកាត់ផ្តាច់ នូវគ្រឿងបណ្តាញ ពោលគឺកិលេស ដូចជាគ្រឿងសាំញ៉ាំនៃឫស្សី ឲ្យជ្រះដាច់ស្រឡះបាន ។

ម៉្យាងទៀត វិបស្សនាបញ្ញាធម្មបរិយាយនេះ មិនមែនជាវិបស្សនា ក្លែងក្លាយ អែបនែបទៅខាង មន្តអាគមគាថាកាប់មិនមុត ដុតមិនឆេះ នោះទេ គឺជាវិបស្សនាយ៉ាងល្អិតសុខុម គួរជាទីប្រព្រឹត្តរបស់ ព្រះយោគាវចរទូទៅពិតប្រាកដណាស់ ។

ភ្នំពេញ ថ្ងៃទី ៩ កញ្ញា ១៩៦៥

**ប៊ូ ប៉ូ**

អតីតក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

# នាវាត្រៃលោក



នាវាត្រៃលោកផ្ទុកពួកសត្វ　　　ឆ្លងកាត់សមុទ្ទសាគរា
ឥតមានកោះត្រើយឆ្ងាយមហិមា　　　ចូលកាន់ជរាព្យាធិ៍មរណៈ ។
តែគេមិនដឹងស្មានថាសុខ　　　ខំចូលត្រសុកគ្រប់វណ្ណៈ
បបួលគ្នីគ្នាច្រើនអនន្ត　　　គ្រឹកគ្រាក់ឡើងជិះហ៊ោសប្បាយ ។
លុះដល់គ្រោះថ្នាក់នាវាធ្លាយ　　　លិចលង់អន្តរាយព្រាត់ខ្ចាត់ខ្ចាយ
ព្រាត់កូនប្រពន្ធឪពុកម្តាយ　　　ព្រាត់ញាតិជិតឆ្ងាយអសារបង់ ។

*និពន្ធឡើងដោយ ព្រះធម្មត្រៃលោកាចារ្យ **ច័ន្ទ សាលី***
*វត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ*

# នមត្ថុរតនត្តយស្ស

សូមនមស្សការចំពោះព្រះរតនត្រៃដោយសេចក្តីគោរព ។

សេចក្តីអធិប្បាយក្នុងខាងដើម នៃវិបស្សនាកម្មដ្ឋាននេះ គួរពួកពុទ្ធសាសនិកជនទូរទៅជ្រាបថា កាលដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង បានត្រាស់ដឹងឡើងជាសាស្តាចារ្យឯកក្នុងលោក ទ្រង់មានព្រះហឫទ័យប្រកបដោយព្រះមហាករុណាដ៏ធំ ទ្រង់ប្រោសប្រទានព្រះសទ្ធម្មទេសនាចំពោះសត្តនិករក្នុងលោក អស់រយៈចំនួន ៤៥ ព្រះវស្សា ។ ដោយទ្រង់មានព្រះពុទ្ធបំណងចង់ឲ្យពួកសត្តនិករទាំងនោះបានសម្រេច មគ្គ ផល ក្នុងពេលបានស្តាប់ ឬស្តាប់រួចហើយ និងបានប្រតិបត្តិតាម ដើម្បីឆ្ពោះត្រង់ទៅកាន់ព្រះនិព្វានតែម៉្យាង ។ មិនមែនមានពុទ្ធបំណង ត្រឹមតែដឹកនាំសត្វឲ្យបានសុគតិ គឺសម្បត្តិមនុស្សលោក ទេវលោក ឬព្រហ្មលោកប៉ុណ្ណោះទេ ។ ព្រោះព្រះអង្គទ្រង់បានជ្រាបជាក់ច្បាស់នូវភពទាំងពួង ដែលទ្រង់បានធ្លាប់កើតស្លាប់ ៗ ដោយផ្ទាល់ព្រះអង្គឯងមក អស់រយៈកាលជាអនេកជាតិ ទាំងទ្រង់ឈ្វេងយល់ច្បាស់ដោយព្រះបញ្ញាញាណផងទៀតថា ភពទាំង៣នេះ សឹងពេញទៅដោយគំនរភ្លើងទុក្ខ និងភ្លើងកិលេស ដែលកំពុងតែឆេះរោលរាលកំដៅពួកសត្វឲ្យក្តៅក្រហាល់ក្រហាយ អន្ទះអន្ទែងជានិច្ច ដោយភ្លើងទុក្ខ ភ្លើងកិលេស ដុតកំដៅឲ្យឆេះរោលដាលវិលវល់កើតស្លាប់ក្នុងវដ្តសង្សារ សោយទុក្ខវេទនារកទីបំផុតគ្មាន ។

ពួកសត្វដែលត្រូវអវិជ្ជាដឹកមុខ បិទបាំងបញ្ញាមិនឲ្យឃើញច្បាស់នូវកងទុក្ខ ត្រឡប់ជាសម្គាល់ថា ការកើតក្នុងភពជាការសុខសប្បាយ

ទៅវិញ ឧបមាដូចសត្វល្អិតៗ តូចៗ មានសត្វមមាចជាដើម ក្រឡេក ឃើញពន្លឺភ្លើងភ្លឺច្រាលក្នុងរាត្រីកាល ក៏នឹកស្មានថាជារបស់ត្រជាក់សុខ សប្បាយ ឥតបានដឹងថាភ្លើងនេះជារបស់ក្តៅក្រហាយឡើយ ក៏នាំគ្នា ហើរត្រសុករុលត្បុល ចូលចោមរោមលេងប្រឡែងព័ទ្ធក្រឡឹងនាយអាយ ដោយសេចក្តីសំគាល់ខុស (មោហៈ) មិនបានមួយនាទីនាឡិកាផង ក៏ដល់នូវសេចក្តីវិនាសអន្តរាយ ស្លាប់ខ្លួននៅទីនោះ ត្រៀបត្រាកកកុញ ហួសវិស័យនឹងរាប់ថាប៉ុណ្ណេះប៉ុណ្ណោះបាន ដោយសារតែភ្លើងនេះឯង យ៉ាងណាមិញ ។ បុគ្គលដែលត្រូវអវិជ្ជាបិទបាំងហើយ សំគាល់ឃើញ សម្បត្តិមនុស្ស សម្បត្តិទេវតា ក៏នឹកស្មានថា សម្បត្តិទាំងនោះជារបស់ វិសេស ត្រជាក់ត្រជុំថ្លៃថ្លា ប្រកបដោយសេចក្តីសុខស្រួល ថាជារបស់ ទៀងទាត់ មិនវិបល្លាសប្រែប្រួល ម្ល៉ោះហើយក៏នាំគ្នាបំពេញការ កុសលផ្សេងៗ ចំពោះតែខាង វដ្តគាមិនីកុសល គឺកុសលដែលធ្វើដំណើរ ឲ្យវិលវល់ក្នុងភព ព្រោះតែប្រាថ្នានូវសម្បត្តិទាំងនោះ ឯសម្បត្តិ ទាំងនោះឯង រមែងចងក្រៀកនូវបុគ្គលជាម្ចាស់នោះ ឲ្យជាប់នៅក្នុងភព ហើយឆេះរោលរាលដោយគំនរភ្លើងទុក្ខ និងភ្លើងកិលេស ធ្វើឲ្យវិលវល់ ស្លាប់កើត ទទួលរងនូវសេចក្តីទុក្ខវេទនាក្នុងវដ្តសង្សាររឿយៗ រកទីបំផុត គ្មានយ៉ាងនោះដែរ ។

ព្រះពុទ្ធភាសិតទ្រង់ត្រាស់ថា:

យថាបិ នាម ជច្ចន្ធោ នរោ អបរិនាយកោ

ឯកកា យាតិ មគ្គេន ឧម្មគ្គេនាបិ ឯកកា
សំសារេ សំសរំ ពាលោ តថា អបរិនាយកោ
ករោតិ ឯកទា បុញ្ញំ អបុញ្ញម្បិ ឯកទា
យទា ច ញត្វា សោធម្មំ សច្ចានិ អភិសមេស្សតិ
តទា អវិជ្ជូបសមា ឧបសន្តោ ចរិស្សតិ ។

សេចក្តីថា មនុស្សខ្វាក់អំពីកំណើត (ត្រាច់ចរលើផែនដី) បើឥតគេដឹកដៃនាំមុខទេ ជូនដើរទៅត្រង់ផ្លូវក៏មាន ជូនដើរទៅខុសផ្លូវក៏មាន យ៉ាងណាមិញ បុគ្គលពាលល្ងង់ខ្លៅ ដែលប្រកបដោយអវិជ្ជាបិទបាំង មិនឲ្យដឹងច្បាស់នូវកងទុក្ខ ព្រោះការអន្ទោលទៅមកក្នុងវដ្ដៈ កាលត្រាច់រង្គាត់ទៅក្នុងវាលវដ្ដសង្សារ បើមិនមានអ្នកប្រាជ្ញដឹកនាំមុខទេ រមែងប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ គឺចំណែកជាបុណ្យខ្លះក៏មាន ប្រារព្ធធ្វើនូវអបុញ្ញាភិសង្ខារ គឺចំណែកជាបាបខ្លះក៏មាន ប្រារព្ធធ្វើនូវអនេញ្ជាភិសង្ខារ គឺជាចំណែកឈានដែលមានចិត្តវិបល្លាសដោយទិដ្ឋិ មានសស្សតទិដ្ឋិជាដើមក៏មានយ៉ាងនោះដែរ ។

លុះណាតែបុគ្គលពាលនោះ យល់ច្បាស់លាស់ បានត្រាស់ដឹងនូវអរិយសច្ចៈ៤ប្រការពេលណា នឹងជាបុគ្គលប្រព្រឹត្តធម្មបតិបត្តិ ឆ្ពោះទៅរកសន្តិសុខស្ងប់ស្ងាត់ក្នុងពេលនោះ ព្រោះបានស្ងប់អវិជ្ជា ។ តែថាបើបុគ្គលពាលនោះ មិនបានត្រាស់ដឹងនូវអរិយសច្ចៈដោយច្បាស់លាស់ទេ ទុកណាជាបុគ្គលនោះប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ គឺការតាក់តែងបុណ្យ

ណាមួយ ដោយកាយ វាចា ចិត្ត បុណ្យនោះឯងរមែងច្រឡំទៅដោយទោសទុក្ខជាច្រើនប្រការ មានជាតិនិងជរាជាដើម ព្រោះហេតុអ្វី? ព្រោះតែប្រាថ្នានូវសម្បត្តិក្នុងលោកទាំង៣ គឺ **មនុស្សលោក ទេវលោក ព្រហ្មលោក** ដោយសំគាល់ថា សម្បត្តិទាំងនេះឯង ជាសម្បត្តិប្រសើរប្រកបដោយសេចក្តីសុខយ៉ាងទៀងទាត់ ។ ប៉ុន្តែព្រះសព្វញ្ញុពុទ្ធពុំដែលទ្រង់សំដែងសរសើរ ចំពោះកំណើតនៃសត្វ ដែលអន្ទោលទៅកើតជាមនុស្សក្តី ជាទេវតាក្តី ជាព្រហ្មក្តី ថាជាកំណើតប្រកបដោយគុណផុតចាកសេចក្តីទុក្ខទាំងពួងនោះឡើយ ។ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា បើជាតិកំណើតរបស់សត្វទាំងឡាយមាននៅដរាបណា សេចក្តីទុក្ខទាំងឡាយ មានជាតិទុក្ខជាដើម ក៏មាននៅដរាបនោះដែរ ។

ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់ត្រាស់សរសើរចំពោះតែព្រះនិព្វានមួយថា ជាធម្មជាតិអាចធ្វើសត្វទាំងឡាយឲ្យរលត់ផុតចាកទុក្ខគ្រប់ប្រការ ។ ចំណែកបុគ្គលដែលប្រកបដោយវិជ្ជា រមែងមានការយល់ឃើញថា ការកើតជាមនុស្សក្តី កើតជាទេវតាក្តី កើតជាព្រហ្មក្តី ដោយអំណាចកាមាវចរកុសល ឬរូបាវចរកុសលណាមួយ ក៏គង់មិនរួចចាកទុក្ខទាំងពួងបានឡើយ ទាំងមានការយល់ឃើញថា បើជាតិកំណើតមិនទាន់អស់ទេ ទុក្ខក៏នៅមិនទាន់អស់ដែរ ព្រោះកំណើតរបស់សត្វទាំងឡាយ ដែលកើតក្នុងភពថោកទាបនិងភពដ៏ឧត្តមនោះៗ ដោយអំណាច កុសលាកុសលកម្ម សុទ្ធតែជាកំណើតនៅមានការប្រែប្រួលមិនទៀងទាត់ កាលបើអស់អំណាច នៃកុសលាកុសលកម្មនោះហើយ សត្វទាំងឡាយនោះឯងត្រូវតែវិលត្រឡប់ចុះឡើងនៅក្នុងវដ្តៈ ដោយ

អំណាចនៃផលបុណ្យនិងផលបាបដឹកនាំដូច្នេះ តើទីបំផុតនៃទុក្ខ របស់សត្វនៅត្រឹមណា?

បុគ្គលដែលប្រកបដោយវិជ្ជា កាលបើយល់ឃើញយ៉ាងនេះហើយ រមែងមានសេចក្ដី នឿយណាយធុញទ្រាន់ ចំពោះកំណើតដែលកើតរឿយៗ ក្នុងវដ្តៈនេះ តែងត្រេះរិះរកឧបាយ ដើម្បីនឹងដោះខ្លួនគេចចេញឲ្យរួចផុតចាកភពទាំង៣ ដោយការខំប្រឹងប្រែងបំពេញកុសលផ្សេងៗ ចំពោះតែខាង វិវដ្តគាមិនីកុសល គឺកុសលដែលធ្វើដំណើរត្រង់ឆ្ពោះទៅកាន់ព្រះនិព្វានជាទីប្រាសចាកវដ្តៈ ។ បុគ្គលនោះ កាលបើធ្វើនូវកុសលណាមួយ ដោយកាយ វាចា ចិត្ត មានការឲ្យទានជាដើម រមែងតាំងចិត្តដើម្បីធ្វើពួកកិលេសទាំងឡាយ មានលោភៈជាដើម ឲ្យរីងស្ងួតអស់ពីខន្ធសន្តាន សំដៅទៅព្រះនិព្វានតែម៉្យាងប៉ុណ្ណោះ ។ កុសលរបស់បុគ្គលនោះហៅថា វិវដ្តគាមិនីកុសល គឺកុសលរបស់បុគ្គលអ្នកដល់ត្រើយនៃច្រាំងគឺព្រះនិព្វាន រួចផុតស្រឡះចាកការវិលកើតវិលស្លាប់ ។

ធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់លើកឡើងសំដែងសម្រាប់ឲ្យសត្វប្រតិបត្តិតាម ដើម្បីឆ្ពោះតម្រង់ទៅកាន់ព្រះនិព្វាននោះ មានច្រើនជាអនេកណាស់ ក្នុងទីនេះទ្រង់សំដែង សំដៅយកវិបស្សនាតែម៉្យាង ទីខ្លះសំដៅយកសមថៈផងទាំងវិបស្សនាផង ទីខ្លះសំដៅយកអដ្ឋង្គិមគ្គ គឺមគ្គដែលប្រកបដោយអង្គ៨ប្រការ មានសមាទិដ្ឋិជាដើម ទីខ្លះសំដៅយកត្រ័យសិក្ខាទាំង៣ គឺ សីល សមាធិ បញ្ញា ទីខ្លះសំដៅយកពោធិបក្ខិយធម៌ទាំង៣៧ប្រការ មានសតិបដ្ឋាន៤ សម្មប្បធាន៤ ជាដើម។

ក្នុងទីនេះសំដៅយកវិបស្សនាកម្មដ្ឋានតែម៉្យាងប៉ុណ្ណោះដូចតទៅ ៖

# កម្មវិធីចំរើន វិបស្សនាកម្មដ្ឋាន

កាលបើព្រះយោគាវចរមានបំណងនឹងចំរើននូវវិបស្សនានោះ គប្បីឲ្យដឹងអត្ថនៃវិបស្សនាភាវនាដូច្នេះថា:

បុគ្គលអ្នកធ្វើវិបស្សនាបញ្ញា ដែលខ្លួនឃើញក្នុងអារម្មណ៍ហើយមានក្នុងចិត្តដោយចេតនាណា ចេតនានោះឈ្មោះថា **វិបស្សនាភាវនា** ។ ក៏ឯវិបស្សនាភាវនានេះ ព្រះយោគាវចរនឹងចំរើន គប្បីសិក្សាឲ្យដឹងច្បាស់នូវធម៌៣ប្រការជាមុនសិនគឺ:

- ១-**ធម៌ជាភូមិ** ជាអារម្មណ៍របស់វិបស្សនា
- ២-**ធម៌ជាឫសគល់** ជាហេតុឲ្យកើតឡើងហើយតាំងនៅរបស់វិបស្សនា
- ៣-**ជាតួវិបស្សនា** ។

អ្វីជាភូមិ ជាអារម្មណ៍របស់វិបស្សនានោះ ?

សង្ខារធម៌ដែលបច្ច័យប្រជុំតាក់តែងឡើងគឺ **ឧបាទិន្នកៈ** ដែលនាមធម៌អាស្រ័យ និង **អនុបាទិន្នកៈ** ដែលនាមធម៌មិនអាស្រ័យ ឬថានាម និង រូប ដែលចែកចេញទៅដោយប្រការផ្សេងៗ មានខន្ធ៥ អាយតនៈ១២ ធាតុ១៨ ឥន្ទ្រីយ២២ជាដើម ទាំងអស់នេះគឺជាភូមិជាអារម្មណ៍ របស់វិបស្សនា ។ អ្នកដែលចំរើនវិបស្សនានោះ ត្រូវរៀនធម៌ដែលជាភូមិជាអារម្មណ៍ របស់វិបស្សនានោះ ឲ្យដឹងច្បាស់លាស់ជាមុនហើយគប្បីសាកសួរលោកអ្នកចេះដឹងនូវអត្ថនិងធម៌ ឲ្យដឹងសេចក្តីពិតប្រាកដ ចំណានល្អ ទើបគួរនឹងចំរើនវិបស្សនាបាន ។

អ្វីជាឫសគល់ ជាហេតុកើតឡើងតាំងនៅរបស់វិបស្សនានោះ ?

**សីលវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃសីល១ **ចិត្តវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃចិត្តគឺឧបចារសមាធិ និងអប្បនាសមាធិ១ វិសុទ្ធិទាំង២នេះឯង ជាឫសគល់ ជាហេតុកើតឡើងតាំងនៅរបស់វិបស្សនា ។ អ្នកដែលនឹងចំរើននោះ ត្រូវប្រតិបត្តិឲ្យជាអ្នកមានសីលបរិសុទ្ធ និងចិត្តបរិសុទ្ធ ដោយសមាធិជាមុនទើបគួរនឹងចំរើនវិបស្សនាបាន ។ បើជាអ្នកមានសីលមិនបរិសុទ្ធ មិនមានសមាធិ ចិត្តរាយមាយហើយ ក៏ជាអ្នកអភ័ព្វ មិនគួរនឹងចំរើនវិបស្សនានោះបានឡើយ ។ ព្រោះថាសីលនិងសមាធិ ជាកម្លាំងឲ្យកើតវិបស្សនា ។

អ្វីជាតួវិបស្សនា ?

វិសុទ្ធិទាំង៥យ៉ាងគឺ:

**១-ទិដ្ឋិវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃការឃើញ ។

**២-កង្ខាវិតរណវិសុទ្ធិ** សេចក្តីបរិសុទ្ធ នៃការឃើញច្បាស់កន្លងបង់ សេចក្តីសង្ស័យបាន ។

**៣-មគ្គាមគ្គញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃការដឹងពិតឃើញពិតថា នេះជាផ្លូវ នេះមិនមែនជាផ្លូវ ។

**៤-បដិបទាញាណទស្សនវិសុទ្ធិ** សេចក្តីដឹងច្បាស់ឃើញច្បាស់នូវផ្លូវប្រតិបត្តិ ដែលជាហេតុឲ្យអរិយមគ្គកើតឡើង ។

**៥-ញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃការដឹងការឃើញ នូវករណីយកិច្ចដែលជាចំណែកនៃលោកុត្តរៈ គឺឃើញក្នុងមគ្គ៤ ដោយជាក់ច្បាស់តាមលក្ខណៈនិងសភាវៈ មិនវង្វេងទៅតាមសម្មតិលោកវោហារ

ថាជា សត្វ ខ្លួន ប្រាណ យើង គេ ឡើយ ដែលជាតួទិដ្ឋិវិសុទ្ធិ ។ ទាំងជាហេតុនិងជាបច្ច័យ កន្លងកង្ខា ក្នុងកាលទាំង៣ ចេញបាន គឺមិនសង្ស័យថាយើងច្យុតមកពីទីណា? យើងជាអ្វី? យើងនឹងទៅកើតក្នុងទីណា? ទេវបុត្រ ទេវតាមានឬមិនមាន? ដែលជាតួកង្ខាវិតរណាវិសុទ្ធិ ។ វិបស្សនាញាណទាំង៩ មានឧទយព្វយញាណជាដើម មានអនុលោមញាណ ជាទីបំផុត ឈ្មោះថា បដិបទាញាណទស្សន-វិសុទ្ធិ ។ អរិយមគ្គទាំង៤នេះឈ្មោះថា ញាណទស្សនវិសុទ្ធិ ។ វិសុទ្ធិទាំង៥ប្រការនេះឯង ជាតួវិបស្សនា ។ ម្យ៉ាងទៀត បញ្ញាដែលយើងដឹងពិតឃើញពិត ក្នុងសភាវៈ ការកើតឯងរបស់សង្ខារ គឺ ឃើញថាជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ឃើញច្បាស់ថា របស់ឯណាមិនទៀង តែកាលណាកើតឡើងហើយរលត់បាត់បង់ទៅវិញ របស់នោះជាទុក្ខពិត បើរបស់ឯណាជាទុក្ខ របស់នោះជាអនត្តា មិនមែនជាខ្លួនជាប្រាណ របស់នោះមិនគួរបើនឹងប្រកាន់ប្រកៀក ថាជារបស់យើង ដោយអំណាចតណ្ហា ឧបាទាន មានៈនិងទិដ្ឋិឡើយ ។ ព្រោះថាខ្លួនប្រាណ យើងគេមិនមានទេ បញ្ញាដែលពិចារណាឃើញជាក់ច្បាស់យ៉ាងនេះ ដរាបដល់កើតនិព្វិទា (នឿយណាយ) ស្អប់ខ្ពើមសង្ខារ កើតវិរាគៈ ប្រាសចាកសេចក្តីតម្រេកត្រេកអរក្នុងសង្ខារវិមុត្តិរួចផុតចាកកិលេសាសវៈទាំងអស់ នេះជាតួវិបស្សនាទាំងអស់ដូចគ្នា ។

សាធុជនអ្នកបំពេញសេចក្តីព្យាយាម បដិបត្តិក្នុងវិបស្សនា ដូចបានពោលមកនេះ ធ្វើឲ្យបរិបូណ៌ហើយ ក៏បានឈ្មោះថាចំរើនវិបស្សនាដោយល្អ នេះជាសេចក្តីអធិប្បាយដោយសង្ខេបក្នុងវិបស្សនានោះ ។

ឯសេចក្តីពិស្តារដូចមានតទៅនេះគឺ ៖

អ្នកដែលចំរើនវិបស្សនា គប្បីឲ្យជាអ្នកបរិសុទ្ធដោយសីល បរិសុទ្ធដោយទិដ្ឋិ ហើយគប្បីដឹង លក្ខណៈ - កិច្ច - ហេតុ - ផល របស់វិបស្សនានោះឯង ។

អ្វីហ្ន៎ជាលក្ខណៈរបស់វិបស្សនា?

សភាវៈការកើតឯងរបស់សង្ខារ គឺជារបស់មិនទៀង, ជាទុក្ខ, ជាអនត្តាពិត ។ សេចក្តីឃើញថាសង្ខារជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាក់ច្បាស់យ៉ាងនេះឯង ជាលក្ខណៈគ្រឿងសំគាល់ របស់វិបស្សនា ។

បើការដឹង ឃើញ យ៉ាងដទៃទៅ មិនត្រូវតាមន័យដូចពោលមកខាងលើនេះ ក៏មិនមែនជាវិបស្សនាឡើយ ។

អ្វីហ្ន៎ជាកិច្ច និងជាគុណរបស់វិបស្សនា?

សេចក្តីងងឹតគឺមោហៈ ការភ័ន្តច្រឡំក្នុងសង្ខារ ថាជារបស់ទៀង ថាសុខ ថាខ្លួនប្រាណឯណា បិទបាំងបញ្ញាមិនឲ្យឃើញច្បាស់ នូវរបស់ពិតនៃសង្ខារ សេចក្តីកំចាត់បង់ងងឹតចេញបានអស់ មិនវង្វេងក្នុងសង្ខារ ថាជារបស់ទៀងទាត់ ជារបស់សុខ ជាខ្លួនប្រាណ ជារបស់ល្អ នេះឯងជាកិច្ច ជាគុណវិបស្សនា។

អ្វីហ្ន៎ជាផលរបស់វិបស្សនា?

សេចក្តីឃើញពិតទូទៅក្នុងសង្ខារទាំងពួង ថាជារបស់មិនទៀង ជាទុក្ខ ជាអនត្តា សេចក្តីងងឹតគឺមោហៈ ការវង្វេងចូលមកតាំងនៅមិនបានព្រោះមានពន្លឺភ្លឺស្វាងកើតឡើង នេះឯងជាផលរបស់វិបស្សនាក្នុងបទនេះ។

អ្វីជាហេតុកើតឡើង ហើយតាំងនៅរបស់វិបស្សនា?

ចិត្តដែលមិនរាយមាយតាំងនៅខ្ជាប់ខ្ជួនឯណានិមួយ ដោយអំណាចសមាធិ នេះឯងជាហេតុកើតឡើងតាំងនៅរបស់វិបស្សនា ។ វិបស្សនានោះ រមែងអាស្រ័យសមាធិ ទើបកើតឡើងតាំងនៅបាន បើមិនបានចំរើនសមាធិឲ្យកើតមុនហើយ ក៏មិនអាចចំរើនវិបស្សនាឲ្យកើតឡើងបាន ព្រោះថាសមាធិជាហេតុឲ្យកើតវិបស្សនា ដោយន័យនេះ អ្នកដែលមានសីលមិនបរិសុទ្ធមិនបានសមាធិ នឹងមកពោលអួតថា ខ្លួនបានសម្រេចវិបស្សនាភាវនាយ៉ាងនេះ មិនគួរជឿឡើយ ។ ព្រោះសីលបរិសុទ្ធជាហេតុឲ្យកើតសមាធិៗ ជាហេតុឲ្យកើតវិបស្សនាៗ ជាហេតុឲ្យកើតអរិយមគ្គៗជាហេតុឲ្យកើតអរិយផល ជាធម៌តាមនិយមមានយ៉ាងនេះមិនប្រែប្រួលទៅជាយ៉ាងដទៃឡើយ ។ អ្នកដែលចំរើនវិបស្សនាគប្បីឲ្យដឹង លក្ខណៈ - កិច្ច - ហេតុ - ផល របស់វិបស្សនា ដោយប្រការដូច្នេះ ។

## ឯវិភាគការចែកជា៦ចំណែកគឺ:

**អនិច្ចំ** របស់មិនទៀង១, **អនិច្ចលក្ខណំ** គ្រឿងសំគាល់ដែលឲ្យកំណត់ដឹងថាជារបស់មិនទៀង១, **ទុក្ខំ** របស់ដែលសត្វអត់ទ្រាំបានដោយកម្រ១, **ទុក្ខលក្ខណំ** គ្រឿងសំគាល់ដែលឲ្យកំណត់ដឹងថាជាទុក្ខ១, **អនត្តា** សភាវៈមិនមែនជាខ្លួនប្រាណ១, **អនត្តលក្ខណំ** គ្រឿងសំគាល់ដែលឲ្យកំណត់ដឹងថាមិនមែនជាខ្លួនប្រាណ១ ។

ក្នុងវិភាគទាំង៦នេះ សង្ខារដែលប្រជុំតាក់តែងឡើងជា ឧបាទិន្នកៈ ១ និងអនុបាទិន្នកៈ១ ឬថានាមនិងរូប ដែលចែកចេញទៅដោយប្រការផ្សេងៗ មានខន្ធ - ធាតុ - អាយតនៈ ជាដើម ដែលជាភូមិ

ជាអារម្មណ៍របស់វិបស្សនានោះទាំងអស់ ជាតួអនិច្ចំ ជារបស់មិនទៀង ព្រោះថាកើតឡើងហើយរលត់សាបសូន្យទៅវិញជាធម្មតា តែងតែប្រែប្រួលទៅយ៉ាងដទៃ មិនតាំងនៅដូចដើមឡើយ ។ ក៏ឯការកើតឡើងហើយសាបសូន្យទៅ និង ប្រែប្រួលទៅជាយ៉ាងដទៃនេះឯង ជាតួ **អនិច្ចលក្ខណៈ** ជាគ្រឿងសំគាល់ដែលឲ្យដឹងថា ជារបស់មិនទៀងពិត ។ សង្ខារនិងនាមរូបដែលជារបស់មិនទៀងនោះ ជាតួ **ទុក្ខំ** ព្រោះជារបស់ ប្រែប្រួលទៅជាយ៉ាងដទៃៗ ដោយភ្លើងគឺ **ជរា ព្យាធិ** និង **មរណៈ** បៀតបៀនដុតបំផ្លាញជានិច្ច ។ រីឯការកើតរលត់ និងប្រែប្រួលជាយ៉ាងដទៃៗ ទៅដោយ ជរា ព្យាធិ និង មរណៈ បៀតបៀនដុតបំផ្លាញនោះឯង ជា**ទុក្ខលក្ខណៈ** ជាគ្រឿងសំគាល់ឲ្យដឹងថាជាតួទុក្ខពិត ។ ធម៌ទាំងអស់ដែលជាសង្ខារនិងវិសង្ខារ និង ព្រះនិព្វានសុទ្ធតែជា អនត្តា ព្រោះជាធម៌សូន្យចាកខ្លួន - ប្រាណ - សត្វ -បុគ្គល មិនមាន អ្នកឯណាមួយជាម្ចាស់របស់ គ្រាន់តែជាសភាវៈធម៌ មួយៗ ផ្សេងៗ ទៅប៉ុណ្ណោះ ។ ក៏ភាពជារបស់សូន្យចាកខ្លួន - ប្រាណ - សត្វ - បុគ្គល មិនមានម្ចាស់របស់ គ្រាន់តែជាសភាវៈម៉្យាងប៉ុណ្ណោះ នេះឯងហៅថា **អនត្តលក្ខណៈ** គ្រឿងសំគាល់ដឹងថា ជាអនត្តាពិត ។

អ្នកដែលចំរើនវិបស្សនា គប្បីដឹងស្គាល់វិភាគធម៌៦យ៉ាង ដូចពោលមកនេះ អ្នកបំពេញព្យាយាមចំរើនវិបស្សនា ជាអ្នកបរិបូណ៌ដោយគុណសម្បត្តិ មានសីល និង ទិដ្ឋិជាដើមដូចបានពោលមកនេះ ទើបគួរជាអ្នកចំរើនវិបស្សនាដ៏ល្អ ជាអ្នកអាចញ៉ាំងវិបស្សនានោះឲ្យបរិបូណ៌បាន ដោយប្រការទាំងពួង ។

លំដាប់នេះ នឹងសំដែងធម៌ដែលជាអារម្មណ៍របស់វិបស្សនា និងវិធីចំរើនវិបស្សនាតាមបាលី និង អដ្ឋកថាដូចតទៅនេះ ៖

សេចក្តីថា សង្ខារដែលជាបច្ច័យប្រជុំតាក់តែងឡើង ជាឧបាទិន្នកៈ និង អនុបាទិន្នកៈ ទាំងអស់នោះឯង ជាអារម្មណ៍របស់វិបស្សនា ។ វិបស្សនាដែលមានសង្ខារជាអារម្មណ៍នោះ បានខាង អនិច្ចលក្ខណៈ និង ទុក្ខលក្ខណៈ ទាំងពីរ ដែលមានមកហើយក្នុងបាលីថាៈ សព្វេ សង្ខារា អនិច្ចា សង្ខារធម៌ទាំងអស់ជារបស់មិនទៀង រមែងកើតឡើងហើយរលត់ បាត់បង់ទៅវិញជាធម្មតា ។ សព្វេ សង្ខារា ទុក្ខា សង្ខារទាំងអស់ ជាទុក្ខដូច្នេះ ។ ម្យ៉ាងទៀត ធម៌ទាំងអស់ដែលជាសង្ខារ និង វិសង្ខារ (ព្រះនិព្វាន) ក៏ជាអារម្មណ៍ របស់វិបស្សនា ។ វិបស្សនាដែលមាន ធម៌ទាំងអស់ជាអារម្មណ៍នោះ បានតែក្នុងអនត្តលក្ខណៈម្យ៉ាង ដែលមាន ក្នុងបាលីថា សព្វេ ធម្មា អនត្តា ធម៌ទាំងអស់មិនមែនខ្លួន-ប្រាណ ។ ព្រះនិព្វានដែលមានសង្ខារទៅប្រោសហើយ មិនមានមកក្នុងសង្ខារ ទាំងពីរខាងដើមនោះទេ ព្រោះព្រះនិព្វានជាធម៌ទៀង ពេញពោរដោយបរមសុខយ៉ាងមាំមួន ប៉ុន្តែព្រះនិព្វាននោះជាអនត្តាធម៌ មិនមែន ជាខ្លួន - ប្រាណ - សត្វ - បុគ្គលឡើយ គឺគ្រាន់តែជា អសង្ខតធាតុប៉ុណ្ណោះ ទើបបានមានមកក្នុងពាក្យថា សព្វេ ធម្មា អនត្តា ដូច្នេះ ។

សាធុជនកាលនឹងចំរើនវិបស្សនា ដែលមានសង្ខារនិងធម៌ជាអារម្មណ៍នោះគប្បីចំរើនតាមន័យដែលមានមកក្នុងបាលីដូច្នេះថាៈ សព្វេ

សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តា ម៉្យាងទៀតថាពួក៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បណ្ដាខន្ធទាំង៥នោះ គឺរូបក្ខន្ធ មានកិរិយាចាស់ទ្រុឌទ្រោមទៅជាខាងដើម មានកិរិយាបែកធ្លាយទៅជាខាងចុង ព្រោះបច្ច័យជាសត្រូវដល់ខ្លួន មានត្រជាក់និងក្ដៅជាដើម ជាលក្ខណៈ បាននឹងមហាភូតរូប៤គឺ ដី ទឹក ភ្លើង ខ្យល់ និងរូបដែល អាស្រ័យនូវមហាភូតរូប៤នោះ ទាំងអស់នេះជាពួករូប ។ វេទនាមានការទទួលរង ការសោយនូវអារម្មណ៍ជាលក្ខណៈ គឺជាសុខ ទុក្ខ ឧបេក្ខា កើតអំពីសម្ផស្សការពាល់ត្រូវ ។ ការសោយនូវអារម្មណ៍ទាំងអស់នេះ ជាពួកវេទនា ។ សញ្ញា មានសេចក្ដី សំគាល់នូវអារម្មណ៍ ចំណាំនូវអារម្មណ៍ជាលក្ខណៈ គឺសំគាល់រូប ហើយចំណាំរូបបាន សំគាល់សម្លេងហើយចាំសម្លេងបាន សំគាល់ក្លិនហើយចាំក្លិនបាន សំគាល់រសហើយចាំរសបាន សំគាល់សម្ផស្សហើយចាំសម្ផស្សបាន សំគាល់ធម្មារម្មណ៍ហើយចាំធម្មារម្មណ៍បាន សេចក្ដីសំគាល់ហើយចាំបានទាំងអស់នេះ ជាពួក សញ្ញា ។ សង្ខារមានការតាក់តែងចិត្ត ប្រុងចិត្តជាលក្ខណៈ គឺមនោសញ្ចេតនា សេចក្ដីត្រិះរិះក្នុងចិត្ត ក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើម គឺចេតសិកធម៌ដែលកើតក្នុងចិត្តទាំងអស់ លើកលែងតែ វេទនានិងសញ្ញាចេញ ទាំងអស់នេះជាពួកនៃសង្ខារ ។ វិញ្ញាណ មានការដឹងច្បាស់នូវអារម្មណ៍ជាលក្ខណៈ គឺចិត្តដែលអាស្រ័យចក្ខុ សោតៈ - ឃានៈ - ជីវ្ហា - កាយ ចិត្តកើតឡើងជា កុសលខ្លះ, អកុសលខ្លះ, ជាវិបាកខ្លះ, ជាកិរិយាខ្លះ ចិត្តទាំងនេះជា ពួកវិញ្ញាណ ។

ខន្ធទាំង៥ដែលពោលមកនេះ ជាភូមិជាអារម្មណ៍របស់វិបស្សនា ដែលមានខន្ធ៥ជាអារម្មណ៍នោះ មានក្នុងអនិច្ចលក្ខណៈ និង អនត្ត-លក្ខណៈទាំងពីរ ដូចបាលីថា **រូបំ អនិច្ចំ** រូបមិនទៀង **វេទនា អនិច្ចា** វេទនាមិនទៀង **សញ្ញា អនិច្ចា** សេចក្តីចាំបានមិនទៀង **សង្ខារា អនិច្ចា** ធម៌ដែលតាក់តែងចិត្តប្រុងចិត្តមិនទៀង **វិញ្ញាណំ អនិច្ចំ** ចិត្តដែលដឹងច្បាស់នូវអារម្មណ៍មិនទៀង ។ **រូបំ អនត្តា** រូបមិនមែនជាខ្លួនប្រាណ **វេទនា អនត្តា** ការសោយនូវអារម្មណ៍មិនមែនជាខ្លួនប្រាណ **សញ្ញា អនត្តា** សេចក្តីចាំបានមិនមែនខ្លួនប្រាណ **សង្ខារ អនត្តា** ធម៌ដែលតាក់តែងចិត្តប្រុងចិត្តមិនមែនខ្លួនប្រាណ **វិញ្ញាណំ អនត្តា** ចិត្តដែលដឹងច្បាស់នូវអារម្មណ៍មិនមែនខ្លួនប្រាណ ។ **សព្វេ សង្ខារា អនិច្ចា** សង្ខារធម៌ទាំងឡាយទាំងពួងមិនទៀង **សព្វេ ធម្មា អនត្តា** ធម៌ទាំងឡាយទាំងពួងជាសង្ខារនិងវិសង្ខារ មិនមែនជាខ្លួនប្រាណដូច្នេះ ។

បាលីដែលលើកយកមកសំដែងនេះ សំដែងតែចំពោះ អនិច្ច-លក្ខណៈនិងអនត្តលក្ខណៈទាំងពីរយ៉ាងប៉ុណ្ណោះ មិនបានសំដែងទុក្ខលក្ខណៈផងទេ ព្រោះទុក្ខលក្ខណៈរាប់បញ្ចូលក្នុងអនិច្ចលក្ខណៈស្រាប់ហើយ ដោយហេតុថា របស់ណាមិនទៀង របស់នោះជាទុក្ខ កាលបើឃើញអនិច្ចលក្ខណៈហើយ ទុក្ខលក្ខណៈក៏នឹងប្រាកដផង ។ ព្រោះហេតុនោះបាលីនេះ ទើបសំដែងត្រឹមតែអនិច្ចលក្ខណៈ និង អនត្តលក្ខណៈប៉ុណ្ណោះ ។

សាធុជនអ្នកបំពេញសេចកក្តីព្យាយាម គប្បីចំរើនវិបស្សនា ដែលមានខន្ធ៥ជាអារម្មណ៍តាមបាលីដូចបានពោលមកមកនេះចុះ ។ ម្យ៉ាងទៀតវិបស្សនាដែលមានខន្ធ៥ជាអារម្មណ៍ មានក្នុងលក្ខណៈ

ទាំង៣គឺ **អនិច្ចលក្ខណៈ១** **ទុក្ខលក្ខណៈ១** **អនត្តលក្ខណៈ១** ដែលមានក្នុងបាលីថា **រូបំ អនិច្ចំ** រូបមិនទៀង **យទនិច្ចំ តំ ទុក្ខំ** រូបឯណាជារបស់មិនទៀង រូបនោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** រូបឯណាដែលជាទុក្ខ រូបនោះមិនមែនជារបស់ខ្លួនទេ ។ **យទនត្តា តំ នេតំ មម នេសោហមស្មិ នមេសោ អត្តា** រូបឯណាមិនមែនខ្លួន រូបនោះមិនមែនជារបស់យើងទេ រូបនោះមិនមែនជាខ្លួនប្រាណនៃយើងទេ អ្នកទាំងឡាយគប្បីឃើញដោយបញ្ញាដ៏ប្រពៃ តាមពិតរបស់រូបដូច្នេះឯង។ **វេទនា អនិច្ចា** ការសោយអារម្មណ៍ជារបស់មិនទៀង **យទនិច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជាទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោហមស្មិ នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួនជាប្រាណ របស់នោះមិនមែនជារបស់យើង របស់នោះមិនមែនជាខ្លួនប្រាណយើងទេ អ្នកទាំងឡាយគប្បីឃើញដោយបញ្ញាដ៏ប្រពៃចុះ ។ **សញ្ញា អនិច្ចា** ការចាំបានជារបស់មិនទៀង **យទ និច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជា ទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោហមស្មិ នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួនជាប្រាណ របស់នោះមិនមែនជារបស់យើងទេ អ្នកទាំងឡាយគប្បីឃើញដោយបញ្ញាដ៏ប្រពៃចុះ ។ **សង្ខារា អនិច្ចា** ធម៌ដែលតាក់តែងចិត្តប្រុងចិត្តទាំងឡាយ មិនទៀង **យទ និច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជា ទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោហមស្មិ**

**នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួន ជាប្រាណ របស់នោះមិនមែនជារបស់យើងទេ អ្នកទាំងឡាយគប្បីឃើញដោយបញ្ញាដ៏ប្រពៃចុះ ។ **វិញ្ញាណំ អនិច្ចំ** ចិត្តដែលដឹងច្បាស់នូវអារម្មណ៍ ជារបស់មិនទៀង **យទនិច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជាទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោ ហាមស្មិ នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួនជាប្រាណ របស់នោះមិនមែនជារបស់យើងទេ អ្នកទាំងឡាយគប្បីឃើញដោយបញ្ញាដ៏ប្រពៃយ៉ាងនេះចុះ ។

ម៉្យាងទៀត វិបស្សនាដែលមានខន្ធ៥ ទាំងហេតុ ទាំងបច្ច័យបាន និងលក្ខណៈទាំង៣ ដែលមានមកហើយក្នុងបាលីថា **រូបំ អនិច្ចំ** រូបមិនទៀង ធម៌ឯណាជាហេតុជាបច្ច័យឲ្យរូបកើតឡើង សូម្បីធម៌នោះ ក៏មិនទៀងដូចគ្នា រូបដែលកើតឡើងព្រមដោយហេតុដែលមិនទៀងហើយ នឹងបានរបស់ទៀងមកពីណា ។ **វេទនា អនិច្ចា** ការសោយអារម្មណ៍ជារបស់មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យឲ្យវេទនាកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា វេទនាដែលកើតឡើងព្រមដោយហេតុដែលមិនទៀងយ៉ាងនេះហើយ នឹងបានរបស់ទៀងមកពីណា ។ **សញ្ញា អនិច្ចា** ការចាំបានជារបស់មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យឲ្យសញ្ញាកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា សញ្ញាដែលកើតឡើងព្រមដោយហេតុនិងបច្ច័យ ដែលមិនទៀងហើយ នឹងបានជារបស់ទៀងមកអំពីណា ។ **សង្ខារា អនិច្ចា** ធម៌ទាំងឡាយដែលតាក់តែងចិត្ត ប្រុងចិត្ត មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យឲ្យសង្ខារកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា សង្ខារដែលកើត

ឡើងព្រមដោយហេតុ- បច្ច័យដែលមិនទៀងហើយ នឹងបានរបស់ទៀង មកពីណា ។ **វិញ្ញាណំ អនិច្ចំ** ចិត្តដែលដឹងច្បាស់នូវអារម្មណ៍ មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យឲ្យវិញ្ញាណកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា វិញ្ញាណដែលកើតព្រមដោយហេតុ -បច្ច័យមិនទៀងហើយ នឹងបានជារបស់ទៀងស្ថិតស្ថេរមកអំពីណា ។

**រូបជាទុក្ខ** ធម៌ឯណាដែលជាហេតុជាបច្ច័យឲ្យរូបកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា ។ រូបដែលកើតឡើងព្រមដោយហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកពីណា ។ **វេទនាជាទុក្ខ** ធម៌ឯណាដែលជាហេតុជាបច្ច័យឲ្យវេទនាកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា ។ វេទនាដែលកើតឡើងព្រមដោយហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកអំពីណា ។ **សញ្ញាជាទុក្ខ** ធម៌ឯណាដែលជាហេតុជាបច្ច័យឲ្យសញ្ញាកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា ។ សញ្ញាដែលកើតឡើងព្រមដោយហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកអំពីណា ។ **សង្ខារជាទុក្ខ** ធម៌ឯណាដែលជាហេតុជាបច្ច័យឲ្យសង្ខារកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា ។ សង្ខារដែលកើតឡើងព្រមដោយហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកពីណា ។ **វិញ្ញាណជាទុក្ខ** ធម៌ឯណាដែលជាហេតុជាបច្ច័យឲ្យវិញ្ញាណកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា ។ វិញ្ញាណដែលកើតឡើងព្រមដោយហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកពីណា ។

**រូបជាអនត្តា** រូបមិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុបច្ច័យឲ្យរូបកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួនប្រាណដូចគ្នា ។

រូបដែលកើតឡើងព្រមដោយហេតុបច្ច័យជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា ។ **វេទនាជាអនត្តា** មិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុបច្ច័យឲ្យវេទនាកើតឡើង សូម្បីធម៌នោះក៏ជាអនត្តាមិនមែនជាខ្លួនប្រាណដូចគ្នា ។ វេទនាដែលកើតឡើងព្រមដោយហេតុបច្ច័យជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា ។ **សញ្ញាជាអនត្តា** មិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុបច្ច័យឲ្យសញ្ញាកើតឡើង សូម្បីធម៌នោះក៏ជាអនត្តាមិនមែនជាខ្លួនប្រាណដូចគ្នា។ សញ្ញាដែលកើតឡើងព្រមដោយហេតុបច្ច័យជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា ។ **សង្ខារជាអនត្តា** មិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុបច្ច័យឲ្យសង្ខារកើតឡើង សូម្បីធម៌នោះក៏ជាអនត្តាមិនមែនជាខ្លួនប្រាណដូចគ្នា ។ សង្ខារដែលកើតឡើងព្រមដោយហេតុបច្ច័យ ជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា ។ **វិញ្ញាណជាអនត្តា** មិនមែនជាខ្លួនប្រាណ ធម៌ឯណា ជាហេតុបច្ច័យឲ្យវិញ្ញាណកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួនប្រាណដូចគ្នា ។ វិញ្ញាណដែលកើតឡើងព្រមដោយហេតុបច្ច័យ ជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា ។

វិបស្សនាដែលមានខន្ធ៥ព្រមទាំងហេតុបច្ច័យជាអារម្មណ៍ មានក្នុងលក្ខណៈទាំង៣ ដូចមានមកហើយក្នុងបាលីដូច្នេះ ។

ព្រះយោគាវចរកុលបុត្តអ្នកចំរើនវិបស្សនា ដែលមានខន្ធ៥ សុទ្ធជាអារម្មណ៍ក្តី ដែលមានខន្ធ៥ទាំងហេតុបច្ច័យជាអារម្មណ៍ក្តី ដូចន័យដែលមានមកហើយក្នុងបាលី ដូចពោលមកនេះក៏បាន ។ រីឯវិធីចំរើនវិបស្សនា ដែលមានមកក្នុងអដ្ឋកថានោះដូច្នេះ គឺអ្នកបំពេញ

ព្យាយាម បើបានឈានជាសមថយានិកៈហើយ រមែងធ្វើឈានដោយខ្លួនឯងបានឲ្យជាបាទនៃវិបស្សនាហើយ គឺចេញចាកឈានហើយ កំណត់ឈានទាំង៥បាននឹងវិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ទាំងសម្បយុត្តធម៌ដែលកើតឡើងព្រមដោយអង្គឈាននោះ តាមន័យចូលចិត្តឲ្យជាក់ច្បាស់ប្រាកដថា អង្គឈាននិងសម្បយុត្តធម៌ទាំងអម្បាលនេះ ជានាមធម៌ ព្រោះជាធម៌បង្អោនទៅកាន់អារម្មណ៍ ហើយស្វែងរកទីអាស្រ័យរបស់នាមធម៌នោះ ទើបឃើញថាហទយរូបនេះជាទីអាស្រ័យរបស់នាមធម៌នោះ មហាភូតរូប និងឧបាទាយរូប ជាទីអាស្រ័យរបស់ហទយរូបនេះ ទើបសន្និដ្ឋានចូលចិត្តច្បាស់ថា ហទយរូប មហាភូតរូប និងឧបាទាយរូប ទាំងអម្បាលនេះជារូបធម៌ ព្រោះជារបស់តែងទ្រុឌទ្រោមគ្រាំគ្រាទៅជាបច្ច័យ ជាសត្រូវដល់ខ្លួន មានត្រជាក់និងក្តៅជាដើម ។

អ្នកបំពេញព្យាយាម កាលបើបានឈានសមថយានិកៈហើយ រមែងកំណត់ដឹងនូវនាម និងរូបជាក់ច្បាស់ យ៉ាងនេះដូច្នេះឯង ។

ចំណែកខាងវិបស្សនាយានិកៈ អ្នកមានញាណ គឺវិបស្សនា មិនបានឈានសមាបត្តិឯណា កាលដែលចំរើនវិបស្សនា មកកំណត់សង្ខារមាននាមនិងរូបជាដើម ។

ម្យ៉ាងទៀតមកកំណត់កាយ និងចិត្ត-ចេតសិក ដោយប្រភេទនៃពួកទាំង៥ គឺពួករូប ជារបស់ទ្រុឌទ្រោមទៅ១, ពួកវេទនា ការសោយនូវអារម្មណ៍១, ពួកសញ្ញា ការចាំបាននូវអារម្មណ៍១, ពួកសង្ខារ ជាអ្នកតាក់តែងនូវចិត្ត១, ពួកវិញ្ញាណ ជាអ្នកដឹងច្បាស់នូវអារម្មណ៍១ រួមត្រូវជា៥ពួក ។ ការដែលកំណត់កាយនិងចិត្ត-ចេតសិកនេះ ចែកចេញ

ជា៥ពួក ដូចពោលមកហើយ ។ អ្នកបំពេញព្យាយាម នឹងពិចារណាខន្ធទាំង៥ឲ្យជាក់ច្បាស់ តាមលក្ខណៈចំពោះខណ្ឌដូច្នេះ ហើយគប្បីបំប្រួញខន្ធទាំង៥នោះ រួមចូលមកជា២ គឺនាម១ រូប១ ។ រូបខន្ធពួករូបជារូបដដែលព្រោះជារបស់ទ្រុឌទ្រោមទៅជាធម្មតា តែវេទនា-សញ្ញា-សង្ខារ-វិញ្ញាណ អរូបខន្ធទាំង៤នេះជានាម ព្រោះជាធម៌បង្អោនទៅកាន់អារម្មណ៍ ការកំណត់សង្ខារដែលប្រព្រឹត្តទៅក្នុងភពទាំង៣ បំប្រួញចុះជានាមជារូបដូច្នេះហើយ ក៏បានសន្និដ្ឋានជា សត្វ-បុគ្គល-ខ្លួន-ប្រាណ-ទេវតា-មារ-ព្រហ្ម ដទៃៗ ក្រៅចាកនាម និង រូបទៅហើយ មិនមាន ។ មានតែនាមរូបប៉ុណ្ណោះ ប្រព្រឹត្តទៅក្នុងភពទាំង៣ ។ ក៏ពាក្យថា សត្វ-បុគ្គល ខ្លួន-ប្រាណ ជាដើមនោះ មិនមានដោយបរមត្ថ មកបញ្ញត្តិសម្មតិនាម-រូបនោះឯង ថាជាសត្វ-បុគ្គល ខ្លួនប្រាណជាដើម បីដូចជាសម្មតិឈើ ថាជាក្រប-ទូកដូច្នោះ ក៏នាម-រូបទាំង២នេះ អាស្រ័យគ្នានឹងគ្នា ហើយក៏លឿនទៅក្នុងសង្សារ បីដូចជាមនុស្សយើងហើយនឹងទូក ទាំងពីរអាស្រ័យគ្នានឹងគ្នាហើយ លឿនទៅក្នុងសមុទ្ទសាគរដូច្នោះ ។ ការកំណត់នាមនិងរូប បានដឹងច្បាស់តាមពិតលះសត្តូបលទ្ធិសត្តញាណចេញ បានតាំងនៅក្នុងភាព ជាអ្នកមិនវង្វេងក្នុងបញ្ញត្តិ ថាសត្វ-បុគ្គល ខ្លួន-ប្រាណជាដើម ដូច្នេះហើយទិដ្ឋិសេចក្តីឃើញរបស់អ្នកបំពេញព្យាយាមនោះក៏បរិសុទ្ធដោយល្អ ឈ្មោះថា **ទិដ្ឋិ-វិសុទ្ធិ** ជាតួវិបស្សនាទី១។

សាធុជនអ្នកបំពេញព្យាយាមធ្វើឲ្យទិដ្ឋិបរិសុទ្ធ បរិបូណ៌ឡើងហើយ គួរចំរើនវិបស្សនាតទៅ ស្វែងរកហេតុបច្ច័យរបស់នាម-រូបនោះ បីដូចជាពេទ្យអ្នកឆ្លាតក្នុងការរក្សារោគ កាលបើឃើញរោគហើយ ក៏រមែង

ស្វែងរកសមុដ្ឋាននៃរោគនោះ យ៉ាងណាមិញ អ្នកបំពេញព្យាយាម កាលបើដឹងនាម-រូបច្បាស់ហើយ គួរស្វែងរកហេតុ-បច្ច័យរបស់នាម-រូបនោះដែរ កាលបើដឹង ហេតុ-បច្ច័យរបស់នាម-រូបនោះច្បាស់ហើយ ក៏រមែងឆ្លងផុតចាកកង្ខា គឺសេចក្តីសង្ស័យក្នុងកាលទាំង៣បាន ។

អ្វីជាហេតុបច្ច័យរបស់នាម-រូបនោះ? ហើយនាម-រូបនោះអាស្រ័យរបស់អ្វីទើបកើត ឡើង?

កម្មជាហេតុ-បច្ច័យរបស់នាម-រូបនោះ នាម-រូបនោះជាតួវិបាកផលសុខវិសេសរបស់កម្ម អាស្រ័យកម្មទើបកើតឡើងបាន ។ កម្មនោះមាន២យ៉ាងគឺ *កុសលកម្ម១ អកុសលកម្ម១* ។ នាម-រូបឯណាកើតឡើងដោយអកុសលកម្ម នាម-រូបនោះជារបស់ទុព្វលភាព (ថោកទាប) ។ នាម-រូបឯណាដែលកើតឡើងដោយអាស្រ័យកុសលកម្ម នាម-រូបនោះជារបស់សុខុម(ល្អិត) ដោយហេតុដូច្នេះទើបបានថា កម្មជាហេតុជាបច្ច័យរបស់នាម-រូបនោះ ។ តែបើគ្រាន់តែកម្មម៉្យាង ក៏មិនជាហេតុឲ្យកើតនាម-រូប ក៏ត្រូវអាស្រ័យឧបាទាន គ្រឿងប្រកាន់ខ្ជាប់ និងឆន្ទៈរាគៈសេចក្តីគាប់ចិត្តត្រេកអរ ឧបាទានត្រូវអាស្រ័យនឹងតណ្ហា សេចក្តីចំណង់ជាហេតុឲ្យអន្ទះអន្ទែងទៅ តណ្ហាក៏ត្រូវអាស្រ័យនឹងអវិជ្ជា សេចក្តីមិនដឹងច្បាស់ មិនដឹងតាមសេចក្តីពិត ព្រោះហេតុនោះ អវិជ្ជាទើបជាបច្ច័យរបស់តណ្ហា តណ្ហាជាបច្ច័យរបស់ឧបាទាន ឧបាទានជាបច្ច័យរបស់កម្ម (គឺភព) ភពជាបច្ច័យរបស់ជាតិ គឺនាម-រូប ដោយន័យនេះទើបបានការសន្និដ្ឋានឃើញច្បាស់ថា ធម៌ទាំង៤យ៉ាងគឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម ជាហេតុ-បច្ច័យរបស់នាម-រូបនោះ ។ នាម-រូបនោះត្រូវអាស្រ័យធម៌៤យ៉ាងនេះ ទើបកើតឡើងហើយប្រព្រឹត្តទៅ ។

មហាភូតរូប៤គឺ ដី-ទឹក-ភ្លើង-ខ្យល់ និងអាហារ ជាបច្ច័យរបស់រូបធម៌ ដោយឧបត្ថម្ភរូបនោះទុក ។ ផស្សៈជាបច្ច័យរបស់នាមធម៌គឺ វេទនា-សញ្ញា-សង្ខារ នាមធម៌ទាំង៣នេះ អាស្រ័យបច្ច័យគឺផស្សៈកើតឡើង ហើយទើបប្រព្រឹត្តទៅបាន ។ នាម-រូបជាបច្ច័យរបស់នាមធម៌ គឺវិញ្ញាណ ព្រោះវិញ្ញាណ នោះអាស្រ័យចក្ខុនិងរូបទាំងពីរហើយកើតឡើង ទើបបានឈ្មោះថា ចក្ខុវិញ្ញាណ, បើអាស្រ័យសោតៈនិងសម្លេងទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា សោតវិញ្ញាណ, បើអាស្រ័យឃានៈនិងខ្លិនទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា ឃានវិញ្ញាណ, បើអាស្រ័យជីវ្ហានិងរសទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា ជិវ្ហាវិញ្ញាណ, បើអាស្រ័យកាយនិងសម្ផស្សទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា កាយវិញ្ញាណ, បើអាស្រ័យចិត្តនិងធម្មាទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា មនោ-វិញ្ញាណ ។ ចក្ខុវិញ្ញាណ, សោតវិញ្ញាណ,ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ, កាយវិញ្ញាណ ទាំង៥នេះមានរូបតែម៉្យាងជាបច្ច័យ អាស្រ័យរូបហើយប្រព្រឹត្តទៅ ។ ឯមនោវិញ្ញាណ មាននាម-រូបទាំងពីរជាបច្ច័យ អាស្រ័យនាម-រូបទាំងពីរនេះហើយកើតឡើងប្រព្រឹត្តទៅ ។ ដោយហេតុនេះ នាមនិងរូបទើបជាបច្ច័យរបស់នាមធម៌ គឺវិញ្ញាណ វិញ្ញាណអាស្រ័យនាមនិងរូបទាំងពីរនេះកើតឡើងហើយប្រព្រឹត្តទៅ ។ បានសេចក្ដីសន្និដ្ឋានឃើញច្បាស់ថា **អវិជ្ជា, តណ្ហា, ឧបាទាន, កម្ម, អាហារ** ជាហេតុបច្ច័យរបស់រូបធម៌ ។ រូបធម៌អាស្រ័យនូវបច្ច័យទាំង៥យ៉ាងនេះកើតឡើងហើយប្រព្រឹត្តទៅ ។ **អវិជ្ជា, តណ្ហា, ឧបាទាន, កម្ម, ផស្សៈ** ជាបច្ច័យរបស់នាមធម៌គឺ **វេទនា, សញ្ញា, សង្ខារ** អាស្រ័យនូវបច្ច័យទាំង៥

យ៉ាងនេះកើតឡើងហើយប្រព្រឹត្តទៅ ។ **អវិជ្ជា, តណ្ហា, ឧបាទាន, កម្ម, នាមនិងរូប** ជាហេតុ-បច្ច័យ របស់នាមធម៌គឺ វិញ្ញាណ អាស្រ័យនូវបច្ច័យទាំង៥ យ៉ាងនេះកើតឡើងហើយប្រព្រឹត្តទៅ ។

កាលបើអ្នកខំបំពេញព្យាយាម មកកំណត់ហេតុ-បច្ច័យរបស់នាម-រូប ជាក់ច្បាស់ដោយប្រការដូច្នេះហើយ គប្បីចូលចិត្តច្បាស់ថា នាម-រូប ដែលជាបច្ច័យនោះ អាស្រ័យហេតុ-បច្ច័យ ហើយប្រព្រឹត្តទៅយ៉ាងណា សូម្បីនាម-រូបដែលជាអតីត-អនាគតក្តី រមែងអាស្រ័យហេតុ-បច្ច័យកើតឡើងហើយប្រព្រឹត្តទៅដូច្នេះឯង ។

កាលបើអ្នកបំពេញព្យាយាម កំណត់ហេតុ-បច្ច័យរបស់នាម-រូប ជាក់ច្បាស់ដូច្នេះហើយ រមែងកន្លងកង្ខា គឺសេចក្តីសង្ស័យក្នុងកាលទាំង៣ កង្ខាក្នុងកាលទាំង៣នោះគឺ កង្ខាប្រារព្ធចំណែកខាងអតីតកន្លងហើយនោះ៥ កង្ខាចំណែកខាងអនាគតខាងមុខ ដែលមិនទាន់មកដល់៥ កង្ខាក្នុងបច្ចុប្បន្ននេះ៦ រួមត្រូវជាកង្ខា១៦យ៉ាងក្នុងកាលទាំង៣ ។

**សង្ស័យក្នុងអតីត៥យ៉ាងនោះគឺ:**

១-សង្ស័យថា ដូចជាអញរំពឹងទៅ ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញកើតជាអ្វីអេះ !

២-សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញមិនបានកើតជាអ្វីទេ ឬអេះ !

៣-សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញជាខត្តិយជាតិ ឬព្រាហ្មណជាតិ ឬក៏ជាអ្នកស្រែ អ្នកឈ្នួញទេអេះ !

៤-សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញមានសណ្ឋានទ្រង់ទ្រាយធំ ឬ តូច ខ្មៅឬស ល្អឬអាក្រក់អេះ !

៥-សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញដើមដំបូងកើតជាអ្វី ដល់មកខាងក្រោយ អាត្មអញកើតជាអ្វីអេះ ? ។

រួមមកត្រូវជា សង្ស័យក្នុងអតីត៥ប្រការ ។

**សង្ស័យក្នុងអនាគត៥គឺ:**

១-សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតជាអ្វីហ្ន៎ !

២-សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតទៀតដែរឬហ្ន៎ !

៣-សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងបានកើតជាខត្តិយជាតិ ឬព្រាហ្មណជាតិ ឬក៏ជាអ្នកស្រែ អ្នកឈ្មួញ ក្រីក្ររហេមរហាម យ៉ាងណាទៅអេះ !

៤-សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតជាអ្នកមានសណ្ឋានទ្រង់ទ្រាយធំ តូច ខ្ពស់ ទាប ខ្មៅ ស ដូចម្ដេចទៅហ្ន៎ !

៥-សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតជាអ្វីតពីនោះទៅនឹងទៅកើតជាអ្វី ទៀតអេះ ! ។

រួមមកត្រូវជាសង្ស័យក្នុងអនាគត៥ប្រការ ។

**សង្ស័យក្នុងបច្ចុប្បន្ន៦នោះគឺ:**

១-សង្ស័យថា ដូចជាអញរំពឹងទៅ សព្វថ្ងៃនេះមានឈ្មោះថាខ្លួនអញមែន ឬមិនមែន ខ្លួនអញទេ !

២-សង្ស័យថា ដូចជាអញគិតទៅ សព្វថ្ងៃនេះមិនមានឈ្មោះថាខ្លួនអញទេ ឬដូចម្ដេច !

៣-សង្ស័យថា សព្វថ្ងៃនេះបានឈ្មោះថា អាត្មាអញកើតក្នុងខត្តិយជាតិ ឬព្រាហ្មណជាតិ ឬក៏ជាអ្នកស្រែ អ្នកឈ្មួញ អ្នកគ្រូឬជាដូចម្ដេច !

៤-សង្ស័យថា សព្វថ្ងៃនេះបានឈ្មោះថា អាត្មាអញកើតបានជារូបរាង ពណ៌សម្បុរ សណ្ឋានទ្រង់ទ្រាយធំ តូច ខ្ពស់ ទាប ខ្មៅ ស ល្អ អាក្រក់ ដូចម្ដេចទៅ !

៥-សង្ស័យថា សត្វនេះមកអំពីណា មកកើតក្នុងទីនេះអេះ !

៦-សង្ស័យថា សត្វនេះមកកើតក្នុងទីនេះហើយ នឹងទៅកើតក្នុងទីណាទៀតអេះ ! ។ រួមត្រូវជាសង្ស័យក្នុងបច្ចុប្បន្ន៦ប្រការ ។ រួមកង្ខាទាំង អតីត៥ អនាគត៥ បច្ចុប្បន្ន៦ ត្រូវជា១៦យ៉ាងដូច្នេះ ។

ការកំណត់នាម-រូបឃើញជាក់ច្បាស់យ៉ាងនេះហើយ រមែងឆ្លងចាកកង្ខាទាំង១៦យ៉ាងបាន ជាអ្នកមិនមានសង្ស័យក្នុងចំណែកអតីត អនាគត បច្ចុប្បន្ន ហើយបញ្ញារបស់អ្នកបំពេញ ព្យាយាមនោះ នឹងមានកម្លាំងក្លៀវក្លា ទើបឈ្មោះថា **កង្ខាវិតរណវិសុទ្ធិ** ជាតួវិបស្សនាទី២ ។

ព្រះយោគាវចរបុគ្គល កាលបើកំណត់ដឹងហេតុ-បច្ច័យរបស់នាម-រូបជាក់ច្បាស់ ដរាបកន្លងចាកកង្ខាក្នុងកាលទាំង៣បានហើយ គួរខំចំរើនវិបស្សនាបញ្ញាតទៅ គឺពិចារណានាម-រូបដែលជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្រៅឬខាងក្នុង ឬគ្រោកគ្រាក ឬសុខុម ថោកទាប ឬឧត្តម ឆ្ងាយឬជិត ឲ្យឃើញនាម-រូបទាំងអស់ជារបស់មិនទៀងពិតបានសេចក្ដីថាសង្ខារទាំងឡាយ កើតឡើងហើយក៏រលត់អស់ទៅក្នុងកាលនោះៗ ។ ក៏នាម-រូបឯណាជាអតីត នាម-រូប នោះក៏រលត់ទៅក្នុងអតីត មិនមានមកដល់បច្ចុប្បន្ននេះទេ ។ នាម-រូបឯណាដែលជាអនាគត នាម-រូបនោះក៏រលត់ទៅក្នុងអនាគត មិនមានទៅដល់អនាគតខាងមុខទៀតឡើយ ។ នាម-រូប ឯណាដែលជាបច្ចុប្បន្នន នាម-រូបនោះក៏រលត់ទៅក្នុងបច្ចុប្បន្ន មិនមានទៅដល់អនាគតខាងមុខទៀតឡើយ ។

នាម-រូបឯណាដែលជាខាងក្នុង នាម-រូបនោះក៏រលត់ទៅខាងក្នុង មិនមែនមក រលត់ខាងក្រៅឡើយ ។ នាម-រូបឯណាដែលជាខាងក្រៅ នាម-រូបនោះក៏រលត់ទៅខាងក្រៅ មិនមែនមក រលត់ខាងក្នុងឡើយ ។ នាម-រូបឯណាដែលជាគ្រោកគ្រាក នាម-រូបនោះក៏រលត់ទៅតាមសភាពគ្រោកគ្រាកទៅ មិនមែនរលត់តាមសភាពល្អិតឡើយ ។ នាម-រូបឯណាដែល ល្អិត នាម-រូបនោះក៏រលត់ទៅតាមសភាពល្អិត មិនមែនរលត់ទៅដោយសភាពជានាម-រូប គ្រោកគ្រាកឡើយ ។ នាម-រូបឯណាដែលថោកទាប នាម-រូបនោះក៏រលត់ទៅក្នុងសភាពជា នាម-រូបថោកទាប មិនដល់សភាពជានាម-រូបឧត្តមឡើយ ។ នាម-រូបឯណាដែលឧត្តម នាម-រូប នោះក៏រលត់ទៅក្នុងសេចក្តីជានាម-រូបឧត្តម មិនមែនដល់នូវសភាពជានាម-រូបថោកទាបឡើយ នាម-រូបឯណាដែលឆ្ងាយ នាម-រូបនោះក៏រលត់ទៅក្នុងទីឆ្ងាយទៅ មិនមែនដល់នូវសភាពជា នាម-រូបជិតបានឡើយ ។ នាម-រូបឯណាដែលជិត នាម-រូប នោះក៏រលត់ទៅក្នុងទីជិត មិនដល់នូវសភាពជានាម-រូបឆ្ងាយបានឡើយ ។ ព្រោះហេតុនោះ នាម-រូបទាំងអស់ជារបស់មិនទៀងពិត ព្រោះកើតឡើងហើយរលត់អស់ទៅក្នុងកាលនោះៗ មិនកន្លងកាលនោះៗ បានឡើយ ។

នាម-រូបឯណាដែលជារបស់មិនទៀង នាម-រូបនោះជាទុក្ខ ព្រោះការកើតឡើងហើយ រលត់អស់ទៅជានិច្ច ឥតឈប់ឡើយ ។ នាម-រូបឯណាជារបស់ទុក្ខ នាម-រូបនោះជារបស់អនត្តាមិនមែនជាខ្លួនប្រាណមិនមានពិត គឺគ្រាន់តែជានាម-រូបប៉ុណ្ណោះឯង ។ ក៏នាម-រូបនោះមិនមែនជារបស់យើងមិនមែនជាខ្លួនប្រាណរបស់យើងមិនមែនជាយើងឡើយ ។

កាលព្រះយោគាវចរមកប្រារព្ធវិបស្សនាដោយល្អដូច្នេះ ធម៌១០យ៉ាង ក៏កើតឡើងគឺ:

១-ឱភាសៈ ពន្លឺភ្លឺស្វាងកើតអំពីវិបស្សនាចិត្ត ផ្សាយចេញចាក សរីរាវយវៈ ។

២-បីតិ ផ្សាយចេញទៅសព្វសព៌ាង្គកាយ ធ្វើកាយនិងចិត្តឲ្យឆ្អែត កើតឡើងដោយវិបស្សនាចិត្ត ។

៣-វិបស្សនាញាណ ចាស់ក្លាឃើញនាម-រូបជាក់ច្បាស់ដោយល្អ កើតឡើង ។

៤-បស្សទ្ធិ សេចក្ដីស្ងប់កាយស្ងប់ចិត្ត រម្ងាប់ក្រវល់ក្រវាយចេញ បានដោយល្អ កើតឡើងដោយវិបស្សនាចិត្ត ។

៥-សុខៈ ប្រព្រឹត្តទៅក្នុងកាយនឹងចិត្តដ៏ឧត្ដម កើតឡើងដោយ វិបស្សនាចិត្ត ។

៦-អធិមោក្ខៈ សេចក្ដីជឿខ្ជាប់ មានកម្លាំងខ្លាំងក្លា ជាទីផ្ទរផង់ របស់ចិត្តនិងចេតសិក កើតឡើងដោយវិបស្សនា ។

៧-បគ្គាហៈ សេចក្ដីព្យាយាម មិនតឹងមិនធូរ ផ្គងចិត្តទុកដោយល្អ ក្នុងអារម្មណ៍ ធ្វើឲ្យចិត្តប្រព្រឹត្តទៅស្មើបាន កើតឡើងដោយវិបស្សនា ។

៨-ឧបដ្ឋានៈ សតិតាំងភ្ជាប់ រក្សានូវអារម្មណ៍ទុក ធ្វើឲ្យប្រាកដ ដោយល្អ ដូចជាបរលោកប្រាកដមានដល់អ្នកមានទិព្វចក្ខុដូច្នោះ ។

៩-ឧបេក្ខា សេចក្ដីឃើញធម៌ជាកណ្ដាលក្នុងសង្ខារទាំងអស់ មាន កម្លាំងខ្លាំងក្លាកើតឡើង ។

១០-និកន្តិ សេចក្តីស្រឡាញ់មានអាការៈសុខុម ធ្វើឲ្យអាល័យក្នុងវិបស្សនាកើតឡើង ។

ធម៌ទាំង១០យ៉ាងនេះ ជាឧបក្កិលេសគ្រឿងសៅហ្មងរបស់វិបស្សនា ព្រោះកើតឡើងហើយ ធ្វើអ្នកចំរើនវិបស្សនាឲ្យវង្វេង ទៅសំគាល់ថា មគ្គ-ផលកើតឡើងដល់ខ្លួន ។ ខ្លួនថាមគ្គ- ផលហើយក៏បញ្ឈប់សេចក្តីព្យាយាម មិនចំរើនវិបស្សនាតទៅទៀត ក៏កើតតណ្ហា-មានៈ-ទិដ្ឋិ ថារបស់គេ របស់យើង ខ្លួន-ប្រាណយើងឡើងទៀត ។ ព្រោះហេតុដូច្នោះ ធម៌ទាំង១០យ៉ាងនេះ ទើបបានថា ជាឧបក្កិលេសគ្រឿងសៅហ្មងរបស់វិបស្សនា ។ ព្រះយោគាវចរមកប្រារព្ធវិបស្សនាដោយល្អ កាលបើឧបក្កិលេសទាំង១០យ៉ាងឯណានិមួយៗកើតឡើងហើយមិនត្រេកអរ មិនវង្វេងក្នុងធម៌ឧបក្កិលេសដែលកើតឡើងនោះមិនបញ្ឈប់សេចក្តីព្យាយាមរបស់ខ្លួនចេញ ដោយចូលចិត្តជឿច្បាស់ថាមិនមែនជាមគ្គ-ផល មិនមែនជាផ្លូវវិបស្សនា ផ្លូវវិបស្សនាផ្សេងៗដែលយើងគប្បីដំណើរទៅ ។ វិបស្សនាបញ្ញារបស់អ្នកបំពេញព្យាយាមចាស់ក្លា ដឹងឃើញជាក់ច្បាស់ថា នេះជាផ្លូវមគ្គ-ផល នេះមិនមែនជាផ្លូវមគ្គ-ផល បានដោយល្អយ៉ាងនេះ ឈ្មោះថា **មគ្គាមគ្គញាណ-ទស្សនវិសុទ្ធិ** ជាតួវិបស្សនាទី៣ ។

អ្នកចំរើនវិបស្សនា កាលបើមានបញ្ញាចាស់ក្លា ធ្វើមគ្គាមគ្គញាណ-ទស្សនវិសុទ្ធិ ឲ្យបរិបូណ៌ហើយ វិនិច្ឆ័យបានឃើញច្បាស់ថា នេះជាតួអរិយមគ្គ នេះជាតួឧបក្កិលេស មិនមែនជាតួអរិយមគ្គដូច្នេះ ហើយគួរចំរើនវិបស្សនាញាណទាំង៩ប្រការ ដ៏បរិសុទ្ធផុតចាកឧបក្កិលេសហើយ ដើម្បីនឹងឲ្យបានអរិយមគ្គខាងលើតទៅ ។

**វិបស្សនាញាណទាំង៩នោះគឺៈ**

១- ឧទយព្វយញ្ញាណ

២- ភង្គញ្ញាណ

៣- ភយតូបដ្ឋានញ្ញាណ

៤- អាទីនវញ្ញាណ

៥- និព្វិទាញាណ

៦- មុញ្ចិតុកាម្យតាញាណ

៧- បដិសង្ខាញាណ

៨- សង្ខារុបេក្ខាញាណ

៩- សច្ចានុលោមញ្ញាណ

ក្នុងញាណទាំង៩នេះ បញ្ញាដែលដឹងច្បាស់នូវសេចក្តីកើតឡើងផង សេចក្តីរលត់អស់ទៅផង របស់នាមរូបនោះឈ្មោះថា ឧទយព្វ-យញ្ញាណ នេះពោលដោយសេចក្តីសង្ខេប ។ បើពោលជា និប្បរិយាយវិញថា អ្នកបំពេញសេចក្តីព្យាយាមគប្បីពិចារណាជា និព្វត្តលក្ខណៈ គឺសេចក្តីកើតឡើង៥ និង វិបរិណាមលក្ខណៈ គឺសេចក្តីរលត់ទៅ៥របស់ខន្ធ៥ ដោយន័យនេះ ក្នុងខមួយៗ មានលក្ខណៈ១០ៗ ទាំងកើតទាំងរលត់ខន្ធទាំង៥ នេះរួមទាំងកើតទាំងរលត់ (៥x១០=៥០) ត្រូវជា៥០គត់ ។ ក្នុងរូបខន្ធនោះឲ្យបំពេញព្យាយាម គប្បីពិចារណាជានិព្វត្តលក្ខណៈ គឺ កើតឡើង៥យ៉ាង រូបកើតក៏ព្រោះអវិជ្ជា សេចក្តី

មិនច្បាស់កើតឡើង១ តណ្ហា១ ព្រោះកម្មជាកុសល-អកុសល កើតឡើង១ ព្រោះអាហារជាគ្រឿងឧបត្ថម្ភកើតឡើង១ គឺសេចក្តីកើតឡើងរបស់សត្វតែម៉្យាងមិនអាស្រ័យហេតុ-បច្ច័យ១ រួមជានិព្វត្តលក្ខណៈសេចក្តីកើតរបស់រូបក្ខន្ធ៥យ៉ាងដូច្នេះ ។ គប្បីឃើញ វិបរិណាមលក្ខណៈក្នុងរូបក្ខន្ធទាំង៥យ៉ាងដូច្នេះ គឺរូបដែលរលត់ទៅព្រោះអវិជ្ជារលត់១ ព្រោះតណ្ហារលត់ទៅ១ ព្រោះកម្មរលត់អស់ទៅ១ ព្រោះអាហាររលត់អស់ទៅ១ ព្រោះរលត់អស់ទៅនៃរូបតែម៉្យាងមិនមានហេតុ-បច្ច័យ១ រួមជាវិបរិណាមលក្ខណៈ៥យ៉ាងដូច្នេះ ។ អ្នកបំពេញសេចក្តីព្យាយាមពិចារណានិព្វត្តលក្ខណៈ៥ និង វិបរិណាមលក្ខណៈ៥ ជា១០ផងគ្នារបស់រូបក្ខន្ធដូច្នេះ ។ រួចហើយត្រូវពិចារណានិព្វត្តលក្ខណៈ៥ វិបរិណាម-លក្ខណៈ៥ របស់វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធផងឲ្យដូចជាពិចារណាក្នុងរូបក្ខន្ធដូច្នោះ ផ្សេងគ្នាតែក្នុងវេទនា-សញ្ញា-សង្ខារនិងវិញ្ញាណ ត្រង់អាហារឲ្យផ្លាស់យកផស្សៈ ដាក់ជំនួសដូច្នេះថា វេទនាកើតឡើងព្រោះផស្សៈកើតឡើងដែរ វេទនារលត់ទៅក៏ព្រោះផស្សៈរលត់ទៅ ។ (សញ្ញាក្តី សង្ខារក្តី មានន័យ ដូចគ្នានឹងវេទនា) ។ រីឯវិញ្ញាណ ត្រង់អាហារឲ្យយកនាម-រូប ជំនួសដូចតទៅនេះថា វិញ្ញាណកើតមានព្រោះនាម-រូបកើតឡើង វិញ្ញាណនោះរលត់ទៅក៏ព្រោះនាម-រូបរលត់ ។ និព្វត្តលក្ខណៈនិង វិបរិណាមលក្ខណៈរបស់វេទនា, សញ្ញា, សង្ខារ និង វិញ្ញាណប្លែកគ្នា មិនដូចលក្ខណៈរបស់រូបតែប៉ុណ្ណោះ ។ បញ្ញាដែលដឹងនិព្វត្តលក្ខណៈនិង វិបរិណាមលក្ខណៈក៏កើតឡើងហើយរលត់ទៅរបស់ខន្ធ៥ដូច្នេះ ឈ្មោះថាឧទយព្វយញ្ញាណ ដែលបង្ហាញឲ្យចំរើនឃើញច្បាស់ថានាម-រូប ជារបស់មិនទៀងពិត ។

២- ភង្គញ្ញាណ បញ្ញាដែលពិចារណាតាមសេចក្តីរលត់របស់សង្ខារតែម៉្យាង មិនពិចារណាហេតុ គឺសេចក្តីកើតឡើង ពិចារណាតែត្រឹមផល គឺសេចក្តីបែកធ្លាយទៅនៃសង្ខារតែម៉្យាងប៉ុណ្ណោះ ជារបស់ពិតដូច្នេះថា សង្ខារទាំងអស់រមែងបែកធ្លាយទៅជាធម្មតា សេចក្តីដែលមិនបែកធ្លាយទៅនៃសង្ខារនោះមិនមានឡើយ ឧបមាដូចជាពពុះទឹកមានដុំធំ-តូច យ៉ាងណាៗក្តី មានកិរិយាបែកធ្លាយទៅវិញជាធម្មតា ។

ក៏ចិត្តឯណា មានរូបជាអារម្មណ៍កើតឡើងហើយ រមែងបែកធ្លាយទៅ អ្នកបំពេញព្យាយាមគប្បីពិចារណាឲ្យឃើញ ការបែកធ្លាយទៅនៃចិត្តនោះជាអារម្មណ៍ ។ ម៉្យាងទៀត ចិត្តឯណាដែលមានវេទនា, សញ្ញា, សង្ខារ វិញ្ញាណ ជាអារម្មណ៍ក្តី គប្បីពិចារណាឲ្យឃើញការបែកធ្លាយទៅ នៃចិត្តនោះៗជាអារម្មណ៍ដូច្នេះ នេះជាកិច្ចរបស់ភង្គញ្ញាណ ។

៣- ភយតូបដ្ឋានញ្ញាណ បញ្ញារបស់អ្នកបំពេញព្យាយាមដឹងនូវសេចក្តីកើតឡើង និងសេចក្តីរលត់ទៅនៃសង្ខារចាស់ភ្លា ដរាបណាសង្ខារទាំងអម្បាលនេះ ប្រាកដជាភ័យគួរឲ្យខ្លាច ដូចជាគេឃើញភ្លើងឆេះផ្ទះ នេះឈ្មោះថា ភយតូបដ្ឋានញ្ញាណ ។

៤- អាទីនវញ្ញាណ កាលឃើញភយតូបដ្ឋានញ្ញាណ គឺឃើញ ថាសង្ខារជាភ័យធំគួរឲ្យខ្លាចប្រាកដជាក់ច្បាស់ដូច្នោះហើយ ទើបមិនមានសេចក្តីត្រេកអរក្នុងសង្ខារទាំងអម្បាលនោះឡើយ ដូចជាបុគ្គលស្រឡាញ់ជីវិត ដឹងថាភោជនាហាររលាយទៅដោយថ្នាំពិសហើយ ក៏មិនហ៊ានបរិភោគដូច្នោះ ឬដឹងថា ស្ទឹងមានក្រពើធំកាច គួរខ្លាចមិនហ៊ានចុះទៅងូតទឹកឡើយ ។ បញ្ញាឃើញទោសរបស់សង្ខារសព្វយ៉ាងនេះ ដរាប

តែមិនត្រេកអរក្នុងសង្ខារ ដូចបានពោលមកហើយនេះឈ្មោះថា អាទីនវញ្ញាណ ។

៥-និព្វិទាញាណ បុគ្គលបានចំរើនអាទីនវញ្ញាណ ឲ្យមានកម្លាំងចាស់ក្លា លុះកណាដែលមាននិព្វិទា គឺសេចក្តីនឿយណាយស្អប់ខ្ពើមក្នុងសង្ខារទាំងអម្បាលនោះ មិនត្រេកអររីករាយ ឧបមាដូចបុគ្គលឃើញទោសរបស់ភរិយា ហើយនឿយណាយស្អប់ខ្ពើមភរិយាដូច្នោះឯង ឈ្មោះថា និព្វិទាញាណ ។

៦- មុញ្ចិតុកាម្យតាញាណ ចិត្តរបស់អ្នកចំរើននោះ មិនជាប់ជំពាក់ ក្នុងសង្ខារឯណានិមួយឡើយ មានបំណងតែនឹងដោះខ្លួនចេញចាកអំពីសង្ខារទាំងឡាយនោះ ព្រោះសេចក្តីនឿយណាយចំពោះសង្ខារ បីដូចជាសត្វនៅក្នុងទ្រុងឬក្នុងអន្ទាក់ ចង់តែរួចចាកទៅខាងក្រៅដូច្នោះ ឈ្មោះថា មុញ្ចិតុកាម្យតាញាណ ។

៧-បដិសង្ខាញាណ កាលបើព្យាយាមធ្វើមុញ្ចិតុកាម្យតាញាណឲ្យបរិបូណ៌ហើយ ប្រាថ្នាឲ្យរួចចាកសង្ខារទាំងអម្បាលនោះ ហើយលើកសង្ខារទាំងនោះឡើងកាន់ព្រះត្រៃលក្ខណ៍ កំណត់ពិចារណាដោយបដិសង្ខានុបស្សនាញាណ ដើម្បីធ្វើឧបាយឲ្យផុតចេញចាកសង្ខារទាំងនោះឡើង ទើបពិចារណាឃើញថា សង្ខារទាំងអស់ជារបស់មិនទៀងពិតព្រោះកើតឡើងហើយរលត់សូន្យទៅវិញ ឲ្យពិចារណាក្នុងលក្ខណៈទាំង៣ ដើម្បីឲ្យសម្រេចឧបាយដោះចេញ ចាកសង្ខារទាំងអម្បាលនោះ ប្រៀបដូចបុរសអ្នកនេសាទចាប់មច្ឆាជាតិ យកអង្រុតទៅរុតត្រី ក្នុងទឹកហើយលូកដៃចុះទៅតាមមាត់អង្រុត គិតនឹងចាប់ត្រីដោយសេចក្តីត្រេកអរ តែថាជាសត្វអាសិរពិសសោះ កាលបើចាប់លើកឡើងមក

ស្រាប់តែឃើញសត្វអាសិរពិស ទើបខ្លាចតក់ស្លុតរន្ធត់ ឃើញទោសក្នុងការចាប់កាន់នោះ ក៏ប្រាថ្នានឹងលែងចោលសត្វអាសិរពិសនោះទៅវិញ ទើបចាប់ត្រង់កន្ទុយលាតផ្ទត់ចេញចាកដើមដៃ ហើយលើកឡើងក្រវីលើក្បាលជាច្រើនជុំ ធ្វើឲ្យសត្វអាសិរពិសនោះទុព្វលភាព ថយកម្លាំងមិនអាចនឹងខាំបាន ក៏រលាស់បោះចោលទៅអំពីដៃ ហើយប្រញាប់ប្រញាល់រត់ឡើងមកលើគោក សម្លឹងមើលផ្លូវដែលសត្វអាសិរពិសវារលូនមក សម្លឹងមើលទៅហើយមិនឃើញ ក៏ត្រេកអរ នឹកថាផុតហើយៗចាកភ័យធំព្រោះតែសត្វអាសិរពិសនោះ មានឧបមាដូចម្តេចមិញ ឧបមេយ្យថា ដូចជាអ្នកព្យាយាមបានអត្តភាពគឺ បញ្ចក្ខន្ធនេះក៏ត្រេកអរប្រកាន់ខ្ជាប់ថា យើង របស់យើង ដូចជាបុរសចាប់សត្វអាសិរពិសក្នុងទឹកបាន ហើយត្រេកអរចាប់ទុកជាប់ ដោយសំគាល់ថាជាមច្ឆាជាតិដូច្នោះ ។ អ្នកបំពេញព្យាយាម កាលបើឃើញអត្តភាពគឺបញ្ចក្ខន្ធនេះ ថាមិនទៀង ជាទុក្ខ ជាអនត្តាពិតហើយ ក៏មានសេចក្តីភ័យតក់ស្លុតរន្ធត់ខ្លាចបញ្ចក្ខន្ធនោះ ដោយភយតូបដ្ឋានញ្ញាណ ដូចជាបុរសលើកដៃឡើងចាប់មាត់អង្រុត ហើយឃើញក្បាលសត្វអាសិរពិស ខ្លាចដូច្នោះឯង ។ វាយមបុគ្គល កាលបើឃើញទោសរបស់បញ្ចក្ខន្ធនេះដោយអាទីនវញ្ញាណហើយ នឿយណាយចំពោះ បញ្ចក្ខន្ធនេះដោយនិព្វិទានោះៗ បញ្ញារបស់បុគ្គលអ្នកបំពេញព្យាយាម ស្វែងរកឧបាយដើម្បីដោះចេញចាកសង្ខារ ដូចពណ៌នាមកដូច្នេះ ឈ្មោះថាបដិសង្ខាញាណ ។

៨- *សង្ខារុបេក្ខាញាណ* កាលកំណត់ពិចារណាសង្ខារ ទាំងអស់ថាជារបស់សូន្យចាកខ្លួន-ប្រាណ-សត្វ-បុគ្គល សូន្យចាកអាការជារបស់

ទៀង សុខ ខ្លួនប្រាណជារបស់ល្អ អាការទាំងអម្បាលនោះមានក្នុងសព្វសង្ខារ ដូចជាដុំនៃពពុះទឹកនិងព្រេញថ្ងៃដូច្នោះ ។ កាលបើអ្នកបំពេញព្យាយម បានកំណត់សង្ខារទាំងអស់ឲ្យឃើញថា សុទ្ធសឹងអនុវត្តន៍ដោយបដិសង្ខានុបស្សនាដូច្នេះហើយ ទើបកំណត់សង្ខារជារបស់សូន្យ មានពីរយ៉ាងគឺ យើងសូន្យចាកសព្វវត្ថុ១ សព្វវត្ថុសូន្យចាកយើង១ ។ រួចកំណត់ការសូន្យចាក៤យ៉ាងទៀតថា ខ្លួនមិនមានរបស់១ របស់មិនមានខ្លួន១ អ្នកដទៃមិនមានរបស់១ របស់អ្នកដទៃមិនមាន១ មានតែសង្ខារប៉ុណ្ណោះ ទូទៅទាំងអស់ហើយទើបកំណត់សង្ខារទាំងអស់ដោយលក្ខណៈ ទាំង៣ថែមទៀត ចិត្តរបស់អ្នកបំពេញព្យាយាមនោះក៏អស់តក់ស្លុត អស់ខ្លាច អស់ភ័យ អស់ស្អប់អស់ស្រឡាញ់ ជាចិត្តប្រងើយៗ ក្នុងសង្ខារទាំងអម្បាលនោះ មិនប្រកាន់ថាយើង របស់យើងទៀតឡើយ ដូចជាបុគ្គលមានភរិយាលែងលះគ្នាហើយ លុះទៅជួបគ្នាទៀត ក៏ព្រងើយកន្តើយដោយសំគាល់ថាមិនមែនជាភរិយារបស់ខ្លួនដូច្នេះ ។ បញ្ញារបស់អ្នកបំពេញព្យាយាមបានពិចារណាឃើញដូចពោលមកនេះ ហៅថា សង្ខារុបេក្ខាញាណ ។

បណ្តាញាណទាំង៣គឺ *សង្ខារុបេក្ខាញាណ១ មុញ្ចិតុកម្យតាញាណ១* និង *បដិសង្ខាញាណ១* ទាំង៣នេះបើពោលដោយអត្ថ គឺដូចគ្នា តែបើពោលទៅតាមព្យញ្ជនៈវិញឃើញថាផ្សេងគ្នា ។ ឯសង្ខារុបេក្ខាញាណនេះជាកំពូលនៃ វិបស្សនាញាណទាំងអស់ ។

៩-*អនុលោមញ្ញាណ* អ្នកបំពេញព្យាយាម កាលបើចំរើនសង្ខារុបេក្ខាញាណ លុះត្រាតែកើតសទ្ធា- វិរិយ- សតិ- សមាធិ និងសង្ខារុបេក្ខាញាណចាស់ក្លាហើយ គួរនឹងពោលបានថា អរិយមគ្គ

កើតឡើងក្នុងកាលឥឡូវនេះ ខណៈនោះសង្ខារុបេក្ខាញាណកើតឡើងហើយ ក៏ពិចារណាសង្ខារទាំង៣ ដោយលក្ខណៈទាំង៣ឯណានិមួយជាអារម្មណ៍ ទើបយាងចុះកាន់ភវង្គ ក្នុងលំដាប់នៃភវង្គនោះ មនោទ្វារាវជ្ជនៈកើតឡើង ធ្វើលក្ខណៈទាំង៣ឯណានិមួយឲ្យជាអារម្មណ៍ ហើយធ្លាក់ចុះកាន់ភវង្គ ។ ក្នុងលំដាប់នៃភវង្គនោះ ជវនចិត្តទី១ ធ្វើលក្ខណៈទាំង៣ឯណានិមួយ ឲ្យជាអារម្មណ៍យ៉ាងនោះកើតឡើងហើយ បានឈ្មោះថាបរិកម្ម ។ ក្នុងលំដាប់នៃបរិកម្មនោះ ជវនចិត្តទី២ ធ្វើលក្ខណៈទាំង៣ឯណានិមួយឲ្យជាអារម្មណ៍កើតឡើងហើយ ទើបបានឈ្មោះថាឧបចារៈ ។ ក្នុងលំដាប់នៃឧបចារៈនោះ ជវនចិត្តទី៣ ធ្វើលក្ខណៈទាំង៣ឯណានិមួយឲ្យកើតឡើងហើយ ទើបឈ្មោះថា អនុលោម ។ ក៏អនុលោមនោះ គឺជាអនុលោមញ្ញាណនោះឯង ព្រោះញាណនេះ អនុលោមទៅតាមវិបស្សនាទាំង៨ខាងដើម ដោយកិច្ចត្រូវធ្វើយ៉ាងនេះដូចគ្នា អនុលោមទៅតាមពោធិបក្ខិយធម៌ទាំង៣៧ខាងលើ ដោយផ្លូវប្រតិបត្តិនោះ ព្រោះហេតុនោះ អនុលោមញ្ញាណនេះ ទើបលោកពោលថាជាអនុលោមិកញ្ញាណ ។

ក៏វិបស្សនាញាណទាំង៩ មានឧទយព្វយញ្ញាណជាដើម មានសច្ចានុលោមញ្ញាណជាទីបំផុត ឈ្មោះថា បដិបទាញាណទស្សនវិសុទ្ធិ ជាតួវិបស្សនាទី៤ ។ ក្នុងលំដាប់នៃអនុលោមញ្ញាណនោះ គោត្រភូចិត្ត ទាញយកព្រះនិព្វាននោះមកជាអារម្មណ៍ កន្លងបថុជ្ជនគោត្រ យាងចុះកាន់អរិយគោត្រ ។ គោត្រភូញាណ មិនបានរាប់បញ្ចូលក្នុងបដិបទាញាណទស្សនវិសុទ្ធិឡើយ គឺរាប់បញ្ចូលទៅក្នុងពួក ញាណ-

ទស្សនវិសុទ្ធិ ព្រោះតាំងនៅក្នុងទីជាអារជ្ជនៈ របស់មគ្គញាណ តាំងនៅក្នុងចន្លោះកណ្ដាលគួររាប់ថាជាវិបស្សនាបាន ព្រោះធ្លាក់ចុះទៅនៅក្នុងក្រសែរបស់ វិបស្សនា ។

រីឯវិបស្សនាញាណ ដែលពិចារណានូវសង្ខារដោយលក្ខណៈ ទាំង៣ ចាប់តាំងពីដើមរហូតដល់គោត្រភូញាណ ជាចំណែកភាវនាមយៈនៃកាមាវចរកុសល ។ ឯចំណែកលោកុត្តរកុសល គឺមគ្គចិត្តកើតឡើងក្នុងលំដាប់នៃគោត្រភូនោះឯង ។ មគ្គចិត្តនេះ កាលដែលនឹងកើតឡើងនោះកាន់យកព្រះនិព្វានជាអារម្មណ៍ កំណត់ដឹងទុក្ខ លះសមុទ័យ ធ្វើនិរោធឲ្យជាក់ច្បាស់ ចំរើនមគ្គឲ្យកើតឡើង ហើយធ្វើកិច្ចសច្ចៈទាំង៤ឲ្យកើតឡើង ផ្ដាច់បង់កងកិលេស គឺ លោភៈ ទោសៈ មោហៈ និងសំយោជនៈទាំង៣គឺ **សក្កាយទិដ្ឋិ១ វិចិកិច្ឆា១ សីលព្វតបរាមាសៈ១** ដាច់សូន្យជាសមុច្ឆេទប្បហាន តាមកម្លាំងរបស់ខ្លួន កើតឡើង១ខណៈ ចិត្តក៏រលត់ទៅ ផលចិត្តក៏កើតឡើងតោងយកព្រះនិព្វានជាអារម្មណ៍ ក្នុងលំដាប់នៃមគ្គចិត្តនោះ ។ រីឯផលចិត្តនោះកើតឡើង២ខណៈខ្លះ ៣ខណៈខ្លះ ហើយធ្លាក់ចុះកាន់ភវង្គក្នុងមគ្គជវនវិថី កំណត់ជវនស្ទុះទៅបានតែ៧ខណៈចិត្តប៉ុណ្ណោះ ។ អ្នកបំពេញព្យាយាម គប្បីឲ្យដឹងដូច្នេះគឺ បើកុលបុត្តដែលមានប្រាជ្ញាជា **ទន្ធាភិញ្ញា** ត្រាស់ដឹងយូរ ជវនជាដំបូងឈ្មោះថា **បរិកម្មជវន** ទី២ឈ្មោះថា **ឧបចារជវន** ទី៣ឈ្មោះថា **អនុលោមជវន** ទី៤ឈ្មោះថា **គោត្រភូជវន** ទី៥ឈ្មោះថា **មគ្គជវន** ជាតួមគ្គ ជវនទី៦និងទី៧ ជាតួផល ។ បើកុលបុត្តមានបញ្ញាជា **ខិប្បាភិញ្ញា** ត្រាស់ដឹងឆាប់ ជវនទី១ ឈ្មោះថា **ឧបចារជវន**

ទី២ឈ្មោះថា **អនុលោមជវន** ទី៣ឈ្មោះថា **គោត្រភូជវន** ទី៤ឈ្មោះថា **មគ្គជវន** ជាតួមគ្គ, ទី៥ ទី៦ និងទី៧ ទាំង៣នេះជាតួ**ផល** ។ អាស្រ័យហេតុនេះទើបលោកពោលថា **ផលចិត្ត** កើតក្នុងលំដាប់នៃ**មគ្គចិត្ត** ២ខណៈខ្លះ ៣ខណៈខ្លះ ហើយធ្លាក់ចុះទៅកាន់ភវង្គ ដូច្នេះ ។

ខាងមុខអំពីភវង្គចិត្តនេះទៅ មានមនោទ្វារាវជ្ជនចិត្ត កាត់ខ្សែភវង្គកើតឡើងក្នុងមនោទ្វារាវជ្ជនចិត្តនោះ បច្ចវេក្ខណញាណកើតឡើងពិចារណាមគ្គ-ផល និងកិលេសដែលកើតហើយៗលះចេញ និងកិលេសដែលសល់នៅព្រមទាំងនិព្វាន ។ បច្ចវេក្ខណញាណទាំង៥ប្រការនេះរមែងមានដល់សោតាបន្នអរិយសាវក ដោយប្រការដូច្នេះ ។ សូម្បីព្រះសកទាគាមិ និងព្រះអនាគាមិ ក៏មានបច្ចវេក្ខណកិច្ច៥ប្រការដូចគ្នានឹងព្រះសោតាបន្នដែរ ។ ចំណែកព្រះអរហន្ត មិនមានបច្ចវេក្ខណៈឡើយ ព្រោះលោកលះកិលេសចេញអស់ហើយ មិនមានសេសសល់បន្តិចបន្តួចក្នុងខន្ធសន្តានរបស់លោកឡើយ ។ ព្រះសោតារមែងធ្វើសង្សារទុក្ខឲ្យអស់ទៅ បិទទ្វារអបាយភូមិទាំង៤បាន ធ្វើនូវភារៈជាអ្នកមានមុខចំពោះអរិយទ្រព្យទាំង៧ប្រការ និងលះមិច្ឆាមគ្គទាំង៨ ធ្វើភ័យនិងពៀរទាំងអស់ឲ្យស្ងប់ស្ងាត់បានដោយល្អ ចូលដល់នូវភាពជាឱរស នៃព្រះសម្មាសម្ពុទ្ធ ។ ញាណសម្បយុត្តអរិយមគ្គទាំង៤ មានសោតាបត្តិមគ្គជាដើម ឈ្មោះថា**ញាណទស្សនវិសុទ្ធិ** ជាតួវិបស្សនាទី៥ ជាកំពូលនៃវិបស្សនា ។ ក៏វិបស្សនាញាណនេះ មានផលធំជាងទាន, សីល, ព្រហ្មវិហារ, ភាវនា, រមែងធ្វើអ្នកដែលចំរើននោះឲ្យមានសតិខ្ជាប់ខ្ជួនមិនវង្វេងលុះពេលធ្វើកាលកិរិយាទៅ រមែងមានសុគតិភព គឺមនុស្សនិងសួគ៌ជាខាងមុខ ។

ម្យ៉ាងទៀតក៏ជាឧបនិស្ស័យ មគ្គ ផល ព្រះនិព្វាន ជាប់ក្នុងសន្តាន តទៅក្នុងខាងមុខផង ។ នេះពោលដោយមិនទាន់បានសម្រេចមគ្គ ផល ព្រះនិព្វាន បើជាឧបនិស្ស័យមគ្គ ផល ព្រះនិព្វាន ក៏ធ្វើអ្នកនោះឯង ឲ្យសម្រេចមគ្គ ផល ព្រះនិព្វាន ក្នុងជាតិនេះឯងពិតប្រាកដ ។

ធម៌ទាំងអស់ដែលមានមកក្នុងផ្ទៃនៃវិបស្សនាកម្មដ្ឋាននេះ មានបញ្ហា ៤យ៉ាង ដែលជាបញ្ហាយ៉ាងធ្ងន់បំផុត រកអ្នកឯណានិមួយនឹង ដោះស្រាយពុំរួចឡើយ មានតែព្រះសម្ពុទ្ធ និងព្រះអរហន្តថ្លៃ ទើបអាចនឹងដោះស្រាយនូវបញ្ហាទាំង៤យ៉ាងនោះរួចបាន ។ រីឯបញ្ហាទាំង៤យ៉ាង នោះគឺ៖ ១- **ជាតិទុក្ខ** ទុក្ខព្រោះកើត, ២- **ជរាទុក្ខ** ទុក្ខព្រោះចាស់, ៣- **ព្យាធិទុក្ខ** ទុក្ខព្រោះឈឺ, ៤- **មរណទុក្ខ** ទុក្ខព្រោះស្លាប់ ។ ទីនេះនឹង យកបញ្ហាទាំង៤យ៉ាងនេះ ទុកធ្វើជាបទមាតិកាខាងដើម ហើយនឹង សម្តែងវែកញែកដោះស្រាយ ឲ្យឃើញជាក់ច្បាស់នូវទុក្ខទោសរបស់ ខន្ធ៥ ដូចមានសេចក្តីអធិប្បាយតទៅខាងមុខនេះ ៖

ខ្ញុំតាំងបុគ្គលាធិដ្ឋាននូវ សញ្ញា១ វិញ្ញាណ១ និង បញ្ញា១ ទាំង៣ នេះធ្វើជាខបុច្ឆា- វិសជ្ជនា នូវកងទុក្ខទាំង៤ខនេះ ដូចមានសេចក្តីតទៅ:

វិញ្ញាណសួរបញ្ញាថា, ដែលហៅថាទុក្ខៗនោះតើដូចម្តេច?

បញ្ញាឆ្លើយថា, របស់អ្វីៗដែលជាទីគួរខ្ពើមរអើម, ជាទីស្អប់, ពុំជាទីគួរស្រឡាញ់, ជាទីគួរភ័យ, គួរខ្លាច, រំភើបញាប់ញ័រដល់ចិត្ត របស់ទាំងអស់នេះហើយ ដែលឈ្មោះថាទុក្ខ ។

សួរថា, ចុះទុក្ខនោះជារបស់តាំងនៅដូចម្តេច?

ឆ្លើយថា, ទុកនោះជារបស់ទំនេរទទេៗ ជារបស់នៅក្រៅខ្លួនយើង, ក្រៅសត្វ, ក្រៅជីវិត, ក្រៅប្រុស-ស្រីទាំងអស់ ។

សួរថា, ចុះទុក្ខនោះមានតែនៅក្នុងចិត្តឬ?

ឆ្លើយថា, មិនមែនដូច្នោះទេ ទុក្ខនេះជារបស់នៅក្រៅចិត្តទេតើ បានជាថាទុក្ខនៅក្រៅចិត្តនោះ ព្រោះចិត្តជាអ្នកនឹកគិតសន្សំយកនូវអារម្មណ៍ទាំង៦ អំពីខាងក្រៅ មានរូបារម្មណ៍ជាដើម មានធម្មារម្មណ៍ជាទីបំផុត ។ អារម្មណ៍ទាំង៦នេះ ជាអារម្មណ៍នៅក្រៅចិត្តទាំងអស់ ។ បើអារម្មណ៍នៅក្រៅចិត្តហើយ ទុក្ខទាំងអស់ក៏នៅក្រៅចិត្តដូចគ្នានឹងអារម្មណ៍ដែរ ។ អារម្មណ៍ទាំង៦នោះគឺ **១- *រូបារម្មណ៍*** អារម្មណ៍គឺរូប ព្រោះរូបជារបស់នៅក្រៅចិត្តពិត តែថាបើភ្នែកក្រឡេកឃើញរូបហើយ ចិត្តក៏ស្ទុះទៅចាប់យកនូវរូបនោះមកជាអារម្មណ៍ ហើយក៏កើតឡើងនូវកងទុក្ខ គឺសោមនស្សទុក្ខ ឬ ទោមនស្សទុក្ខ បរិទេវទុក្ខ ឬ អប្បិយេ-ហិសម្បយោគទុក្ខ ណាមួយកើតឡើងចំពោះចិត្តដែលស្ទុះទៅចាប់យកនូវអារម្មណ៍ គឺរូបនោះមកទុកក្នុងចិត្ត ម្លោះហើយចិត្តនោះ ក៏ទៅជាក្តៅរោលរាលទៅដោយអំណាចភ្លើងទុក្ខ និងភ្លើងកិលេស ព្រោះតែចិត្តចាប់យកនូវរូបារម្មណ៍អំពីខាងក្រៅចូលមកទុកក្នុងចិត្ត ។ **២-*សទ្ទារម្មណ៍*** អារម្មណ៍គឺសម្លេង ។ សម្លេងនេះជារបស់នៅក្រៅត្រចៀក តែបើសម្លេងនោះមកប៉ះពាល់ត្រូវត្រចៀកហើយ ចិត្តក៏ស្ទុះទៅចាប់យកសម្លេងនោះនាំមកទុកក្នុងចិត្ត ហើយចិត្តនោះក៏កើតសោមនស្សទុក្ខ ឬ ទោមនស្ស-ទុក្ខ ភ្លើងទុក្ខ និងភ្លើងកិលេសក៏កើតឡើងព្រោះតែចិត្តចាប់យកនូវសទ្ទារម្មណ៍អំពីខាងក្រៅ នាំចូលមកទុកក្នុងចិត្ត ហើយក៏កើតសេចក្តីក្តៅក្រហាយ រោលរាលទៅតាមសភាពរបស់សម្លេងនោះៗទៅ ។ល។ **៦-*ធម្មារម្មណ៍*** អារម្មណ៍គឺធម៌ដែលកើតនៅក្នុងចិត្ត គឺចិត្តនឹកគិតសន្សំចាប់យកនូវអារម្មណ៍ពីក្រៅ ដូចយ៉ាងឧទ្ធច្ចៈចិត្ត ចិត្តដែលអណ្តែត

អណ្តូងរាយមាយ ទៅចាប់យកអារម្មណ៍ឆ្ងាយៗ នាំមកទុកក្នុងចិត្ត ហើយក៏ឆេះឡើងជាភ្លើងទុក្ខ និងភ្លើងកិលេស គឺសោមនស្សទុក្ខ និងទោមនស្សទុក្ខ ។ ទុក្ខទាំងអស់នេះសុទ្ធតែនៅក្រៅចិត្តទាំងអស់ សេចក្តីនេះឧបមាដូចម្តេចមិញ ឧបមេយ្យដូចជាគោនិងដំណាំស្រូវ ចិត្តដូចជាគោ ភ្លើងទុក្ខនិងភ្លើងកិលេស ដូចជាដំណាំមានស្រូវជាដើមនៅទីទៃពីគ្នាដូច្នេះ ។ ឯស្រូវនិងដំណាំមិនដែលដើរទៅស៊ីគោ ដល់ម្តងសោះ មានតែគោនេះឯងដែលដើរទៅស៊ីស្រូវនិងដំណាំជាធម្មតា ។ បើគោណាមានខ្សែចង គោនោះក៏មិនអាចនឹងទៅស៊ីស្រូវនិងដំណាំនោះបានឡើយ ព្រោះគោនោះជាប់នឹងខ្សែចំណង ។ បើគោណាគ្មានខ្សែចំណងចងទេ គោនោះមុខជាទៅស៊ីស្រូវនិងដំណាំនោះញយៗ យ៉ាងណាមិញ ឯចិត្តទុកដូចជាគោ ភ្លើងទុក្ខនិងភ្លើងកិលេសឧបមាដូចជាស្រូវនិងដំណាំយ៉ាងនោះដែរ ។

ហេតុនេះហើយបានជាព្រះបរមគ្រូ ទ្រង់ទូន្មានភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាចូរខំសង្រួមឥន្ទ្រីយ៍ទាំង៦ បិទផ្លូវបាបទាំងឡាយ គឺអភិជ្ឈានិងទោមនស្ស កុំឲ្យកើតឡើងបាន ។ ឥន្ទ្រីយ៍ទាំង៦នោះគឺ៖ ១- **ចក្ខុន្ទ្រិយសំវរសីល** គឺការសង្រួមភ្នែក បិទបាំងហាមឃាត់មិនឲ្យចិត្តស្ទុះចេញទៅតាមខ្សែរូបារម្មណ៍ ដែលភ្នែកក្រឡេកឃើញរូបនោះៗ ។ រូបារម្មណ៍នេះ ជាខ្សែឬជាផ្លូវរបស់ចិត្តសម្រាប់ចេញចូល ដឹកនាំយកនូវភ្លើងទុក្ខ និងភ្លើងកិលេសពីខាងក្រៅ នាំចូលទៅទុកក្នុងចិត្ត ហើយដុតបំពក់ចិត្តឲ្យក្តៅរោលរាល ដោយកម្លាំងអភិជ្ឈានិងទោមនស្ស ។ បើចិត្តមិនទទួលយកនូវអភិជ្ឈា និងទោមនស្សទេ ឈ្មោះថាសង្រួមបានហើយ សីលរបស់ភិក្ខុនោះក៏បានបរិសុទ្ធល្អ ដោយសេចក្តី

ព្យាយាមសង្រួម ។ បើមិនសង្រួមទេ ចិត្តនោះក៏ចាប់យកអភិជ្ឈា និងទោមនស្ស នាំចូលមកទុកក្នុងចិត្ត ម្លោះហើយសីលរបស់ភិក្ខុនោះ មិនបានបរិសុទ្ធទេ ។ល។ **៦-មនិន្ទ្រិយសំវរសីល** សីលដែលត្រូវសង្រួមចិត្ត ។ ចិត្តដែលបានសង្រួម និងមិនបានសង្រួមនោះ ត្រូវដឹងបានដូចម្ដេច? ចិត្តដែលបានសង្រួមនោះ គឺចិត្តដែលមិនលុះទៅតាមអារម្មណ៍ក្នុងមនោទ្វារ ដែលជាទ្វាររបស់ចិត្ត សម្រាប់ចេញចូលដឹកជញ្ជូន នាំយកនូវអារម្មណ៍របស់កាមគុណទាំង៥ អំពីទីឆ្ងាយៗមកទំពាស៊ី ព្រោះយល់ឃើញថា កាមគុណនេះឆ្ងាញ់ណាស់ ស្រួលណាស់ សុខណាស់ ប្រសើរណាស់ ម្លោះហើយចិត្តនោះក៏ក្រេបជញ្ជក់ យកជាតិកាមទាំង៣ គឺ ៖ **១-កាមវិតក្កៈ** ត្រិះរិះតែក្នុងកាមគុណទាំង៥ ហើយញៀនញ៉ាមជាប់ចិត្ត លង់លិចនៅដេកត្រាំក្នុងអារម្មណ៍របស់កាមគុណ ឬនៅដេកត្រាំក្នុងអន្លង់ឱឃៈទាំង៤ ដែលជាអន្លង់ជ្រៅសម្រាប់លង់ចិត្តរបស់សត្វ ដែលប្រកបដោយមោហៈ លង់លិចក្នុងភពតូចនិងភពធំ។ **២- ព្យាបាទវិតក្កៈ** ត្រិះរិះរករឿងរកហេតុប្រទូសរ៉ាយដល់សត្វនិងសង្ខារ ត្រិះរិះគំនុំគំគួនចងពៀរវេរា រករឿងរកហេតុឲ្យគេវិនាសទ្រព្យសម្បត្តិ និងវិនាសជីវិត ។ **៣-វិហិង្សាវិតក្កៈ** ត្រិះរិះបៀតបៀនដល់សត្វនិងសង្ខារ មានការត្រិះរិះសម្លាប់សត្វ និងត្រិះរិះចង់បានទ្រព្យអ្នកដទៃ យកមកធ្វើជាទ្រព្យរបស់ខ្លួន ។ ម៉្យាងទៀតដូចជាឧទ្ធច្ចចិត្ត ចិត្តដែលអណ្ដែតអណ្ដូងរាយមាយទៅយកអារម្មណ៍ពីទីឆ្ងាយៗចូលមកទុកនៅក្នុងចិត្ត, ចិត្តដូចបានអធិប្បាយមកនេះជាចិត្តប្រព្រឹត្តទៅតាមមនោទ្វារតែម៉្យាង ។ សម្ដែងមកនេះឲ្យឃើញថា ភ្លើងទុក្ខនិងភ្លើងកិលេស ជារបស់នៅក្រៅចិត្តពិតដូចជាគោនិងស្រូវដំណាំផ្សេងៗ ចំណែកស្រូវនិងដំណាំមិនដែលដើរ

ទៅស៊ីគោមួងសោះ មានតែគោដើរទៅស៊ីស្រូវនិងដំណាំ ។ ព្រោះហេតុហ្នឹងហើយ បានជាព្រះអង្គទ្រង់ប្រៀនប្រដៅថា ម្នាលភិក្ខុទាំងឡាយ អ្នកត្រូវសង្រួមចិត្ត ពត់ចិត្តឲ្យបាននឹងនួនល្អ កុំឲ្យចិត្តទៅយកភ្លើងទុក្ខនិងភ្លើងកិលេស មកដុតបំពក់ចិត្តទៀត ។ ពួកព្រះអរហន្តទាំងឡាយគ្រប់ៗព្រះអង្គ លោកខំព្យាយាមសង្រួមចិត្តចូលកាន់សមាធិ, ជាចិត្តរួចផុតស្រឡះចាកអំពីភ្លើងទុក្ខ និងភ្លើងកិលេសគ្រប់ៗព្រះអង្គ ។ ចិត្តដែលស្រូបយកភ្លើងទាំង២ភ្នក់នេះ ឧបមាដូចជាសត្វមមាច ក្រឡេកឃើញភ្លើង ក៏ស្មានថាភ្លើងនេះជារបស់ឆ្ងាញ់ ម្លោះហើយក៏នាំគ្នាហើរត្រសុកត្បុលចូលទៅក្នុងភ្លើង ឥតមានខ្លាចឡើយ សត្វមមាចស្លាប់ខ្លួន ដោយសារតែសេចក្ដីយល់ខុស,សំគាល់ខុស,ដឹងខុស ហើយពួកសត្វនេះមិនដឹងជាខុសផង ។ នែសញ្ញា- វិញ្ញាណ! អ្នកឯងនេះល្ងង់ដូចជាសត្វមមាច, សត្វមមាចហើរចូលតែភ្នក់ភ្លើង១ អ្នកឯងហើរចូលភ្នក់ភ្លើងដល់ទៅ៣ភ្នក់ ភ្លើងគឺរាគៈ១ ភ្លើងគឺទោសៈ១ ភ្លើងគឺមោហៈ១ ឃើញថាអ្នកឯងនេះល្ងង់ជាងសត្វមមាច២ភាគ ។

បញ្ញាសួរទៅវិញថា, សត្វមមាចហើយនឹងភ្លើង វានៅជាមួយគ្នា ឬក៏វានៅទីទៃអំពីគ្នា?

វិញ្ញាណឆ្លើយថា, វានៅទីទៃពីគ្នាទេ តែថាសត្វមមាចនោះក្រឡេកឃើញភ្លើងហើយស្រឡាញ់ បានជាចេះតែហើរចូលទៅក្នុងភ្លើង ។

បញ្ញាសួរទៀតថា, ចុះដូចសញ្ញា-វិញ្ញាណឯងនេះ នៅទីទៃអំពីភ្លើងរាគៈ ទោសៈ មោហៈឬក៏នៅជាមួយគ្នា?

សេចក្ដីនេះសូមឲ្យលោកបញ្ញាសម្ដែងប្រាប់ ខ្ញុំទាំងពីរនាក់នឹងចាំស្ដាប់ ។

អើបើដូច្នេះ អ្នកឯងទាំង២ចាំស្ដាប់ចុះ ។ **វិញ្ញាណាបីតិ៧** និង ***សត្តាវាសៈ៩*** ដូចជាភ្លើង ។ វិញ្ញាណដែលស្ថិតនៅក្នុងភ្នែក ក្នុងត្រចៀក ក្នុងច្រមុះ ក្នុងអណ្ដាត ក្នុងកាយ ក្នុងចិត្ត ទាំងអស់នេះជាកន្លែងរបស់អ្នកឯង ។ ឯរូប សម្លេង ខ្លិន រស សម្ផស្ស និងធម្មារម្មណ៍ របស់ទាំង៦នេះ ជារបស់នៅឆ្ងាយអំពីអ្នកឯងណាស់ទេតើ ហេតុដូចម្ដេចបានជាអ្នកឯងទៅដេកនៅក្នុងភ្នក់ភ្លើង ទាំង៣ភ្នក់ ទាំងយប់ទាំងថ្ងៃយ៉ាងនេះ មកតែអំពីអ្នកឯងនេះល្ងង់ខ្លាំងជាងសត្វមមាចទៅទៀត បានជាពុំដឹងភ្លើងទុក្ខ និងភ្លើងកិលេស ទាំងមិនដឹងថាខ្លួនឯងនេះជាអ្នកល្ងង់ ថែមទៀតផង ។ នៃសញ្ញា- វិញ្ញាណ អ្នកឯងល្ងង់ខ្លាំងជ្រៅ វង្វេងធំ យ៉ាងនេះហើយ សេចក្ដីសុខមិនមានដល់អ្នកឡើយ មានតែសេចក្ដីទុក្ខនិងទោសជាអាហាររបស់អ្នកប៉ុណ្ណោះ សព្វថ្ងៃខ្លួនអ្នកឯងដូចជាសត្វដង្កូវក្នុងបង្គន់ ស៊ីសុទ្ធតែលាមកហើយមិនដឹងថាលាមកផង ដេកក្នុងបង្គន់ហើយមិនដឹងទាំងបង្គន់នោះដូចម្ដេចផង សេចក្ដីនេះមានឧបមាថា, ដូចជាវិញ្ញាណឯងដែលនៅអាស្រ័យក្នុងកាយនេះ មិនដឹងថាកាយនេះប្រកបទៅដោយសាកសពដូច្នេះទេ គឺដឹងថាសុទ្ធតែល្អៗ ប្រសើរទៅវិញ ។ រូបនេះជាគ្រឿងមិនស្អាតស្មោកគ្រោកជាទីបំផុត ហូរទឹកអសុភទៅតាមទ្វារទាំង៩ តែរាល់ៗថ្ងៃ កាលបើអសុភហូរចេញមកខាងក្រៅ វិញ្ញាណឯងដឹងថាស្អុយណាស់ ត្រង់វិញ្ញាណឯងដេកនៅជាមួយគ្នានឹងអសុភនោះ វិញ្ញាណឯងថាស្រួលណាស់ សប្បាយណាស់ វិញ្ញាណដូចកលមាយាយ៉ាងនេះឯង ។

សួរថា, ចុះទុក្ខក្នុងខន្ធទាំង៥នេះមានប៉ុន្មានយ៉ាង?

ឆ្លើយថា, ទុក្ខក្នុងខន្ធទាំង៥នេះមាន២យ៉ាងគឺ ទុក្ខក្នុងរូបម្យ៉ាង ទុក្ខក្នុងនាមម្យ៉ាង ។ រូបនេះបាននឹងរូប២៨ តែពុំបានអធិប្បាយពីរូបនោះទេ អធិប្បាយតែអំពីទុក្ខរបស់រូបប៉ុណ្ណោះ ។ ។

ឯទុក្ខរបស់រូបនោះមាន៤យ៉ាងគឺ **១- ជាតិទុក្ខ** ទុក្ខព្រោះការកើត, **២- ជរាទុក្ខ** ទុក្ខព្រោះជរាគឺចាស់, **៣- ព្យាធិទុក្ខ** ទុក្ខព្រោះព្យាធិគឺការឈឺចុកចាប់, **៤- មរណទុក្ខ** ទុក្ខព្រោះមរណៈគឺការស្លាប់ ។ បណ្តាទុក្ខទាំង៤កងនេះ លើកទុក៣កងខាងចុងសិន នឹងសម្តែងជាតិទុក្ខជាមុន ។

**១- ជាតិទុក្ខ** នោះបើតាមការពិតនោះ ព្រះសម្មាសម្ពុទ្ធ ជាចមភពនៃសត្វក្នុងត្រៃលោក ទ្រង់ជ្រាបស្គាល់ច្បាស់ដោយព្រះបញ្ញាញាណដ៏ល្អិតជ្រាលជ្រៅ ក្នុងរយៈផ្លូវនៃបដិសន្ធិវិញ្ញាណរបស់សត្វ ដែលចុះចាកគភ៌នៃមាតានោះថា ៖

**បឋមំ កលលំ ហោតិ កលលា ហោតិ អព្វុទំ អព្វុទា ជាយតេ បេសិ បេសិយា ជាយតេ ឃនោ ឃនាបិ សាខា ជាយន្តិ កេសា លោមា នខាបិច ។**

ប្រែថា, មុនដំបូងកើតជារូប «**កលលៈ**» ជាសរីរៈល្អិត ឆ្មារក្រៃលែងឆ្មារ ស្ថិតនៅក្នុងផ្ទៃមាតា ដូចដំណក់ប្រេងល្ងថ្លា ឬក៏ដូចជាសប្បិទន់ថ្លា តាំងនៅអស់រយៈ៧ថ្ងៃ ទើបប្រែទៅជារូប «**អព្វុទៈ**» មានអាការៈដូចជាទឹកគេលាងសាច់ ក្រហមព្រឿងៗ តាំងនៅបាន៧ថ្ងៃ ក៏ក្លាយទៅជារូប «**បេសិ**» មានសណ្ឋានដូចជាបន្ទះចម្រៀកតូចមួយ ដូចជាសំណដែលគេរំលាយនឹងអំបែង តាំងនៅបានរវាង៧ថ្ងៃ ទើបប្រែទៅជារូប «**ឃនៈ**» មានអាការៈមូលខន់ខាប់ ដូចជាស៊ុតមាន់ខាងក្នុង

តាំងនៅបាន៧ថ្ងៃ តមកខាងក្រោយទៀត រូបនោះក៏ចំរើនឡើង បែកចេញជាពក៥ តាំងឡើងកើតជាអវយវៈមានដៃជាដើម ដែលកើតអំពីកម្មប្បច្ច័យរបស់សត្វ តាំងនៅអស់៧ថ្ងៃ ទើបដុះសក់ រោម ក្រចកឡើងជាលំដាប់ដែលហៅថាបែក **បញ្ចសាខា** ។

ចាប់តាំងពីថ្ងៃនោះតទៅ មានតែជរានិងមរណៈចាំស្ទាក់កាត់ពីមុខ ព្រោះមានធម៌មិនទៀង ជាទុក្ខ ជាអនត្តា នៅក្នុងជាតិទុក្ខនោះ ។ ជាតិទុក្ខនេះ ឥតមាននិយាយពី វេទនា សញ្ញា វិញ្ញាណ ថាដឹងជាទុក្ខជាសុខនោះគ្មានសោះ ។ ជាតិទុក្ខនេះ ជាទុក្ខរបស់ដី-ទឹក-ភ្លើង-ខ្យល់ទេតើ! ដែលសង្ខារតាក់តែង អាស្រ័យឆ្អឹងខ្លះ សរសៃខ្លះ សាច់ខ្លះ ស្បែកខ្លះ ផ្សំផ្គុំរុំព័ទ្ធកសាងឲ្យកើតឡើងទៅជាខន្ធ៥នោះ មិនមែនជាទុក្ខរបស់វេទនា សញ្ញា វិញ្ញាណទេ ពិតជាទុក្ខរបស់រូប គឺ ដី-ទឹក-ភ្លើង-ខ្យល់ដូច្នេះ ។

២- **ជរាទុក្ខ** ទុក្ខព្រោះចាស់ទ្រុឌទ្រោមគ្រាំគ្រាទៅនៃខន្ធ ជាលក្ខណៈ មានការនាំចូលទៅកាន់សេចក្ដីស្លាប់ជាកិច្ច មានការវិនាសទៅនៃវ័យជាផល ចាត់ជារបស់នាំមកនូវសេចក្ដីទុក្ខ ។

សួរថា, ចុះកើតជាដំបូងនោះ តើកើតអ្វី? ចាស់គ្រាំគ្រានោះ ចាស់អ្វី? ចូរឆ្លើយរៀបរាប់មកមើល ។

ឆ្លើយថា, ដែលកើតជាដំបូងនោះ គឺទឹកថ្លា- ទឹកក្រហម- ទឹកស-ខាប់ៗរឹងៗ ក្លាយទៅជាដី ត្រង់ណារឹងៗហៅថាធាតុដី ត្រង់ណាទន់ៗជ្រាយៗហៅថាធាតុទឹក ដែលមានលក្ខណៈសម្រាប់ចំអិននូវកាយមានអាការៈក្ដៅៗចាត់ទុកជាធាតុភ្លើង ដែលមានលក្ខណៈសម្រាប់បក់ផាត់នូវកាយ មានអាការៈល្ហើយៗ ចាត់ទុកថាជាធាតុខ្យល់ ។ ដែល

ពោលថា ចាស់គ្រាំគ្រាទ្រុឌទ្រោមទៅនោះ គឺចាស់ធាតុទាំង៤នោះឯង ទេតើ ។ ឯធាតុទាំង៤នោះ បើចែកចេញទៅតាមឈ្មោះមាន៤២ គឺធាតុដីមាន២០ ធាតុទឹកមាន១២ ធាតុភ្លើងមាន៤ ធាតុខ្យល់មាន៦ រួមជា៤២ ។ ប៉ុន្តែពុំបានសម្ដែងអំពីធាតុទាំង៤នោះ ឲ្យបានសព្វគ្រប់ទេ គ្រាន់តែស្រង់យកធាតុទាំង៤នោះ ប្រារព្ធដើម្បីឲ្យបានដឹងថា ជរាទុក្ខនោះ តើចាស់របស់អ្វី ជាទុក្ខរបស់អ្វីប៉ុណ្ណោះ បើកើតសក់វាចាស់សក់ វាជរាសក់ ។ល។ បើកើតស្បែក វាចាស់ស្បែក វាទុក្ខស្បែក បើកើតសាច់ វា ចាស់សាច់ វាទុក្ខសាច់, អ្នកណាកើត អ្នកនោះនឹងចាស់ អ្នកណាចាស់ អ្នកនោះនឹងទុក្ខ ។

សួរថា, ចុះសក់ - រោម - ក្រចក - ធ្មេញ - ស្បែក ជាដើមនេះ គ្មានដឹងអ្វីសោះទេ ម្ដេចក៏ថាជាទុក្ខដែរ? ពួករូប២៨សុទ្ធតែមិនដឹងអ្វីទាំងអស់ទេ?

ឆ្លើយថា, ព្រោះមិនដឹងហ្នឹងហើយជាតួទុក្ខយ៉ាងធ្ងន់បំផុតក្នុងលោក បានជាហ៊ានពោលថាទុក្ខ ព្រោះប្រកបដោយមោហៈនិងអវិជ្ជា ការវង្វេងភាន់ច្រឡំ និងការដែលមិនដឹងច្បាស់ពិតប្រាកដ ការដែលមិនដឹងនេះហើយជាតួទុក្ខ បញ្ញាដែលជាអ្នកដឹងច្បាស់នេះជាតួសុខ ។ សេចក្ដីទុក្ខទាំងអស់នេះ មិនងាយសត្វណានឹងស្គាល់ច្បាស់បានទេ ស្គាល់បានតែលោកអ្នកត្រាស់ដឹង ចាក់ធ្លុះឃើញច្បាស់នូវព្រះអរិយសច្ចទាំង៤ ពិតប្រាកដ ។ ក៏ក្នុងអរិយសច្ចទាំង៤នោះ មានសម្ដែងដូច្នេះថា សេចក្ដីសុខសោមនស្សឯណាដែលកើតឡើងដោយសាររូប ហៅថាសេចក្ដីត្រេកអរជ្រះថ្លារបស់រូប ចាត់ជាសមុទយសច្ច ត្រាស់ដឹងបានដោយការលះបង់ ។ រូបដែលមិនទៀងជាទុក្ខ រមែងប្រែប្រួលទៅ លោកហៅថា

ទោសរបស់រូបកើតឡើងដោយសាររូប ចាត់ជាទុក្ខសច្ច ត្រាស់ដឹងបាន ដោយការកំណត់ ។

ការលះបង់នូវសេចក្ដីប្រាថ្នាក្នុងរូប ហៅថារលាស់ចោលនូវរូប ចាត់ជានិរោធសច្ច ត្រាស់ដឹងបានដោយកិរិយាធ្វើឲ្យជាក់ច្បាស់នូវ អដ្ឋង្គិកមគ្គទាំង៨ មានសម្មាទិដ្ឋិ សេចក្ដីយល់ត្រូវក្នុងហេតុទាំង៣យ៉ាង នេះជាដើម ហៅថាមគ្គសច្ច ត្រាស់ដឹងបានដោយកិរិយាចំរើន ។ ឯ វេទនា - សញ្ញា - សង្ខារ - វិញ្ញាណនេះ ក៏មានន័យដែលត្រូវចែកដូចគ្នា នឹងរូបខាងដើមដែរ ។ សេចក្ដីចាស់ទ្រុឌទ្រោមគ្រាំគ្រារបស់រូបទាំង២៨ នេះហើយ ដែលហៅថា ជរាទុក្ខ ។

**៣- ព្យាធិទុក្ខ** ទុក្ខព្រោះមានការឈឺចុកចាប់ ឈឺនោះតើឈឺ របស់អ្វី? ឈឺនោះគឺឈឺ សក់ - រោម - ក្រចក - ធ្មេញ - ស្បែក - សាច់ - សរសៃជាដើម ឈឺនេះក៏ព្រោះតែរូប២៨នេះដែរ ។ បើវេទនាទទួលយក ឈឺអំពីរូបនោះមកជាអារម្មណ៍ ក៏វាចម្លងជម្ងឺនោះចូលទៅដល់ចិត្តផង បើជាវេទនាមិនទទួលទេ ក៏វាឈឺតែរូបប៉ុណ្ណោះឯង ។

**៤- មរណទុក្ខ** ទុក្ខព្រោះមានការស្លាប់ តើអ្នកណាជាអ្នកទទួល ទុក្ខ បើរូបស្លាប់ទៅហើយ? រូបអ្នកណាស្លាប់ រូបអ្នកហ្នឹងហើយទទួលទុក្ខ ។ ទុក្ខក្នុងការស្លាប់នេះ ធ្ងន់ជាងក្នុងការឈឺទៅទៀត បានជាពោលថាធ្ងន់ ជាងឈឺនោះ ព្រោះការស្លាប់នេះ គឺស្លាប់ទៅទាំងអស់ មានធម៌មិនទៀន ជាទុក្ខ, ជាអនត្តា, តាមជាប់រហូតលុះត្រាតែអស់រូបនោះ ទើបបានអស់ ទុក្ខដែរ ។

ទុក្ខទាំង៤កងនេះ ជាទុក្ខកើតឡើងចំពោះរូប ទោះជារូបអ្វីៗ រូបមានវិញ្ញាណក្តី រូបឥតវិញ្ញាណក្តី ក៏លុះទៅក្នុងអំណាចលក្ខណៈទាំង៣ គឺ **អនិច្ចំ ទុក្ខំ អនត្តា** គឺ **ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ** ដូចគ្នាទាំងអស់ ។ រូបតែងវិនាសទៅដោយអំណាចភ្លើង ទាំង៤ភ្នក់នេះឯង ។ សម្តែងមកក្នុងទុក្ខរបស់រូបសង្ខេបតែប៉ុណ្ណេះ ។ តពីនេះទៅនឹងសម្តែងពីទុក្ខរបស់នាមតទៅ ៖

នាមធម៌មាន៤ប្រការគឺ **វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១** ទាំង៤ប្រការនេះហៅថានាមធម៌ ព្រោះជាធម៌មានតែឈ្មោះ ជាសភាវធម៌គ្មានរូបរាងកាយ រកកំណត់កត់សំគាល់ សណ្ឋានភេទមិនបាន ។ ព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់ទេសនាចាត់ឲ្យឈ្មោះថានាមធម៌ ដើម្បីជាប្រយោជន៍ដល់ព្រះយោគីអ្នកចំរើនវិបស្សនាបញ្ញា រាវរកឲ្យឃើញសភាវធម៌ដែលជារបស់ពិត ពិនិត្យដោយព្រះត្រ័យលក្ខណញ្ញាណប៉ុណ្ណោះឯង ។ ទុក្ខរបស់នាមនោះមាន៨កងគឺ៖ **សោកទុក្ខ១ បរិទេវទុក្ខ១ ទុក្ខទុក្ខ១ ទោមនស្សទុក្ខ១ ឧបាយាសទុក្ខ១ អប្បិយេហិសម្បយោគទុក្ខ១ បិយេហិវិប្បយោគទុក្ខ១ យម្បិច្ឆំ-នលភតិតម្បិទុក្ខ១ បញ្ចុបាទានក្ខន្ធាទុក្ខ១** ។ ទុក្ខទាំង៨ នេះជាទុក្ខរបស់នាម សម្រាប់ដុតបំផ្លាញពួកនាមទាំង៤ ។ ដោះស្រាយទុក្ខក្នុងខន្ធទាំង៥នេះ ឃើញថាចង្អៀតក្រៃពេកណាស់ ។ ខន្ធ៥នេះចែកទុក្ខទៅជា២ចំណែក ដូចបានអធិប្បាយមកហើយ ម្នាលសញ្ញានិងវិញ្ញាណ អ្នកស្តាប់បានហើយឬនៅ?

ខ្ញុំស្តាប់បានហើយ ពិតជាខ្ញុំនេះល្ងង់ជាងសត្វមមាចមែន ។

សញ្ញាសួរថា, ភ្នែក - ត្រចៀក - ច្រមុះ - អណ្ដាត - កាយ ទាំង៥នេះជារបស់អ្នកណា?

វិញ្ញាណឆ្លើយថា, របស់ទាំង៥នេះជារបស់ខ្ញុំពិត ។ អើបើអ្នកឯងយល់ឃើញយ៉ាងនេះហើយ ទុក្ខទាំង៨នេះត្រូវបានមកលើអ្នកទាំងអស់ ។ បញ្ញាថា, អ្នកយល់យ៉ាងនេះវិញទើបត្រូវ ភ្នែក- ត្រចៀក- ច្រមុះ- អណ្ដាត- កាយ, ទាំង៥នេះជារបស់ដី- ទឹក- ភ្លើង- ខ្យល់ មិនមែនជារបស់អ្នកទេ ។ កាលដែលភ្នែកវាកើត វាកើតរបស់វា ដល់ភ្នែកវាចាស់ ក៏វាចាស់របស់វា ដល់វាឈឺ ក៏វាឈឺរបស់វា ដល់វាស្លាប់ ក៏វាស្លាប់របស់វា ។ របស់ទាំងនេះ ជារបស់ ដី - ទឹក - ភ្លើង - ខ្យល់ ទាំងអស់ មិនមែនជារបស់អ្នកទេ បានជាថាមិនមែនជារបស់អ្នកនោះ ព្រោះកាយនេះវាចាស់តែរាល់ថ្ងៃ ហូរទៅកាន់សេចក្ដីទុក្ខមិនទៀង អនត្តាតែរាល់ថ្ងៃ អ្នកឃាត់ថាកុំឲ្យវាចាស់ កុំឲ្យឈឺ កុំឲ្យស្លាប់ ឃាត់យ៉ាងណាក៏វាមិនស្ដាប់ មិនតាមបង្គាប់អ្នកឯងដែរ ។ ត្រង់ឃាត់មិនបាន បង្គាប់មិនតាមនេះហើយ តើអ្នកសំគាល់ថាជារបស់អ្នកដូចម្ដេចកើត? សញ្ញា-វិញ្ញាណថា, ឃីអើហ្ន៎! យើងទាំងពីរនាក់នេះខុសហើយតើ ខុសនេះមិនមែនតិចតួចទេ ប្រហែលជា២ម៉ឺនអសង្ខ័យមកហើយ មិនដែលបានស្ដាប់ធម៌យ៉ាងនេះម្ដងសោះ ច្បាស់ណាស់ៗ ភ្លឺស្វាងដូចព្រះអាទិត្យទើបនឹងរះ ។ ខ្ញុំទាំង២នាក់សូមថ្វាយខ្លួនចំពោះបញ្ញា ។ សូមចាំទុកថា ខ្ញុំទាំង២នាក់លែងយល់ខុសដូចមុនៗនោះទៀតហើយ ។ ខ្ញុំកាលពីមុននោះជាអ្នកវង្វេងជ្រៅ លង់ខ្លាំងជាងសត្វមមាចពិត ។ ឥឡូវនេះ ខ្ញុំឃើញច្បាស់ណាស់ព្រះអង្គ សូមព្រះបញ្ញាទ្រង់ព្រះមេត្តាប្រោស សម្ដែងធម៌តទៅទៀត, ខ្ញុំនឹងស្ដាប់ឲ្យបានសព្វគ្រប់ព្រះអង្គ ។

អើ សញ្ញា-វិញ្ញាណ ប្រពៃណាស់ អ្នកចូរតាំងសតិស្តាប់ឲ្យបានច្បាស់ចុះណ៎ា! អវិជ្ជា និង សង្ខារដែលបង្កើតអ្នកឯងមកនេះ គឺឲ្យដឹងតែខុសៗ យល់តែខុសៗ មិនបានឲ្យយល់ទៅតាមសភាវធម៌ តាមមែនតាមពិត របស់ធម៌ដល់ម្តងសោះឡើយ ឥឡូវនេះអ្នកកើតបញ្ញាហើយតើ, បើដូច្នេះយើងនឹងសម្តែងអំពីទុក្ខទាំង៨កងនេះម្តងទៀតឲ្យអ្នកស្តាប់គឺ ៖

**១-សោកទុក្ខ** ទុក្ខព្រោះនឹកស្តាយស្រណោះអាឡោះអាល័យចំពោះសង្ខារដែលព្រាត់ប្រាសទៅ គឺ រូប១ សម្លេង១ ខ្លិន១ រស១ សម្ផស្ស១ យល់ឃើញថារបស់ទាំង៥នេះជារបស់ខ្លួន ហើយក៏ប្រកាន់ខ្ជាប់ ចង់ឲ្យតែនៅៗ ឲ្យតែទៀងៗ ដល់របស់នោះមិននៅ មិនទៀងក៏កើតសេចក្តីសោកស្តាយចំពោះវត្ថុដែលវិនាសនោះ ។ ត្រង់សេចក្តីថាចង់ឲ្យវត្ថុទាំង៥នោះនៅៗ ទៀងៗ ត្រង់នេះជាតួភ្លើងមោហៈផង លោភៈផង ។ ត្រង់ដែលវត្ថុនោះវិនាសទៅ ហើយសោកស្តាយ ត្រង់នេះជាភ្លើងលោភៈនិងមោហៈឆេះឡើងឲ្យកើតទុក្ខសោកស្តាយ ចំពោះរបស់ដែលបាត់បង់ទៅ ។ ភ្លើងទុក្ខនេះឆេះចំពោះតែពួកនាម ព្រោះសញ្ញា-វិញ្ញាណនេះល្ងង់ពេកណាស់ ហើរទៅចូលក្នុងគំនរភ្នក់ភ្លើង ហើយមិនដឹងថាជាភ្លើងថែមទៀតផង ។

**២-បរិទេវទុក្ខ** បានខាងការយំទួញរៀបរាប់ ពោលបូរបាច់ ប៉ប៉ាច់ប៉ប៉ោច ថ្លែងអំពីសេចក្តីកំសត់ផ្សេងៗ និងសង្ខារដែលព្រាត់ប្រាសបាត់ទៅ បណ្តាលឲ្យទៅជាត្អូញត្អែ រអាក់រអួល តឹងណែន ចុកឆ្អល់ក្នុងដើមទ្រូង បណ្តាលឲ្យហៀរហូរទឹកភ្នែកសស្រាក់ តឹងចិត្ត ធ្ងន់ចិត្ត ។ ភ្លើងទុក្ខនេះកើតមកពីមោហៈ ។

**៣-ទុក្ខទុក្ខ** ទុក្ខលំបាកទាំងរូបទាំងនាម ទុក្ខហើយទុក្ខទៀត បង្ហូរមកនូវសេចក្តីទុក្ខ មិនដាច់ជាប់តគ្នាទៅ ដូចជាខ្សែទឹកដែលហូរនោះឯង ទុក្ខដែលត្រួតៗលើគ្នាយ៉ាងនេះ ហៅថាទុក្ខទុក្ខ ។

**៤-ទោមនស្សទុក្ខ** ទុក្ខព្រោះសេចក្តីអាក់អន់ចិត្តចំពោះអារម្មណ៍ដែលឃើ្ញសយ្នងចិត្ត គឺអារម្មណ៍ទាំង៦ មានរូបារម្មណ៍ជាដើម ដែលភ្នែកឃើញហើយមិនត្រូវចិត្ត មិនគាប់ចិត្ត ក៏កើតបដិឃៈថ្នាំងថ្នាក់ចិត្តចំពោះអារម្មណ៍ដែលទាស់នោះៗ ហើយក៏ក្តៅរោលរាលទៅដោយភ្លើងទុក្ខ គឺភ្លើងទោសៈផង ភ្លើងមោហៈផង ។ សេចក្តីថា សត្វទាំងឡាយដែលមានសេចក្តីទុក្ខពេញប្រៀបដល់បន្ទុកហើយ តែងសោកស្តាយយំកន្ទក់កន្ទេញ គក់ទ្រូងផ្តួលខ្លួនប្រមៀលត្រឡប់ត្រឡិន ផ្តួលខ្លួនដាំដូង យកជើងឡើងលើ ចាប់កាំបិតកោរ អារកឬលេបថ្នាំពិស ចងកដោយខ្សែស្ទុះរត់ចូលភ្លើង រមែងសោយនូវសេចក្តីទុក្ខយ៉ាងនេះ ជាអនេកប្បការ ហៅថា ទោមនស្សទុក្ខ ។

**៥-ឧបាយាសទុក្ខ** ទុក្ខបណ្តាលឲ្យរអាក់រអួលទង្គិះ ដោយការតឹងណែននៅក្នុងចិត្ត ព្រោះនឹកឃើញដល់សត្វនិងសង្ខារ ដែលជាទីស្រឡាញ់ពេញចិត្ត ដែលព្រាត់ប្រាស់ទៅយូរហើយ ហើយនឹកឃើញដោយសេចក្តីអាល័យ ក៏ឆ្អេតចិត្តតឹងណែន ហៅថាឧបាយាសទុក្ខនេះកើតអំពីមោហៈទាំងអស់ ។

**៦-អប្បិយេហិសម្បយោគទុក្ខ** ទុក្ខព្រោះជួបប្រទះសត្វនិង សង្ខារដែលខ្លួនមិនត្រូវចិត្ត ។

**៧-បិយេហិវិប្បយោគទុក្ខ** ទុក្ខព្រោះព្រាត់ប្រាស់និរាសចាកសត្វនិងសង្ខារ ដែលខ្លួនពេញចិត្ត គាប់ចិត្ត ។

**៨-យម្បិច្ឆំនលភតិតម្បិទុក្ខ** ទុក្ខកើតអំពីចិត្តប៉ុនប៉ងប្រាថ្នានូវ របស់ណាៗហើយ មិនបានរបស់នោះៗដូចសេចក្ដីប្រាថ្នា ក៏នាំឲ្យកើតសេចក្ដីទុក្ខ ។ ទុក្ខនេះមកតែអំពីលោភៈ មោហៈ មានឧបាទានជាមេប្រកាន់មាំ បានជាទុក្ខទាំងអស់នោះកើតច្រើនឡើងៗ ។ ទុក្ខទាំងអស់ដូចបានអធិប្បាយមកនេះ ជាទីប្រជុំនូវភ្លើងលោភៈ ទោសៈ មោហៈទាំងអស់ ។ នៃសញ្ញា វិញ្ញាណ អ្នកធ្លាប់ដេកនៅក្នុងភ្លើងទុក្ខភ្លើងកិលេស ដូចបានអធិប្បាយមកនេះមែនឬទេ? មែនណាស់ហើយបញ្ញា ខ្ញុំទាំងពីរនាក់នេះល្ងង់មែន ដូចជាសត្វមមាចត្រេកអរតែនឹងភ្លើង។ ចំណែកខ្ញុំទាំងពីរនាក់ឥតបានដឹងថាភ្លើងទុក្ខ និងភ្លើងកិលេសនេះច្រើនដល់ម្លឹងៗទេ ។ ខ្ញុំឃើញច្បាស់ណាស់ហើយ ខ្ញុំជឿប្រាកដឥតមានសង្ស័យឡើយ សូមបញ្ញា សម្ដែងតទៅទៀត ។ អើបើដូច្នោះអ្នកចាំស្ដាប់ចុះ យើងនឹងសម្ដែងអំពីទុក្ខទោសរបស់ខន្ធ៥តទៅទៀត ។ ខន្ធ៥នេះមានទុក្ខទោសច្រើនជាអនេក ជារបស់មិនទៀងទាត់ មិនស្ថិតស្ថេរចិរកាលយូរលង់ឡើយ តែងដឹកជញ្ជូនមកនូវសេចក្ដីទុក្ខ យកមកឲ្យជាសម្បុក ឬថាជាទីលំនៅរោគផ្សេងៗ សម្បូរទៅដោយដំបៅពកដោយសេចក្ដីចាក់ដោតនិងដោយពាក្យតិះដៀល អំពីសំណាក់បុគ្គលដទៃ និងការមិនចំរើនផ្សេងៗ លុះដោយជម្ងឺដម្កាត់ជាច្រើន មិនស្ដាប់បង្គាប់បញ្ញាអ្នកណាឡើយ ជរា ព្យាធិ និងមរណៈ តែងប្រលោមលួងលោម ឲ្យលុះនៅក្នុងសេចក្ដីវិនាស រាប់កប្បមិនអស់ឡើយ, តែងនាំមកនូវកម្មមិនមែនជាប្រយោជន៍ធំទូលាយ ដល់បុគ្គលដែលមិនដឹងច្បាស់នូវព្រះត្រៃលក្ខណ៍ ប្រកបដោយឧបទ្រពចង្រៃគ្រប់យ៉ាង និងភ័យផ្សេងៗ ជាប់ទៅដោយកម្មឥតប្រយោជន៍រាប់មិនអស់, ញាប់ញ័រទៅ

ដោយជរានិងមរណៈ និងលោកធម៌ទាំង៨, វិនាសទៅដោយសេចក្តីព្យាយាមរបស់ខ្លួន និងសេចក្តីព្យាយាមរបស់បុគ្គលដទៃ មិនស្ថិតស្ថេរយូរប៉ុន្មានឡើយ រកអ្វីជាទីពឹងពុំបាន ឥតមានទីជ្រកកោនឡើយ សេចក្តីសុខមានប្រមាណតិចណាស់ រកសង្ឃឹមមិនបាន, ជារបស់សូន្យទទេៗ ជារបស់មិនមែនជាខ្លួនប្រាណ ប្រកបទៅដោយទោសផ្សេងៗ ចេះតែប្រែប្រួល ប្រព្រឹត្តទៅខុសចាករបស់ដើម រកខ្លឹមសារគ្មានដូចដើមចេក រកសេចក្តីចំរើនគ្មាន តែងតែព្រាត់ប្រាស់ចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់ពេញចិត្ត ប្រកបទៅដោយអាសវៈ មានកាមាសវៈជាដើម ជាបច្ច័យប្រជុំតាក់តែង ប្រកបដោយមច្ចុមារ និងកិលេសមារ តាមបៀតបៀនជានិច្ច គឺ **ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ** ជាប់ជាបច្ច័យតាមបៀតបៀនមិនដាច់ រាប់មិនអស់នៅក្នុងភពតូច និងភពធំ ព្រោះតែ **អវិជ្ជា១ តណ្ហា១ ឧបាទាន១ កម្ម១ អាហារ១** ទាំង៥នេះហើយដែលជាអ្នកដឹកនាំឲ្យកើត-ស្លាប់រាប់មិនអស់ វិលទៅវិលមក នៅតែក្នុងភព៣ ជួនកាលធ្លាក់ទៅនរក សោយសេចក្តីវេទនារឹតតែធ្ងន់ៗថែមទៀត ។ ជួនកាលកើតទៅជាប្រេត សោយនូវសេចក្តីទុក្ខវេទនា ដោយរកអាហារបរិភោគពុំបាន ជួនកាលមកកើតជាមនុស្សដោយសេចក្តីទុក្ខលំបាក ជាប់ជាបច្ច័យតៗគ្នាមិនដាច់ កើត ស្លាប់ៗកើត រកទីបំផុតគ្មាន រាប់កំណើតក៏ពុំអស់ រាប់ការស្លាប់ក៏មិនអស់ កាលដែលស្លាប់ទៅនោះក៏ទៅទទេ មានតែទុក្ខនិងទោសជាប់តាមមកជាមួយផង ។ ខន្ធ៥មានទុក្ខទោសច្រើន ហូរទៅកាន់សេចក្តីវិនាស ដូចបានអធិប្បាយមកនេះឯង, នែសញ្ញា-វិញ្ញាណ! អ្នកស្តាប់បានហើយ ឬក៏នៅទេ?

ខ្ញុំទាំងពីរនាក់ស្តាប់បានហើយលោកម្ចាស់បញ្ញា ច្បាស់ណាស់ៗ ខ្ញុំឥតមានសេចក្តីសង្ស័យទេ ពិតជាខ្លួនខ្ញុំទាំងពីរនាក់នេះកើតមកមួយជាតិៗមានតែទុក្ខនិងទោស ហើយប្រព្រឹត្តទៅកាន់សេចក្តីវិនាសគ្មានបានសុខទេ សូមលោកសម្តែងតទៅទៀតចុះ ។

បើដូច្នេះ យើងនឹងសម្តែងអំពីកំណើតដែលអ្នកកើតនោះ អាស្រ័យនូវធម៌ដូចតទៅនេះ, ដើមដំបូងគឺ **អវិជ្ជា**ៗ មានហើយជាបច្ច័យឲ្យកើត**សង្ខារ**ៗ មានហើយជាបច្ច័យឲ្យកើត**វិញ្ញាណ**ៗ មានហើយជាបច្ច័យឲ្យកើត**នាមនិងរូប**ៗ មានហើយជាបច្ច័យឲ្យកើត**សឡាយតនៈ**ៗ មានហើយជាបច្ច័យឲ្យកើត**ផស្សៈ**ៗ មានហើយជាបច្ច័យឲ្យកើត **វេទនា**ៗ មានហើយជាបច្ច័យ ឲ្យកើត **តណ្ហា**ៗ មានហើយជាបច្ច័យឲ្យកើត**ឧបាទាន**ៗ មានហើយជាបច្ច័យឲ្យកើត **ភព**ៗ មានហើយជាបច្ច័យឲ្យកើត **ជាតិ**ៗ មានហើយជាបច្ច័យឲ្យកើត**ជរា-មរណៈ** ។ ក៏ធម៌ទាំង១២នេះ ចែកចេញជា២យ៉ាងគឺ រូប២៨ម៉្យាង, នាមធម៌៤គឺ វេទនា-សញ្ញា-សង្ខារ-វិញ្ញាណ ម៉្យាង, រួមមកនៅលើខន្ធ៥ដដែល ជារបស់ដោយឡែកពីគ្នា តែត្រូវអាស្រ័យគ្នានឹងគ្នាហើយប្រព្រឹត្តទៅ ជាសភាវធម៌មួយៗ មិនមែនជាសត្វ ជាបុគ្គល មិនមែនជាខ្លួន-ប្រាណ មិនមែនជាគេជាយើង ជាសភាវៈមួយៗអាស្រ័យគ្នានឹងគ្នា កើតឡើងហើយ រលត់សូន្យទៅជាធម្មតា វិលកើត វិលស្លាប់ នៅក្នុងវដ្តសង្សារ រកទីបញ្ចប់គ្មាន ។

រីឯសញ្ញានិងវិញ្ញាណ បានស្តាប់ហើយគិតថា បើយើងប្រឹងនៅតែក្នុងធម៌ទាំង១២យ៉ាងនេះ មុខជាបានតែទុក្ខនិងទោសយ៉ាងនេះពុំខាន

ឡើយ បើដូច្នេះខ្ញុំទាំងពីរនាក់ សូមសួរទៅបញ្ញាថា តើឲ្យខ្ញុំបដិបត្តិដូចម្តេច ទើបនឹងបានរួចអំពីធម៌ទាំង១២នេះ?

បញ្ញាឆ្លើយថា អើសញ្ញា-វិញ្ញាណ អ្នកធ្លាប់នៅក្នុងនាវាត្រៃលោកដែលប្រដាប់ដោយធម៌១៦យ៉ាងនេះ ជាយូរអង្វែងណាស់មកហើយ ។ ធម៌ទាំង១៦យ៉ាងនោះគឺ បដិច្ចសមុប្បាទ១២ ត្រៃលោក៣ អាកាសធាតុ១ ត្រូវជា១៦ ។ ធម៌ទាំង១៦នេះ ហៅថា នាវាត្រៃលោក សម្រាប់ដឹកនាំសត្វឲ្យទៅកាន់សេចក្តីវិនាស វិលទៅវិលមកនៅតែក្នុងភពតូចនិងភពធំ ។ ដូចមានសេចក្តីនៅខាងមុខឯណោះ ។

## នាវាត្រៃលោក សង្ខេបប៉ុណ្ណោះ



# នាវាត្រៃលក្ខណ៍

នាវាត្រៃលក្ខណ៍ល្អបរិសុទ្ធ ឆ្លងផុតឆ្លាមមករសត្វសាហាវ
ជញ្ជូនពួកសត្វដាក់សំដៅ ឆ្ពោះទៅនិព្វានឋានផុតភ័យ ។
នាវាត្រៃលក្ខណ៍ជាប់មាំមួន ដឹកនាំជញ្ជូនសត្វភពត្រៃ
ឆ្លងផុតសមុទ្រធំពេកក្រៃ ឥតមានទុក្ខភ័យនឹងលិចលង់ ។
តែសត្វមិនសូវចូលចិត្តជិះ ព្រោះនាវានេះមានគ្នាតិច
ស្ងាត់ស្ងៀមទ្រឈឹងឥតក្បូរក្បាច់ រំលេចភ្លឺវល្លិ៍ល្អពែនព័ន្ធ ។

និពន្ធឡើងដោយព្រះធម្មត្រៃលោកាចារ្យ **ចន្ទ - សាលី**
វត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ

# នាវាត្រៃលក្ខណ៍

ឥឡូវនេះ សញ្ញា-វិញ្ញាណ ចូរអ្នកបដិបត្តិទៅតាមនាវាត្រៃលក្ខណ៍ ដែលប្រដាប់ដោយធម៌១៦យ៉ាងនេះវិញចុះ ។ ឯធម៌១៦យ៉ាងនោះគឺ ព្រះធម្មចក្កៗ ដែលប្រដាប់ដោយអង្គទាំង៨ និងអរិយសច្ច៤ ត្រៃលក្ខណ៍ ៣ ព្រះនិព្វាន១ ត្រូវជា១៦ ។ ធម៌ទាំង១៦នេះ តែងស្ទួយលើកឡើងនូវសត្វណាដែលប្រតិបត្តិតាម ឲ្យឆ្លងផុតអំពីអន្លង់ ឱឃៈទាំង៤ ហើយនាំយកទៅដាក់ដល់ត្រើយគឺ ព្រះនិព្វាន ជាស្ថានបំផុតទុក្ខទាំងអស់ ។

សញ្ញា-វិញ្ញាណ! អ្នកស្គាល់ទុក្ខទោសច្បាស់លាស់ហើយឬនៅឡើយ?

ខ្ញុំស្គាល់ទុក្ខទោសច្បាស់ណាស់ហើយ ឥតមានសេចក្ដីសង្ស័យទេលោកម្ចាស់ ។

បើដូច្នោះបញ្ញាកើតឡើងហើយ ញាណគឺ **ធម្មចក្ខុ** កើតឡើងហើយចំពោះភ្នែករបស់អ្នក ដែលមើលទៅឃើញទុក្ខទោសរបស់ខន្ធ៥ ឃើញទុក្ខទោសរបស់ភពទាំង៣ ឃើញទុក្ខទោសរបស់ធាតុ៤ ឃើញទុក្ខទោសរបស់កាមគុណ៥ ដូច្នេះឈ្មោះថា **សម្មាទិដ្ឋិ** និង **សម្មាសង្កប្បោ** កើតឡើងហើយដល់អ្នក ។ បើដូច្នោះ អ្នកត្រូវយកធម៌មិនទៀង១ ទុក្ខ១ អនត្តា១ មកកំណត់ធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ចំពោះធម៌ **អនិច្ចំ ទុក្ខំ អនត្តា** នេះចុះ, ដើម្បីឲ្យត្រៃលក្ខណ៍ទាំង៣ កើតឡើងដល់អ្នក ។ កាលបើកំណត់ទុក្ខមកជាអារម្មណ៍ជាប់មិនដាច់ ហៅថា **ទុក្ខសច្ចៈ** មានកិច្ចជាគ្រឿងកំណត់ ។ កាលបើឃើញទុក្ខហើយ

ចំរើនឲ្យច្រើនឡើងៗ ហៅថា **មគ្គសច្ចៈ** មានកិច្ចតែខាងធ្វើឲ្យចំរើនឡើងនូវធម៌ **អនិច្ចំ ទុក្ខំ អនត្តា** ។ **សមុទយសច្ចៈ** មានកិច្ចលះបង់នូវតណ្ហា ឧបាទានចោល ។ កាលបើរំលត់តណ្ហា-ឧបាទានអស់ហើយ ហៅថា **និរោធសច្ចៈ** មានកិច្ចត្រូវធ្វើឲ្យជាក់ច្បាស់នូវធម៌មិនទៀង- ទុក្ខ- អនត្តា និងធ្វើឲ្យជាក់ច្បាស់នូវមគ្គ ផល ព្រះនិព្វាន ។ នែសញ្ញា-វិញ្ញាណ! អរិយសច្ចៈទាំង៤ កើតឡើងដល់អ្នកហើយ ។ ត្រង់ដែលអ្នកព្យាយាមចំរើនឲ្យឃើញនូវទុក្ខទោសនោះ ហៅថា **សម្មាវាយាមោ** ។ ត្រង់ដែលអ្នករំលឹកទៅឃើញតែមិនទៀង- ទុក្ខ- អនត្តា រឿយៗហៅថា **សម្មាសតិ** ។ ត្រង់ដែលអ្នកកំណត់ចិត្តទុកក្នុងអារម្មណ៍របស់ត្រៃ-លក្ខណ៍ទាំង៣នោះ ឲ្យនឹងនៅមូលតែមួយ ហៅថា **សម្មាសមាធិ** ។ ដូច្នេះអដ្ឋង្គិកមគ្គទាំង៨ មានដល់អ្នកគ្រប់គ្រាន់ហើយ ។

ត្រង់ដែលអ្នកកំណត់ទុក្ខយកមកជាអារម្មណ៍ រមែងរំលត់បង់នូវ **សង្ខតនិមិត្ត** គឺនិមិត្តដែលធ្លាប់ឃើញថាសុខៗនោះចេញអស់ ហៅថា **ព្រះនិព្វាន** ។

ត្រង់ដែលអ្នកកំណត់យកការមិនទៀងមកជាអារម្មណ៍នោះ រមែងរំលត់បង់នូវសញ្ញា ដែលធ្លាប់សំគាល់ថាទៀងៗ ថាជាប់ៗ ថាល្អៗនោះចេញ កាន់យកនូវ **អសង្ខតនិមិត្ត** គឺមិនមាននិមិត្តក្នុងអារម្មណ៍ទាំង៦ ហៅថា **អនិមិត្តវិមោក្ខ** ព្រោះរួចផុតអំពីនិមិត្ត ឬថាឆ្លងផុតអំពីអារម្មណ៍ទាំង៦ អស្មិមានៈក៏រលត់អស់ទៅ ហៅថា **អនិមិត្តវិមោក្ខនិព្វាន** ដូច្នេះវិញក៏បាន ។ ត្រង់ដែលអ្នកកំណត់នូវធម៌អនត្តាមកជាអារម្មណ៍នោះ គឺកំណត់ឃើញច្បាស់ថា ខន្ធទាំង៥នេះ ពិតជាមិនមែន

ខ្លួន មិនមែនអញ-ឯង មិនមែនយើង មិនមែនគេ មិនមែន ជាប្រុស-ស្រី មិនមែនជាសត្វ- បុគ្គល ។ កំណត់ឃើញច្បាស់ថា ជារបស់ធាតុដី- ទឹក- ភ្លើង- ខ្យល់ ប៉ុណ្ណោះ ។ កាលបើឃើញថាមិនមែនខ្លួន មិនមែនអញ ដូច្នោះហើយ ក៏រមែងរំលត់បង់នូវ **សង្ខតនិមិត្ត** គឺនិមិត្តដែលឃើញ ថាខ្លួនៗ ថាអញៗនោះចេញបាន កាន់យកនូវអសង្ខតនិមិត្ត គឺមិនមាន និមិត្ត ហើយប្រព្រឹត្តទៅឆ្លងផុតពីសង្ខតធម៌ ឬថាឆ្លងផុតពីអារម្មណ៍ ទាំង៦ ឬថាប្រាសចាកសង្ខារធម៌ជាអារម្មណ៍ ឈ្មោះថា **សុញ្ញតវិមោក្ខ** ព្រោះរួចផុតអំពីនិមិត្ត ដែលឃើញថាខ្លួន ថាអញៗនោះ ។

នៃសញ្ញា និង វិញ្ញាណ នាវាត្រៃលក្ខណ៍មានគ្រប់គ្រាន់ដល់អ្នក ហើយឬ? មានគ្រប់គ្រាន់ហើយព្រះអង្គ ភ្លឺស្វាងច្បាស់ណាស់ៗ ដូចជាព្រះអាទិត្យទើបនឹងរះ ភ្លឺណាស់ ឥតមានសង្ស័យអ្វីបន្តិចបន្តួច ក្នុងភពទាំង៣នេះសោះឡើយ ខ្ញុំទាំងពីរនាក់នេះ ក៏ឆ្លងផុតអំពី នាវាត្រៃលោកហើយ ឥតមានការទាក់ទាមនៅក្នុងនាវាត្រៃលោកទៀតទេ ។

បញ្ញាពោលថា, មហាបាតិមោក្ខទាំង៣នេះ បើអ្នកចូលតាម បាតិមោក្ខណាមួយ ក៏នឹងឃើញច្បាស់នូវព្រះនិព្វានដូចគ្នាទាំង៣ ។ កាលបើអ្នកចំរើនធម៌ទុក្ខំ ចូលកាន់អប្បណិហិតវិមោក្ខ ក៏ឃើញច្បាស់ នូវព្រះនិព្វាន ។ កាលបើអ្នកចំរើនធម៌អនិច្ចំ ចូលកាន់អនិមិត្តវិមោក្ខ ក៏ ឃើញច្បាស់នូវព្រះនិព្វានដូចគ្នា ។ កាលបើអ្នកចំរើនធម៌អនត្តា ចូលកាន់សុញ្ញតវិមោក្ខ ក៏ឃើញច្បាស់នូវព្រះនិព្វានដូចគ្នាដែរ ។ ធម៌ទាំង៣នេះ តាមតែអ្នកស្ទាត់ជំនាញ ពេញចិត្តណាមួយក៏បាន (បានជាកវីបូរាណយើងនិពន្ធទុកក្នុងសាស្ត្រាច្បាប់ក្រមថា) **ចូលមហា-បាតិមោក្ខ គឺនិព្វានហោង ។**

មហាបាតិមោក្ខទាំង៣នេះ ជាធម៌ផុតព្រំដែនរបស់ត្រៃលោក ។ នាវាត្រៃលក្ខណ៍ដែលប្រដាប់ដោយធម៌១៦គឺ **អដ្ឋង្គិកាមគ្គ៨ អរិយ-សច្ចៈ៤ ត្រៃលក្ខណ៍៣** និង **ព្រះនិព្វាន១** ។ ធម៌ទាំង១៦នេះ មានគ្រប់គ្រាន់ដល់អ្នកហើយ ។ បើដូច្នេះចូរអ្នកកំណត់ធម៌ **អនិច្ចំ- ទុក្ខំ- អនត្តា** ឲ្យមាំមួនចុះ ព្រោះថាសេចក្តីកំណត់ជាហេតុនាំឲ្យត្រាស់ដឹងនូវពោធិបក្ខិយធម៌ទាំង៣៧ប្រការ ហូរមកប្រជុំលើការកំណត់ទុក្ខ គឺការកំណត់ថាមិនទៀង កំណត់ថាទុក្ខ កំណត់ថាជាអនត្តា ។ ឯការកំណត់នូវធម៌ទាំង៣នេះ ជាកិច្ចរបស់ទុក្ខសច្ចៈ គឺជាកិច្ចត្រូវតែកំណត់ហើយចំរើនធម៌ទាំងនេះឲ្យច្រើនឡើងៗ នេះជាកិច្ចរបស់មគ្គសច្ចៈ ត្រូវតែចំរើនឲ្យច្រើននូវសេចក្តីកំណត់ទាំង៣នេះ ។ បញ្ញាដែលឃើញច្បាស់នូវកងទុក្ខ មិនទៀង ជាទុក្ខ ជាអនត្តា ឃើញច្បាស់នូវចិត្តដែលកំណត់ទុក្ខ ឃើញច្បាស់នូវមគ្គដែលចំរើនទុក្ខនោះ ឃើញច្បាស់នូវធម៌ដែលរំលត់ទុក្ខនោះ ត្រង់កិច្ចពិនិត្យឲ្យច្បាស់នូវធម៌គ្រប់អន្លើនោះ ជាកិច្ចរបស់និរោធសច្ចៈ កិច្ចនេះត្រូវតែធ្វើឲ្យជាក់ច្បាស់ដោយញាណជាគ្រឿងត្រាស់ដឹង ។ ធម៌ដែលជាញាណត្រូវត្រាស់ដឹងនោះ គឺ ពោធិ-បក្ខិយធម៌៣៧ គឺសតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រីយ៥ ពលៈ៥ ពោជ្ឈង្គ៧ អង្គមគ្គ៨ ។ ធម៌ទាំង៣៧ប្រការនេះកើតឡើងព្រមដោយគ្រឿងកំណត់ថាជាទុក្ខ កំណត់ថាមិនទៀង កំណត់ថាជាអនត្តា បើខ្វះគ្រឿងកំណត់ថាមានទុក្ខជាដើមហើយ ធម៌ទាំង៣៧ប្រការនេះឥតកើតមានទេ ។ បើកំណត់យកធម៌អនត្តាមកជាអារម្មណ៍ ឃើញច្បាស់ថា រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ, ធម៌ទាំងអស់នេះមិនមែនជាខ្លួនប្រាណ មិនមែនជាអញ-ឯង មិនមែនជាប្រុស - ស្រី មិនមែនជា

សត្វ - បុគ្គល ឃើញយ៉ាងនេះហើយ ខំបំពេញព្យាយាមចំរើនមិនឲ្យដាច់ នោះសតិបដ្ឋាន៤ សម្មប្បធាន៤ ក៏កើតឡើងព្រម ឥទ្ធិបាទ៤ ឥន្ទ្រីយ៥ ពលៈ៥ ពោជ្ឈង្គ៧ អង្គមគ្គ៨ ក៏កើតឡើងព្រមគ្នាដោយសេចក្ដីកំណត់នោះ និងគប្បីព្យាយាមចំរើនឲ្យច្រើនឡើងៗ នេះជាកិច្ចរបស់មគ្គសច្ចៈ ។ ពិនិត្យឲ្យជាក់ច្បាស់នូវពោធិបក្ខិយធម៌ ដែលកើតឡើងព្រមដោយសេចក្ដីព្យាយាមចំរើននោះ ជាកិច្ចរបស់និរោធសច្ចៈ ។

សេចក្ដីថាមគ្គញ្ញាណខាងដើមនេះ ធ្វើឲ្យសម្រេច មិនគប្បីធ្វើនូវកិច្ចដទៃទៀតឡើយ ត្រូវតែចំរើនអនត្តា ជាអនុលោមបដិលោមម្យ៉ាងឲ្យសម្រេច ។ កិលេសដែលបិទបាំងនូវសច្ចៈទាំង៤នេះ ត្រូវកំចាត់បង់ដោយអនុលោម៣ ចិត្តដែលមិនជាប់នៅក្នុងសង្ខារ មិនស្ទុះស្ទារទៅកាន់អារម្មណ៍ផ្សេងៗ ដូចជាទឹកដែលមិនដក់នៅលើស្លឹកឈូក មានការប្រព្រឹត្តទៅ មានអនត្តាជាអារម្មណ៍ ទាំងនេះក៏កើតប្រាកដដល់ព្រះយោគីដែលមានសេចក្ដីខ្វល់ខ្វាយ ។ លំដាប់នោះព្រះយោគីចំរើននូវ អនុលោមញ្ញាណ ធ្វើនូវព្រះនិព្វានដែលមិនមាននិមិត្ត ប្រាសចាកសង្ខារធម៌ឲ្យជាអារម្មណ៍ ហើយកន្លងនូវបុថុជ្ជនគោត្រនិងបុថុជ្ជនភូមិ ហើយឡើងទៅកាន់អរិយគោត្រ និងអរិយភូមិ គោត្រភូញាណក៏កើតប្រាកដ ហើយគ្របសង្កត់នូវកិរិយាកើតឡើង និងកិរិយាប្រព្រឹត្តទៅ ហើយក៏ស្ទុះទៅកាន់ព្រះនិព្វានជាអារម្មណ៍ ដូច្នេះឈ្មោះថា គោត្រភូ ហើយក៏នៅស្ងៀមយ៉ាងណាមិញ ចំណែកព្រះយោគីដែលនឹងឆ្លងទៅកាន់ព្រះនិព្វាន ក៏យ៉ាងនោះដែរ ។ អនុលោមជវនដែលពិចារណាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ដូច្នេះក៏មិនព្រមលែងនៅរូបនោះ ហើយលោតឡើងដោយ អនុលោមចិត្តជាបឋម មានចិត្តទោរទន់ទៅកាន់ព្រះនិព្វាន ដូចជាទោរទន់ទៅកាន់

ត្រើយម្ខាងជិតព្រះនិព្វាន ដោយគតិយជវនដូចជាដល់ត្រើយខាងនាយ លែងពិចារណានូវសង្ខារ ដល់នូវត្រើយគឺព្រះនិព្វាន ដោយគោត្រភូចិត្ត អនុលោមញ្ញាណកំចាត់បង់នូវងងឹតគឺកិលេស ដែលបិទបាំងនូវសច្ចៈ៤ តែមិនអាចធ្វើនូវព្រះនិព្វានឲ្យជាអារម្មណ៍បានឡើយ ។ ឯគោត្រភូទើប ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍បាន តែមិនអាចកំចាត់បង់ងងឹត គឺកិលេស បានឡើយ ។ ចំណែកអនុលោមញ្ញាណកំចាត់បង់នូវកិលេសបាន តែមិនអាចឃើញនូវព្រះនិព្វានដោយខ្លួនឯងបានទេ ។ ឯគោត្រភូ-ញាណឃើញនូវព្រះនិព្វាន តែមិនអាចកំចាត់បង់កិលេសបានឡើយ, មគ្គមិនលែងនូវសញ្ញាដែលគោត្រភូញាណឲ្យ ។ បញ្ញានោះក៏ត្រាស់ដឹង តៗគ្នាមិនដាច់ ហើយទំលាយនូវគំនរលោភៈ ទោសៈ មោហៈ ដោយ អំណាចអរិយមគ្គញ្ញាណ ។

នែសញ្ញា-វិញ្ញាណ ! ផ្លូវប្រតិបត្តិដែលបានសំដែងមកនេះ អ្នក ឃើញសព្វគ្រប់ហើយឬ?

ខ្ញុំព្រះករុណាទាំង២នាក់ បានឡើងជិះនាវាព្រះត្រៃលក្ខណ៍ ដែល ប្រដាប់ដោយធម៌ទាំង១៦ យ៉ាងនោះ ឃើញថាត្រជាក់ណាស់ សុខ ក្សេមក្សាន្តណាស់ ភ្លឺណាស់ ។ ផ្លូវប្រតិបត្តិដើម្បីជាគ្រឿងរំលត់ទុក្ខ ខ្ញុំស្គាល់ច្បាស់ណាស់ហើយ ឥតមានទាក់ទាមទេព្រះអង្គ សូមព្រះអង្គ សំដែងធម៌តទៅទៀត ។

អើបើដូច្នោះ យើងនឹងសំដែងអំពីនាវាត្រៃលោក ដែលប្រដាប់ ដោយធម៌១៦យ៉ាង និង កិលេសដែលកើតឡើងជ្រៀតជ្រែកនៅជា មួយគ្នានោះតទៅ ធម៌ទាំង១៦នោះគឺ **បដិច្ចសមុប្បាទ១២ ត្រៃលោក៣ អាកាសធាតុ១** ត្រូវជា១៦ ។ ធម៌ទាំង១៦នេះ ឧបមាដូចជានាវាសម្រាប់

ដឹកនាំសត្វឲ្យទៅកាន់ភពតូចនិងភពធំ ប្រកបទៅដោយទុក្ខនិងទោស ច្រើនជាអនេករាប់មិនអស់នៅក្នុងភព៣ កើតហើយស្លាប់ ស្លាប់ហើយកើតវិញរកទីបំផុតគ្មាន ព្រោះតែប្រកបដោយធម៌ទាំង១៦យ៉ាងនេះ ។ នឹងអធិប្បាយអំពីធម៌ទាំង១៦យ៉ាងនេះតទៅគឺ បដិច្ចសមុប្បាទ១២នោះ បានសំដែងរួចមកហើយ (ក្នុងទំព័រលេខ៦១) ឯក្នុងទីនេះនឹងសំដែងតែអំពីត្រៃលោក និងអាកាសធាតុប៉ុណ្ណោះ ។ ត្រៃលោកនោះមាន៣គឺ កាមលោក១ រូបលោក១ អរូបលោក១ និងអាកាសធាតុ១ ជាមេប្រធានលើលោកទាំង៣ ។ អាកាសធាតុ ធាតុដែលស្រូបជប់ឲ្យកើតឡើងនូវធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ នៅក្នុងលោកទាំង៣នេះ ម្ល៉ោះហើយសង្ខារលៃលកតាក់តែងឲ្យកើតមនុស្ស-សត្វ នៅក្នុងកាមភព, រូបភព, អរូបភព ដោយសង្ខារជាអ្នកតាក់តែងលៃលកទៅតាមអំពើបុណ្យនិងអំពើបាបរបស់សត្វ ល្អនិងអាក្រក់ ធំនិងតូច ខ្ពស់និងទាប ដោយសង្ខារជាអ្នកចាត់ចែងលៃលកឲ្យកើតឡើង ដោយអាស្រ័យនូវធាតុទាំង៥ គឺអាកាសធាតុ១ ធាតុដី១ ធាតុទឹក១ ធាតុភ្លើង១ ធាតុខ្យល់១ កើតឡើងតៗគ្នាគឺ អវិជ្ជា១ សង្ខារ១ វិញ្ញាណ១ នាមរូប១ សឡាយតនៈ១ ផស្សៈ១ វេទនា១ តណ្ហា១ ឧបាទាន១ ភព១ ជាតិ១ ជរា-មរណៈ១ ធម៌ដែលកើតឡើងតៗគ្នានេះហៅថា បដិច្ចសមុប្បាទ ។ កងទុក្ខទាំង១២ ក៏កើតឡើងតៗគ្នាជាមួយនឹង បដិច្ចសមុប្បាទ ហើយប្រព្រឹត្តទៅនៅក្នុងនាវាត្រៃលោក៣គឺ **កាមលោក រូបលោក អរូបលោក** លោកទាំង៣នេះ បានសេចក្ដីថាវិនាស ក្នុងកាមលោកក៏វិនាស រូបលោកនិងអរូបលោក ក៏វិនាស ។ ត្រង់សេចក្ដីថាវិនាស ហៅថាលោក ។ ត្រង់ដែលសូន្យចន្លោះទទេៗ ហៅថាអាកាសធាតុ ។ ធម៌ទាំង១៦នេះ ឧបមាដូច

ជានាវាមួយសម្រាប់ដឹកនាំសត្វឲ្យទៅកាន់សេចក្ដីវិនាស នៅតែក្នុងត្រៃលោកទាំង៣នេះទេ គឺកើតហើយស្លាប់ ស្លាប់ហើយកើត រាប់មិនអស់រកទីចប់គ្មាន ។ ហេតុមកតែអំពីអវិជ្ជា តណ្ហានិងឧបាទាន ដែលជាបច្ច័យឲ្យកើតភព ។ ភពនោះមាន២យ៉ាងគឺ **ឧបបត្តិភព១ កម្មភព១** ។ ចំណែក ឧបបត្តិភពនោះមាន៩ផ្សេងគ្នាដោយខន្ធ គឺ **កាមភព១ រូបភព១ អរូបភព១ សញ្ញាភព១ អសញ្ញាភព១ នេវសញ្ញានាសញ្ញាភព១ ឯកវោការភព១ ចតុវោការភព១ បញ្ចវោការភព១** ភពទាំង៩នេះហៅថា**ឧបបត្តិភព** ។ ចំណែក**កម្មភព** ភពដែលប្រកបដោយតម្រេកទាំងប៉ុន្មាន បានដល់អបាយភូមិ៤ មនុស្ស១ និងស្ថានសួគ៌៦ជាន់ ។ រូបភពគឺភពដែលមានរូប បានដល់ព្រហ្ម១៦ជាន់ ។ **អរូបភព** ភពដែលឥតរូប បានដល់អរូបព្រហ្ម៤ជាន់ ។ **សញ្ញាភព** គឺភពដែលមានសញ្ញា ។ **អសញ្ញាភព** ភពដែលឥតសញ្ញា ។ **នេវសញ្ញានាសញ្ញាភព** បានដល់អរូបព្រហ្ម៤ ។ ភព៩សង្ខេបតែប៉ុណ្ណេះ ។

នឹងសំដែងអំពីកម្មភពតទៅ ។ ឯកម្មភពនេះគឺភពដែលសត្វធ្វើមាន៣យ៉ាងគឺ **កាមភព១ រូបភព១ អរូបភព១** ។ ភពទាំង៣នេះមានឧបាទាននិងតណ្ហាជាបច្ច័យឲ្យកើតឡើង ។ នឹងវិនិច្ឆ័យអំពីតណ្ហានិងឧបាទានដែលបង្កើតឡើងនូវភពនោះៗ ។ តណ្ហានោះមាន៣៦គឺ តណ្ហាខាងក្នុងមាន១៨ ខាងក្រៅមាន១៨ រួមជា៣៦ ។ ឯតណ្ហាខាងក្នុងនោះគឺ

ចិត្តត្រេកអរនឹងភ្នែក តួចិត្តដែលត្រេកអរនោះហៅថា **កាមតណ្ហា** ភ្នែកនោះហៅថា **កាមភព** ។ បើជាប់ចិត្តនឹងភ្នែក ប្រកាន់យកតែ

ទៀងៗ តួចិត្តជាប់នេះហៅថា **ភវតណ្ហា** ភ្នែកនោះជា **រូបភព១** ។ បើចិត្តមិនចង់ឲ្យភ្នែក ចាស់ ឈឺ ស្លាប់ តួចិត្តដែលមិនចង់នោះជា **វិភវតណ្ហា** ភ្នែកនោះហៅថា **អរូបភព១** ។ ក្នុងភ្នែក១មានតណ្ហា៣ មានឧបាទាន៣ មានទិដ្ឋិ២ គឺកាមតណ្ហានិងភវតណ្ហាប្រកបដោយ **សស្សតទិដ្ឋិ** ចំណែកឯវិភវតណ្ហាប្រកបដោយ **ឧច្ឆេទទិដ្ឋិ** ។ ឯឧបាទាននោះប្រកាន់ទៅតាមតណ្ហាទាំង៣ មិនដែលលះបង់ចោលគ្នាឡើយ ។

បើចិត្តត្រេកអរនឹងត្រចៀក តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** ត្រចៀកនោះជា **កាមភព** , បើចិត្តជាប់នឹងត្រចៀកឲ្យនៅតែទៀងៗ តួចិត្តជាប់នោះហៅថា **ភវតណ្ហា** ត្រចៀកនោះហៅថា **រូបភព១** ។ បើចិត្តមិនចង់ឲ្យត្រចៀកចាស់ ឈឺ ស្លាប់ តួចិត្តមិនចង់នោះហៅថា **វិភវតណ្ហា** ត្រចៀកនោះហៅថា **អរូបភព១** ។ ក្នុងត្រចៀក១ មានតណ្ហា៣ មានភព៣ មានឧបាទាន៣ មានទិដ្ឋិ២ ។

បើចិត្តត្រេកអរនឹងច្រមុះ តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** ច្រមុះនោះជា **កាមភព** , បើចិត្តជាប់នឹងច្រមុះចង់ឲ្យនៅតែទៀងៗ តួចិត្តជាប់នោះហៅថា **ភវតណ្ហា** ច្រមុះនោះហៅថា **រូបភព១** ។ បើចិត្តមិនចង់ឲ្យច្រមុះចាស់ ឈឺ ស្លាប់ តួចិត្តដែលមិនចង់នោះហៅថា **វិភវតណ្ហា** ច្រមុះនោះហៅថា **អរូបភព១** ។ ក្នុងច្រមុះនោះមានតណ្ហា៣ មានភព៣ មានឧបាទាន៣ មានទិដ្ឋិ២ គឺកាមតណ្ហានិងភវតណ្ហា ប្រកបដោយ **សស្សតទិដ្ឋិ** និងវិភវតណ្ហាប្រកបដោយ **ឧច្ឆេទទិដ្ឋិ** (ដូចគ្នាទាំងអស់) ។

បើចិត្តត្រេកអរនឹងអណ្តាត តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** អណ្តាតនោះជា **កាមភព** ។ បើចិត្តជាប់នឹងអណ្តាត តួចិត្តជាប់នោះជា **ភវតណ្ហា** អណ្តាតនោះជា *រូបភព១* ។ បើចិត្តមិនចង់ឲ្យអណ្តាតចាស់ ឈឺ ស្លាប់ តួចិត្តដែលមិនចង់នោះជា **វិភវតណ្ហា** អណ្តាតនោះជា *អរូបភព១* ។

បើចិត្តត្រេកអរនឹង**កាយ** តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** កាយនោះជា **កាមភព១** ។ បើចិត្តជាប់នឹងកាយ តួចិត្តដែលជាប់នោះជា **ភវតណ្ហា** កាយនោះជា *រូបភព១* ។ បើចិត្តមិនចង់ឲ្យកាយចាស់ ឈឺ ស្លាប់ តួចិត្តដែលមិនចង់នោះជា **វិភវតណ្ហា** កាយនោះជា *អរូបភព១* ។ បើចិត្តដែលត្រេកអរនោះ ហៅថា **កាមតណ្ហា** ចិត្តនោះហៅថា **កាមភព១** ។ បើចិត្តជាប់នឹងចិត្ត តួចិត្តដែលជាប់នោះហៅថា **ភវតណ្ហា** ចិត្តនោះហៅថា *រូបភព១* ។ បើចិត្តមិនចង់ឲ្យចិត្តព្រាត់ប្រាស តួចិត្តដែលមិនចង់នោះ ហៅថា **វិភវតណ្ហា** ចិត្តនោះហៅថា *អរូបភព១* ។

**តណ្ហា១៨ខាងក្នុងសង្ខេបតែប៉ុណ្ណោះ ។**

**នឹងសំដែងអំពីតណ្ហាខាងក្រៅ១៨តទៅទៀត ។**

បើចិត្តត្រេកអរនឹងរូប តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** រូបនោះជា **កាមភព១** ។ បើចិត្តជាប់នឹងរូប តួចិត្តដែលជាប់នោះជា **ភវតណ្ហា** រូបនោះជា *រូបភព១* ។ បើចិត្តមិនចង់ឲ្យរូបព្រាត់ប្រាស តួចិត្តដែលមិនចង់នោះជា **វិភវតណ្ហា** រូបនោះជា *អរូបភព១* ។

ក្នុងរូប១មានភព៣ មានតណ្ហា៣ មានឧបាទាន៣ មានទិដ្ឋិ២ (ដូចគ្នាទាំងអស់) ។ បើចិត្តត្រេកអរនឹងសម្លេង តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** សម្លេងនោះជា **កាមភព១** ។ បើចិត្តជាប់នឹងសម្លេង តួចិត្តដែលជាប់នោះជា **ភវតណ្ហា** សម្លេងនោះជា ***រូបភព១*** ។ បើចិត្តមិនចង់ឲ្យសម្លេងព្រាត់ប្រាស តួចិត្តដែលមិនចង់នោះជា ***វិភវតណ្ហា*** សម្លេងនោះជា ***អរូបភព១*** ។ ក្នុងសម្លេង១មានភព៣ មានតណ្ហា៣ មានឧបាទាន៣ មានទិដ្ឋិ២ (ដូចគ្នាទាំងអស់) ។ បើចិត្តត្រេកអរនឹងក្លិន តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** ក្លិននោះជា **កាមភព១** ។ បើចិត្តជាប់នឹងក្លិន តួចិត្តដែលជាប់នោះជា **ភវតណ្ហា** ក្លិននោះជា ***រូបភព១*** ។ បើចិត្តមិនចង់ឲ្យក្លិនព្រាត់ប្រាសបាត់ទៅ តួចិត្តដែលមិនចង់នោះជា ***វិភវតណ្ហា*** ក្លិននោះជា ***អរូបភព១*** ។ ក្នុងក្លិន១ មានភព៣ មានតណ្ហា៣ មានឧបាទាន៣ មានទិដ្ឋិ២ ។ បើចិត្តត្រេកអរនឹងរស តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** រសនោះជា **កាមភព១** ។ បើចិត្តជាប់នឹងរស តួចិត្តដែលជាប់នោះជា **ភវតណ្ហា** រសនោះជា ***រូបភព១*** ។ បើចិត្តមិនចង់ឲ្យរសនោះបាត់ទៅ តួចិត្តដែលមិនចង់នោះជា ***វិភវតណ្ហា*** រសនោះជា ***អរូបភព១*** ។ ក្នុងរស១ មានភព៣ មានតណ្ហា៣ មានឧបាទាន៣ មានទិដ្ឋិ ២ ។ បើចិត្តត្រេកអរនឹងសម្ផស្ស តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** សម្ផស្សនោះជា **កាមភព១** ។ បើចិត្តជាប់នឹងសម្ផស្ស តួចិត្តដែលជាប់នោះជា **ភវតណ្ហា** សម្ផស្សនោះជា ***រូបភព១*** ។ បើចិត្តមិនចង់ឲ្យសម្ផស្សបាត់បង់ទៅ តួចិត្តដែលមិនចង់

នោះជា **វិភវតណ្ហា** សម្ពស្សនោះជា **អរូបភព១** ។ ក្នុងសម្ពស្ស១ មានភព៣ មានតណ្ហា៣ មានឧបាទាន ៣ មានទិដ្ឋិ២ ។ បើចិត្តត្រេកអរនឹងធម្មារម្មណ៍ តួចិត្តដែលត្រេកអរនោះជា **កាមតណ្ហា** ធម្មារម្មណ៍នោះជា **កាមភព១** ។ បើចិត្តជាប់នឹងធម្មារម្មណ៍ តួចិត្តដែលជាប់នោះជា **ភវតណ្ហា** ធម្មារម្មណ៍នោះជា **រូបភព១** ។ បើចិត្តមិនចង់ឲ្យធម្មារម្មណ៍ព្រាត់ប្រាសទៅ តួចិត្តដែលមិនចង់នោះជា **វិភវតណ្ហា** ធម្មារម្មណ៍នោះជា **អរូបភព១** ។ ក្នុងធម្មារម្មណ៍១ មានភព៣ មានតណ្ហា៣ មានឧបាទាន៣ មានទិដ្ឋិ២ ។

បូករួមតណ្ហាខាងក្នុង១៨ និងខាងក្រៅ១៨ ត្រូវជា៣៦ ។

តណ្ហាទាំង៣៦នេះ តែងកើតឡើងផ្លាស់ប្តូរគ្នាជាធម្មតា ។ ត្រង់ដែលផ្លាស់ប្តូរគ្នាម្តងៗនេះហើយ ដែលចាត់ជាអតីត អនាគត បច្ចុប្បន្ន ។ កាលបើភ្នែកក្រឡេកឃើញរូបហើយ ចិត្តត្រេកអរ កាមតណ្ហានេះជាបច្ចុប្បន្ន អតីត អនាគត មិនទាន់មានមកដល់ ។ កាលបើចិត្តជាប់នឹងរូប **ភវតណ្ហា** នេះជាបច្ចុប្បន្ន **កាមតណ្ហា** នោះជាអតីតវិញ អនាគតមិនទាន់មានមកដល់ ។ កាលបើចិត្តមិនចង់ឲ្យរូបព្រាត់ប្រាស **វិភវតណ្ហា** នេះជាបច្ចុប្បន្ន **ភវតណ្ហា**នោះជាអតីតវិញ អនាគតមិនទាន់មានមកដល់ ។ តណ្ហានេះចាត់ទុកជា អតីត៣៦ អនាគត៣៦ បច្ចុប្បន្ន៣៦ រួមទាំងអស់ត្រូវជា១០៨ ។

| | | |
|---|---|---|
| **ជាតិ** | កើតមានព្រោះ | **ភព** |
| **ភព** | កើតមានព្រោះ | **ឧបាទាន** |

ឧបាទាន  កើតមានព្រោះ  តណ្ហា

តណ្ហា  កើតមានព្រោះ  វេទនា

វេទនា  កើតមានព្រោះ  ផស្សៈ

ផស្សៈ  កើតមានព្រោះ  សឡាយតនៈ

សឡាយតនៈ កើតមានព្រោះ  នាម-រូប

នាម-រូប  កើតមានព្រោះ  សង្ខារ

សង្ខារ  កើតមានព្រោះ  អវិជ្ជា ។

ក៏បដិច្ចសមុប្បាទនេះជាធម៌ដោយឡែកអំពីគ្នា តែត្រូវអាស្រ័យគ្នាហើយកើតឡើងតៗគ្នា ព្រោះមានអវិជ្ជានិងសង្ខារជាមេប្រធានបណ្តាលឲ្យកើតឡើងតៗគ្នាមិនដាច់ ហើយអវិជ្ជាទៅកាន់ការគ្រប់តំណែងសង្ខារក៏ជាអ្នកតាក់តែងគ្រប់ដំណែង នៅក្នុងបដិច្ចសមុប្បាទធម៌នេះហើយកងទុក្ខទាំង១២មានជាតិទុក្ខជាដើម ក៏កើតឡើងតៗគ្នា ព្រោះមានអវិជ្ជានិងសង្ខារជាបច្ច័យ ។ កាលបើបដិច្ចសមុប្បាទកើតឡើង កងទុក្ខក៏កើតឡើង ហើយហូរចូលទៅកាន់ត្រៃលោក ។ ត្រៃលោកក៏បញ្ជូនទៅកាន់អាកាសធាតុ ទៅនៅត្រង់សេចក្តីវិនាសសូន្យសោះទទេៗហៅថាអាកាសធាតុ ។ នាវាត្រៃលោកដែលប្រដាប់ទៅដោយធម៌ទាំង១៦ យ៉ាងនេះ គឺបដិច្ចសមុប្បាទ១២ ត្រៃលោក៣ អាកាសធាតុ១ ត្រូវជា១៦ ។ កាលបើធម៌ទាំង១៦នេះកើតឡើងហើយ ភ្លើងទុក្ខនិងភ្លើងកិលេសក៏កើតឡើងតៗគ្នាជាប់មិនដាច់ ដូចន័យដែលមានសេចក្តីអធិប្បាយទៅខាងមុខនេះ ។

ភ្លើងកិលេសដែលកើតឡើងតៗគ្នានោះដូច្នេះគឺ៖

សំយោជនៈ១០

កិលេស១០

មិច្ឆត្តធម៌១០

លោកធម៌៨

មច្ឆរិយៈ៥

វិបល្លាស៣

គន្ថៈ៤

អគតិ៤

អាសវៈ៤

ឱឃៈ៤

យោគៈ៤

នីវរណៈ៥

ឧបាទាន៤

បរាមាសៈ១

អនុសយៈ៧

មលៈ៣

អកុសលកម្មបថ១០

អកុសលចិត្តុប្បាទ១២ ។

សំយោជនៈ១០គឺ ៖

| | |
|---|---|
| សក្កាយទិដ្ឋិ | ប្រកាន់កាយថាជារបស់ខ្លួន១ |
| វិចិកិច្ឆា | សេចក្តីសង្ស័យស្ទាក់ស្ទើរ១ |
| សីលព្វតបរាមាសៈ | ចិត្តស្ទាបអង្អែលក្នុងជីវិត១ |
| កាមរាគៈ | សេចក្តីត្រេកអរក្នុងកាម១ |
| បដិឃៈ | សេចក្តីថ្នាំងថ្នាក់ចិត្ត១ |
| រូបរាគ | សេចក្តីត្រេកអរក្នុងរូបភព១ |
| អរូបរាគ | សេចក្តីត្រេកអរ ក្នុងអរូបភព១ |
| មានោ | លើកដាក់ខ្លួនឯងប្រកាន់១ |
| ឧទ្ធច្ចៈ | ចិត្តអណ្តែត អណ្តូងរាយមាយ១ |
| អវិជ្ជា | សេចក្តីល្ងង់ខ្លៅ១ ។ |

កិលេស១០ នោះគឺ៖

| | |
|---|---|
| លោភោ | សភាពធ្វើចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍១ |
| ទោសោ | សភាពធ្វើចិត្តឲ្យប្រទុស្តក្នុងអារម្មណ៍ឬថ្នាំងថ្នាក់១ |
| មោហោ | សភាពធ្វើចិត្តឲ្យវង្វេងក្នុងអារម្មណ៍១ |
| មានោ | សភាពលើកខ្លួនឬដាក់ខ្លួន១ |
| ទិដ្ឋិ | ធម្មជាតិធ្វើចិត្តឲ្យឃើញខុសឬយល់ខុស១ |

វិចិកិច្ឆា ធម្មជាតិឲ្យសង្ស័យឬស្ទាក់ស្ទើរ១

ថីនំ ធម្មជាតិធ្វើចិត្តឲ្យរួញរា ឬឲ្យធុញទ្រាន់ក្នុងកុសលផ្សេងៗ១

ឧទ្ធច្ចំ ធម្មជាតិធ្វើចិត្តឲ្យញាប់ញ័រឬឲ្យរាយមាយ១

អហិរិកំ ធម្មជាតិមិនខ្មើមអំពើទុច្ចរិត១

អនោតប្បំ ធម្មជាតិមិនខ្លាចឬមិនតក់ស្លុតនូវអំពើទុច្ចរិត១ ។

### មិច្ឆត្តធម៌១០នោះគឺ៖

១- មិច្ឆាទិដ្ឋិ គំនិតយល់ខុសហើយប្រកាន់ថាត្រូវ

២- មិច្ឆាសង្កប្បៈ ត្រិះរិះខុស

៣- មិច្ឆាវាចា សំដីខុស

៤-មិច្ឆាកម្មន្តៈ ការងារខុស

៥- មិច្ឆាអាជីវៈ ចិញ្ចឹមជីវិតខុស

៦- មិច្ឆាវាយាមៈ ព្យាយាមខុស

៧- មិច្ឆាសតិ រលឹកខុស

៨- មិច្ឆាសមាធិ ដំកល់ចិត្តខុស

៩- មិច្ឆាវិមុត្តិ ផុតខុស

១០- មិច្ឆាញាណ ដឹងខុស ។

លោកធម៌៨នោះគឺ ៖

| | |
|---|---|
| ១-លាភោ | បានលាភ |
| ២-អលាភោ | មិនបានលាភ |
| ៣-យសោ | បានយស |
| ៤-អយសោ | មិនបានយស |
| ៥-សុខំ | បានសុខ |
| ៦-ទុក្ខំ | បានទុក្ខ |
| ៧-និន្ទា | តិះដៀល |
| ៨-បសំសា | សរសើរ ។ |

មច្ឆិរិយៈ៥នោះគឺ ៖

| | |
|---|---|
| ១-អាវាសមច្ឆរិយៈ | កំណាញ់អាវាស (ឬទីលំនៅ) |
| ២-កុលមច្ឆរិយៈ | កំណាញ់ត្រកូល |
| ៣-លាភមច្ឆរិយៈ | កំណាញ់លាភ |
| ៤-វណ្ណមច្ឆរិយៈ | កំណាញ់ពណ៌សម្បុរ (ឬកំណាញ់គុណ) |
| ៥-ធម្មមច្ឆរិយៈ | កំណាញ់ធម៌ ។ |

## គន្ថៈ៤នោះគឺ ៖

១-អភិជ្ឈាកាយគន្ថៈ ចំណងកាយគឺអភិជ្ឈា

២-ព្យាបាទកាយគន្ថៈ ចំណងកាយគឺព្យាបាទ

៣-សីលព្វតបរាមាសកាយគន្ថៈ ចំណងកាយគឺសីលព្វតបរាមាសៈ

៤-ឥទំសច្ចាភិនិវេសកាយគន្ថៈ ចំណងកាយគឺសេចក្តីសំគាល់ថារបស់នេះពិត ។

## វិបល្លាស៣នោះគឺ

១-សញ្ញាវិបល្លាស សំគាល់ខុស គឺយល់ថាខន្ធ៥ដែលជារបស់មិនទៀង សំគាល់ថាទៀង ទុក្ខសំគាល់ថាសុខ មិនមែនខ្លួនសំគាល់ ថាខ្លួន

២-ចិត្តវិបល្លាស ត្រិះរិះខុស

៣-ទិដ្ឋិវិបល្លាស យល់ខុស ។

## អគតិ៤នោះគឺ ៖

១-ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់

២-ទោសាគតិ លំអៀងព្រោះស្អប់

៣-មោហាគតិ លំអៀងព្រោះមិនដឹង

៤-ភយាគតិ លំអៀងព្រោះភ័យខ្លាច ។

## អាសវៈ៤នោះគឺ ៖

១-កាមាសវៈ តម្រាំគឺកាម

២-ភវាសវៈ តម្រាំគឺភព

៣-ទិដ្ឋាសវៈ តម្រាំគឺទិដ្ឋិ ការយល់ខុស

៤-អវិជ្ជាសវៈ តម្រាំគឺអវិជ្ជា សេចក្តីល្ងង់ ។

## ឱឃៈ៤នោះគឺ ៖

១-កាមោឃៈ អន្លង់គឺកាម

២-ភវោឃៈ អន្លងគឺភព

៣-ទិដ្ឋោឃៈ អន្លង់គឺទិដ្ឋិ

៤-អវិជ្ជោឃៈ អន្លង់គឺអវិជ្ជា ។

## នីវរណៈ៥នោះគឺ ៖

១-កាមច្ឆន្ទៈ សេចក្តីប្រាថ្នាក្នុងកាម

២-ព្យាបាទៈ សេចក្តីគំនុំគំគួន

៣-ថីនមិទ្ធៈ សេចក្តីរួញរា

៤-ឧទ្ធច្ចៈ ចិត្តអណ្តែតអណ្តូង

៥-វិចិកិច្ឆា សេចក្តីសង្ស័យមិនដាច់ស្រេច ។

ឧបាទាន៤នោះគឺ

| | |
|---|---|
| ១-កាមុបាទាន | ការប្រកាន់ខ្ជាប់ក្នុងកាម |
| ២-សីលព្វតុបាទាន | ការប្រកាន់ខ្ជាប់ក្នុងសីលវត្ត |
| ៣-អត្តវាទុបាទាន | ការប្រកាន់ខ្ជាប់ក្នុងខ្លួនប្រាណ |
| ៤-ទិដ្ឋុបាទាន | ការប្រកាន់ខ្ជាប់ក្នុងការយល់ឃើញ ។ |

បរាមាសៈ១គឺ មិច្ឆាទិដ្ឋិ ។

អនុសយៈ៧នោះគឺ ៖

១-កាមរាគានុសយៈ

២-ភវរាគានុសយៈ

៣-បដិឃានុសយៈ

៤-មានានុសយៈ

៥-ទិដ្ឋានុសយៈ

៦-វិចិកិច្ឆានុសយៈ

៧-អវិជ្ជានុសយៈ ។

អនុសយៈទាំង៧នេះជាកិលេសដេកត្រាំនៅរឿយៗក្នុងសន្តានរបស់សត្វ ។

មូលៈ ៣នោះគឺ ៖

១-លោភៈ ២-ទោសៈ ៣-មោហៈ ។

អកុសលកម្មបថ១០នោះគឺ ៖

កាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ ត្រូវជា១០ ។

អកុសលចិត្តុប្បាទ១២នោះគឺ

លោភមូល៨ ទោសមូល២ មោហមូល២ ត្រូវជា១២ ។

ភ្លើងកិលេសដែលកើតឡើងតៗគ្នាដូច្នេះនេះ គឺមកតែអំពីអវិជ្ជា និងសង្ខារជាបច្ច័យឲ្យកើតឡើង នៅក្នុងបដិច្ចសមុប្បាទដដែល ។

នែសញ្ញា និងវិញ្ញាណ ! អ្នកឃើញភ្លើងកិលេសហើយឬនៅ? សាធុ សាធុ ប្រពៃហើយ! ប្រពៃហើយ! ខ្ញុំទាំងពីរនាក់ឃើញច្បាស់ណាស់ហើយ ថាភ្លើងកិលេសទាំងអស់នេះប្រជុំចូលក្នុង បដិច្ចស-មុប្បាទធម៌ទាំង១២ពិតមែន ហើយធម៌ទាំងនេះបង្វិលឲ្យវិលទៅកាន់នាវាត្រៃលោក ហើយក៏នាំចូលទៅកាន់អាកាសធាតុ គឺជារបស់សោះសូន្យទទេៗ រកប្រយោជន៍គ្មាន ស្លាប់ទៅទទេៗ មានតែភ្លើងទុក្ខ និងភ្លើងកិលេស ជាប់តាមទៅជាមួយផង ដល់ត្រឡប់មកកើតវិញ ក៏មកទទេៗ មានតែភ្លើងទុក្ខនិងភ្លើងកិលេសតាមមកជាមួយផង ។ ខ្ញុំទាំងពីរនាក់ឃើញច្បាស់ថា នាវាត្រៃលោកដែលប្រដាប់ដោយធម៌ ១៦គឺ បដិច្ចសមុប្បាទ១២ ត្រៃលោក៣ អាកាសធាតុ១ ។ ធម៌ទាំង១៦ នេះពិតជាប្រកបទៅដោយភ្លើងទុក្ខនិងភ្លើងកិលេស ដុតបំផ្លាញរូប ដុត

បំផ្លាញនាមឲ្យរលាយទៅជាអាកាសទទេៗ ។ ឯភ្លើងទុក្ខទាំង៩ភ្នក់នេះ សម្រាប់ដុតបំផ្លាញរូបទាំង ២៨ ឲ្យរលាយសោះសូន្យទៅទទេៗ ។ ចំណែកភ្លើងកិលេសទាំង១៥០០នេះ សម្រាប់ដុតបំផ្លាញពួកនាមទាំង៤គឺ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១ ឲ្យរលាយសោះសូន្យទៅ ហើយបំភ្លៃកំណើតឲ្យក្លាយទៅកើតជាប្រេត -នរក -តិរច្ឆាន -អសុរកាយ សោយនូវសេចក្ដីទុក្ខវេទនា រកទីបំផុតគ្មាន ។

សត្វទាំងអស់វិលកើតវិលស្លាប់រាប់មិនអស់ នៅក្នុងភពតូច និងភពធំ ហេតុមកតែអំពីអវិជ្ជាខ្ទប់មុខ ឲ្យងងឹតងងល់ងប់ដូចយប់ ដូចមនុស្សខ្វាក់លលើធ្វើលលាក់ ដូចអន្ទាក់ឆ្វាក់រឹតក អូសទាញដឹកនាំឲ្យនៅតែក្នុងនាវាត្រៃលោក ច្រើនមីរដេរដាសកកកុញណែនណាន់តាន់តាប់ ចង្អៀតដូចជាអង្ករនៅក្នុងនាឡិ ឬដូចជាស្និតចេកត្រារាប់ពុំអស់ នូវមនុស្សសត្វដែលជិះនៅលើនាវាត្រៃលោក ហើយបើកទៅតាមប្រឡាយទឹកដែលហូរត្របាញ់ គឺតណ្ហា ឆ្ពោះទៅកាន់ភពតូចនិងភពធំនោះឯង ។ ខ្ញុំទាំងពីរនាក់ឃើញច្បាស់ណាស់ព្រះអង្គ ថាមនុស្សសត្វទាំងអស់នេះ ស្ម័គ្រចិត្តជិះតែនាវាត្រៃលោកច្រើនរាប់មិនអស់ ។ ឯនាវាត្រៃលក្ខណ៍វិញ នៅចតចោលទទេ ឥតមានមនុស្សឬសត្វណាជិះសោះឡើយ មែនឬមិនមែនព្រះអង្គ?

អើ! មែនហើយ សញ្ញា វិញ្ញាណ អ្នកឃើញយ៉ាងហ្នឹងត្រូវហើយ ព្រោះមានច្បាប់ថា ត្រៃលោកគោកត្រៃលក្ខណ៍សង្សារចក្រវិលមិនដល់ អវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ នាំសត្វឲ្យសោកសៅ លិចលង់ទៅក្នុងជលសារ បញ្ចមារមោហន្ធការ រឹតរុំហ៊ុំជុំជាប់នៅ ។

នៃសញ្ញា វិញ្ញាណ! មារទាំង៥នោះគឺ កិលេសមារ១ ខន្ធមារ១ អភិសង្ខារមារ១ មច្ចុមារ១ ទេវបុត្តមារ១ មារទាំង៥នេះ មានខ្សែ៥ សម្រាប់ចងមនុស្សសត្វ រឹតរុំហ៊ុំឲ្យជាប់នៅតែក្នុងនាវាត្រៃលោក បានជានាវាត្រៃលក្ខណ៍នេះនៅទំនេរ ។

សញ្ញា វិញ្ញាណ សួរទៅបញ្ញាថា កាលពីដើមខ្ញុំបានធ្វើទាន សីល ភាវនាណាស់ដែរ តើខ្ញុំបាននៅក្នុងនាវាត្រៃលក្ខណ៍ដែរឬទេ?

បញ្ញាសួរទៅសញ្ញា វិញ្ញាណវិញថា កាលអ្នកធ្វើ ទាន សីល ភាវនានោះ តើអ្នកសំគាល់ឃើញដូចម្តេចបានជាអ្នកធ្វើ?

ខ្ញុំសំគាល់ឃើញដូច្នេះថា ធ្វើទានឲ្យបានផលមានភោគសម្បត្តិ ធ្វើសីលឲ្យបានផលមានអាយុវែងរូបល្អ ចំរើនភាវនា ឲ្យបានផលមានបញ្ញា និងបានសេចក្តីសុខច្រើន ខ្ញុំសំគាល់ឃើញដូច្នេះហើយក៏ខំធ្វើទាន សីល ភាវនាទៅ ។

បញ្ញាថា បើអ្នកសំគាល់ឃើញដូច្នោះ ហើយខំធ្វើទាន សីល ភាវនាយ៉ាងនេះ មិនបានចូលក្នុងនាវាត្រៃលក្ខណ៍ជាដាច់ខាត បានជាថា មិនបានចូលក្នុងនាវាត្រៃលក្ខណ៍នោះ ព្រោះថាអ្នកសំគាល់យក ត្រៃ-លោកមកជាអារម្មណ៍ ហៅថាលោកាធិបតេយ្យ អត្តាធិបតេយ្យ ។ ទាន សីល ភាវនា របស់អ្នកនេះ ចាត់ចូលទៅក្នុងនាវាត្រៃលោកទាំងអស់ ។

បើទាន សីល ភាវនារបស់អ្នក កាន់យកធម្មាធិបតេយ្យ ជាអារម្មណ៍នោះ ទើបចាត់ចូលទៅក្នុងនាវាត្រៃលក្ខណ៍ទាំងអស់ ។

សញ្ញា វិញ្ញាណថា ទាន សីល ភាវនាដែលខ្ញុំបានធ្វើទាំងអស់ មិនចាត់ចូលទៅក្នុងនាវាត្រៃលក្ខណ៍ ខ្ញុំក៏យល់ព្រមហើយ ពិតជានៅក្នុងនាវាត្រៃលោកប្រាកដមែន ចុះចំណែកផលបុណ្យបានឬមិនបាន?

បញ្ញាថា សេចក្តីត្រង់នេះអ្នកចាំស្តាប់អភិធម្មសំដែងថា សោមនស្ស សហគត ញាណសម្បយុត្ត កុសលចិត្តកើតឡើងប្រកបដោយសោមនស្សវេទនា ប្រកបដោយញាណជាគ្រឿងដឹង បើមានញាណទើបធ្វើទាន សីល ភាវនា កាន់យកធម្មាធិបតេយ្យជាអារម្មណ៍បាន ។ កុសលចិត្តដែលកើតឡើងក្នុងនាវាត្រៃលក្ខណ៍ បើគ្មានញាណទេ ហើយធ្វើទាន សីល ភាវនា ប្រើតែវិញ្ញាណនោះ កាន់យកបានតែលោកាធិបតេយ្យ និងអត្តាធិបតេយ្យ ជាអារម្មណ៍ប៉ុណ្ណោះ ជាប់នៅក្នុងនាវាត្រៃលោកទាំងអស់ ។ សោមនស្ស សហគត ទិដ្ឋិគតសម្បយុត្ត លោភចិត្តកើតឡើងប្រកបដោយសោមនស្សវេទនា និងព្រមដោយទិដ្ឋិទាំង២ប្រការគឺ សស្សតទិដ្ឋិ១ ឧច្ឆេទទិដ្ឋិ១ ។

បើធ្វើទានប្រកបដោយសោមនស្ស ព្រមដោយទិដ្ឋិដែលយល់ឃើញថា អនាគតទៅខាងមុខ នឹងមានភោគសម្បត្តិច្រើន ឃើញដូច្នោះហើយចិត្តក៏ត្រេកអរជាប់ចិត្តនឹងសម្បត្តិ ហើយក៏ប្រាថ្នាថាឲ្យបានសម្បត្តិ៣គឺ សម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ។ ចំណែកឯអ្នកដែលទទួលយកទាននោះ ក៏ឲ្យពរថា ឲ្យអ្នកបានសម្រេច ដូចសេចក្តីប្រាថ្នារបស់អ្នកចុះ ។ ចំណែកអ្នកម្ចាស់ទាន ក៏កើតលោភមូលសោមនស្ស ជាទិដ្ឋិសម្បយុត្តរឹតតែខ្លាំងឡើងៗ ត្រង់ដែលយល់ឃើញថា ធ្វើទានបានសម្បត្តិច្រើននេះ ជាតួ សស្សតទិដ្ឋិ ។ ត្រង់ចិត្តដែលជាប់នឹងសម្បត្តិ ប្រកាន់ឲ្យតែមានៗ ឲ្យតែនៅៗ នេះជាតួ ភវតណ្ហា ។

ត្រេកអរនឹងរបស់មាន ត្រេកអរនឹងរបស់នៅ នេះជាតួ កាមតណ្ហា ។ បើមិនចង់ឲ្យរបស់នោះវិនាសព្រាត់ប្រាសទៅ នេះជាតួ វិភវតណ្ហា ។ វិភវតណ្ហានេះប្រកបដោយ ឧច្ឆេទទិដ្ឋិ ។ នៃសញ្ញា វិញ្ញាណ! អ្នកស្ដាប់ហើយវិនិច្ឆ័យដោយខ្លួនឯងចុះរឿងទាននេះ ។

ខ្ញុំទាំងពីរនាក់ស្ដាប់បានជាក់ច្បាស់ណាស់ ថាធ្វើទានប្រកបដោយញាណសម្បយុត្ត ទើបបានមហាកុសល៨ ខ្ញុំដឹងច្បាស់ថា ខ្ញុំជាបុថុជ្ជនគ្មានញាណសម្បយុត្តទេ ព្រោះញាណសម្បយុត្តនោះ មានពីត្រឹមព្រះសោតាបន្នបុគ្គលឡើងទៅ ម្ល៉ោះហើយបានជាខ្ញុំធ្វើទាន តាំងពីដើមរៀងរាបមក មានតែលោភមូលជា ទិដ្ឋិសម្បយុត្ត ធ្វើទានប្រាថ្នាចង់ឲ្យបានតែផលបុណ្យ គឺ ឲ្យបានតែទ្រព្យច្រើនប៉ុណ្ណោះ ។ ខ្ញុំទាំងពីរនាក់នេះយល់ឃើញថា ខុសឆ្ងាយអំពីព្រះពុទ្ធសាសនា គ្មានឆិតគ្មានជ្រិះសោះ ។ ខ្ញុំខុសណាស់ព្រះអង្គបញ្ញា ហើយខ្លួនខ្ញុំមិនដឹងជាខុសផង ឥឡូវនេះខ្ញុំបានភ្លឺណាស់ហើយព្រះអង្គ ខ្ញុំលែងវង្វេងទៀតហើយ ។ សញ្ញា វិញ្ញាណថា ខុសម្លឹងៗ ហើយមិនដឹងជាខុសផងធ្វើទានម្ដងៗលោភៈតណ្ហារឹតតែច្រើនឡើង ម្ល៉ោះហើយផលលោភៈផលតណ្ហាឲ្យមកបានតែក្ររៗ តែខ្វះៗ នេះជាផលរបស់លោភៈនិងតណ្ហាហុចផលឲ្យយ៉ាងនេះឯង ។ ខ្ញុំទាំងពីរនាក់នេះខុសណាស់ព្រះអង្គកាលខ្ញុំទៅរកស៊ីធ្វើការងារអ្វីៗ ក៏យកលោភៈ តណ្ហានិងទិដ្ឋិទៅធ្វើទៅរកដល់ខ្ញុំទៅធ្វើទាន ក៏យកលោភៈ តណ្ហា និងទិដ្ឋិទៅធ្វើទានទៀត ម្ល៉ោះហើយផលហុចឲ្យមកបានតែទុក្ខ បានតែខុស បានតែក្រ បានតែខ្វះ

នេះខ្លួនខ្ញុំវិនិច្ឆ័យអំពីទានដោយខ្លួនឯង ឥតមានសេចក្ដីសង្ស័យទេ ពិតជានៅក្នុងនាវាត្រៃលោកប្រាកដណាស់ព្រះអង្គ ។

**ចុះធ្វើទានដូចម្ដេច ទើបបានទៅនៅក្នុងនាវាត្រៃលក្ខណ៍?**

អើសញ្ញា វិញ្ញាណ! អ្នកចាំស្ដាប់ចុះ ធ្វើទានប្រកបដោយ សោមនស្សសហគតញាណសម្បយុត្ត ទើបបានទៅនៅក្នុងនាវាត្រៃលក្ខណ៍ ។ ចុះញាណសម្បយុត្តនោះតើដូចម្ដេច? ញាណសម្បយុត្តនោះ គឺ មគ្គញាណ ញាណដែលត្រាស់ដឹងច្បាស់ នូវភ្លើងទុក្ខនិងភ្លើងកិលេស ក្នុងខន្ធទាំង៥ ដឹងច្បាស់នូវភ្លើងទុក្ខនិងភ្លើងកិលេស ក្នុងកាមគុណទាំង៥ ញាណដែលដឹងច្បាស់នូវទុក្ខ ហើយចិត្តនៅសម្បយុត្តជាប់នឹង អនិច្ចំ ទុក្ខំ អនត្តា ដូច្នេះឈ្មោះថាញាណ ។ ញាណនេះឯងហើយ ដែលធ្វើទានបានមហាកុសល៨នោះ ។ កាលដែលខ្ញុំធ្វើទាន នោះ មានចិត្តសោមនស្សចំពោះបុគ្គលដែលគួរឲ្យទាន មុននឹងឲ្យទាននោះ មានញាណជាគ្រឿងដឹងថា ឲ្យទាននេះរំលត់តែភ្លើងគឺលោភៈ តណ្ហា និងឧបាទានឲ្យអស់តែប៉ុណ្ណោះ មិនមានចិត្តប្រាថ្នាអ្វីអំពីទាននោះឡើយ គឺមានចិត្តត្រេកអរចំពោះតែត្រង់បានធ្វើទាននេះ១ ត្រេកអរចំពោះបុគ្គលដែលបានទទួលទាននេះ១ ។ បើធ្វើទានម្ដងៗ លោភៈ តណ្ហា និងឧបាទានក៏រលត់អស់ បើរលត់អស់ហើយ មហាកុសល៨ ក៏កើតឡើងពេញនៅក្នុងចិត្តឥតខ្វះខាត ។ បើធ្វើទានម្ដងៗ លោភៈ តណ្ហា ប្រាថ្នា ចង់បានបុណ្យចង់បានសម្បត្តិ ចង់បានលាភ យស សរសើរ ចង់បានសុខ ចង់បានអាយុវែង ចង់បានរូបល្អ ចំណង់ចង់បាននេះ ហៅថា លោភៈ តណ្ហា កើតមកអំពីសស្សតទិដ្ឋិ កាន់យកលោកាធិបតេយ្យ និងអត្តាធិបតេយ្យជាអារម្មណ៍ ទាននេះឈ្មោះថា កាមសុខល្លិកាទាន

រាប់ចូលក្នុងនាវាត្រៃលោកទាំងអស់ ។ ពាក្យបូរាណមួយឃ្លាបានពោល ថា **បើឲ្យទានឲ្យៗស្មោះ កុំអាឡោះអាល័យស្ងួន ទ្រព្យនេះនឹងនាំខ្លួន ទៅបរលោកពុំសោះសូន្យ** ។ អ្នកដែលឲ្យទានស្មោះនោះ គឺឲ្យទានទៅ ហើយ មិនប្រាថ្នា មិនទារយកបុណ្យ មិនទារយកសម្បត្តិ មិនទារ យកសុខ សរសើរ លាភ យស មិនទារយកអាយុវែង មិនប្រាថ្នារូបល្អ ចិត្តមិនមានអាឡោះអាល័យក្នុងការដែលបានឲ្យទានហើយនោះ គឺមាន ចិត្តស្ងប់រម្ងាប់ប្រាសចាកលោភៈ តណ្ហា ទិដ្ឋិ និង ឧបាទានស្រឡះ ។ តួចិត្តដែលស្ងប់រម្ងាប់នេះហើយជាតួមហាកុសល៨។ បើឲ្យទានស្មោះ អស់លោភៈ តណ្ហា ទិដ្ឋិ និង ឧបាទាន ដូចបានពោលមកនេះ បុណ្យនោះ ច្រើនជាអនេករាប់មិនអស់ ពីព្រោះលោភៈ តណ្ហា ទិដ្ឋិ នេះជាតួ អកុសល បើអស់លោភៈ តណ្ហា ទិដ្ឋិហើយ ចិត្តនោះជាតួមហាកុសល ទាំងអស់ ។ ទានដែលឲ្យស្មោះនេះ ព្រោះកាន់យក ធម្មាធិបតេយ្យ ជាអារម្មណ៍ ហៅថា **មជ្ឈិមាបដិបទាទាន** រាប់បញ្ចូលទៅក្នុង នាវាព្រះត្រៃលក្ខណ៍ ។ សញ្ញាថា ខ្ញុំចេះអភិធម្មដែរ វិញ្ញាណថាខ្ញុំចេះដែរ ចុះហេតុដូចម្ដេច ក៏បានទៅជាធ្វើទានម្ដងៗប្រកប ដោយលោភមូល ជាទិដ្ឋិសម្បយុត្តដូច្នេះ ហើយមិនដឹងខុសផង ។ វិញ្ញាណថា យើងធ្លាប់ បានធ្វើពីដើមរៀងរាបមកក៏ច្រើនណាស់ដែរ ហើយទើបនឹងមកដឹងខុស ត្រូវក្នុងថ្ងៃនេះ ។ សញ្ញាថា យើងទាំងពីរនាក់នេះខុសហើយ បានជាថា ខុសហើយនោះ ព្រោះលោភៈ តណ្ហា និង សស្សតទិដ្ឋិ កើតឡើងព្រមគ្នា ក្នុងកាលដែលយើងធ្វើទានម្ដងៗនោះ កាន់យកតែលោកាធិបតេយ្យ និង អត្តាធិបតេយ្យជាអារម្មណ៍ ហើយធ្វើទានទៅ លោភចិត្តកើតឡើងហើយ ចង់បានបុណ្យ ចង់បានទ្រព្យសម្បត្តិច្រើន ចង់បានជាទេវតា ជាព្រះឥន្ទ្រ

ចង់បានអាយុវែង ចង់បាន លាភយស ចង់បានសុខសរសើរ ចង់បានរូបល្អ ។ ត្រង់ដែលចិត្តជាប់ នឹងសម្បត្តិ នឹងវត្ថុទាំងអស់ដូចជាខាងលើនេះ ហៅថាលោភចិត្ត ។ ត្រង់ដែលយល់ឃើញថា បានបុណ្យមកស្រួល បានសម្បត្តិមកស្រួល បានយសមកស្រួល យល់ឃើញដូច្នេះ ហៅថា សស្សតទិដ្ឋិ ។ បើចិត្តត្រេកអរតែនឹងវត្ថុដូចមានខាងលើនេះទាំងអស់ តួចិត្តដែលត្រេកអរនោះហៅថា កាមតណ្ហា ។ បើចិត្តប្រកាន់ខ្ជាប់នូវវត្ថុទាំងអស់នោះ ឲ្យតែនៅៗ ទៀងៗ តួចិត្តនោះហៅថា ភវតណ្ហា ។ បើចិត្តមិនចង់ឲ្យវត្ថុទាំងអស់នោះវិនាសព្រាត់ប្រាសបាត់បង់ទៅ តួចិត្តដែលមិនចង់នោះហៅថា វិភវតណ្ហា ។ បើចិត្តកាន់យកនូវវត្ថុដូចមាននៅខាងលើនេះ ណាមួយមកជាអារម្មណ៍ ហើយធ្វើទានទៅ ទាននោះហៅថា លោកាធិបតេយ្យទាន និង អត្តាធិបតេយ្យទាន ។ នេះរាប់បញ្ចូល ទៅក្នុងនាវាត្រៃលោកទាំងអស់ ។ មានរឿងមួយសម្តែងថា នាកាល ព្រះពុទ្ធសករាជបានណ ២១៨ឆ្នាំ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមធម្មាសោក ក្នុងកាលនោះ ព្រះអង្គបានកសាងព្រះចេតិយចំនួន ៨ម៉ឺន៤ពាន់ ឃើញថាធ្វើទាននោះច្រើនជាអនេក តែកាន់យក អត្តាធិបតេយ្យជាអារម្មណ៍ ហើយខំកសាងទៅ ។ លុះកសាងរួចស្រេចហើយ ទើបចូលទៅក្រាបទូលសួរព្រះមោគ្គលីបុត្តថា ខ្ញុំព្រះករុណាម្ចាស់កសាងនេះតើនឹងបានទៅជាអ្វី? ព្រះមោគ្គលីបុត្តតបថា ទានដែលមហារាជធ្វើទាំងអស់នេះ ជាទានក្រៅព្រះពុទ្ធសាសនា គ្មានចូលក្នុងព្រះពុទ្ធសាសនាទេ ។ បញ្ញាសួរទៅវិញ្ញាណថា នាវាត្រៃលោកតើនាំសត្វ

ទៅឯណា? វិញ្ញាណឆ្លើយថា នាវាត្រៃលោកនាំសត្វទៅកាន់សេចក្ដីវិនាសព្រាត់ប្រាសសោះសូន្យទទេៗ ។ អើវិញ្ញាណ! អ្នកឆ្លើយហ្នឹងត្រូវហើយ ព្រោះថាសត្វទាំងអស់នេះមានកម្មជាគោល បើធ្វើកម្មនោះយ៉ាងណា តែងហុចផលឲ្យមកយ៉ាងនោះ មិនដែលឲ្យផលមកខុសគោលដើមទេ ។ ឥឡូវនេះយើងធ្វើទានម្ដងៗ យកតែគ្រឿងវិនាសមកជាអារម្មណ៍ហើយឲ្យទានទៅ បានជាផលមក បានតែវិនាសព្រាត់ប្រាសសោះសូន្យទទេៗ ។ បើធ្វើទានកាន់យកលោកាធិបតេយ្យនិងអត្តាធិបតេយ្យជាអារម្មណ៍ ទាននោះហៅថាកាមសុខល្លិកាទានរាប់បញ្ចូលទៅក្នុងនាវាត្រៃលោកទាំងអស់ ។ បើធ្វើទាន កាន់យកធម្មាធិបតេយ្យជាអារម្មណ៍ ទាននោះហៅថា **មជ្ឈិមាបដិបទាទាន** ។ មជ្ឈិមាបដិបទាទាននេះរាប់បញ្ចូលទៅក្នុងនាវាត្រៃលក្ខណ៍ ។ ដែលធ្វើទានកាន់យកលោកាធិបតេយ្យ និង អត្តាធិបតេយ្យ ជាអារម្មណ៍នោះមានគ្រប់សាសនា វៀរលែងតែព្រះពុទ្ធសាសនា ។ ព្រហ្មញ្ញសាសនាគ្រិស្តសាសនា និងឥស្លាមសាសនា ទាំង៣នេះគេប្រដៅឲ្យធ្វើទានហើយគេនាំគ្នាប្រាថ្នាថា ឲ្យមានសម្បត្តិ ឲ្យបានបុណ្យ បានសក្តិយសឲ្យបានខ្ពង់ខ្ពស់ឲ្យបានកើតទៅជាទេវតា ជាព្រះឥន្ទ្រ ជាព្រះព្រហ្មឲ្យបានស្មើរៗគ្នាទៅហោង គេនាំគ្នាសោមនស្សត្រេកអរថា សាធុៗ ៣ដង គេសន្មតថាបានបុណ្យ ។

ចំណែកព្រះពុទ្ធសាសនា មិនប្រដៅឲ្យធ្វើទាន សីល ភាវនា ដូច្នេះទេ គឺព្រះអង្គទ្រង់ប្រដៅឲ្យធ្វើទានដើម្បីរំលត់នូវភ្លើងទុក្ខគឺ លោភៈ១ ឲ្យធ្វើសីលដើម្បីរំលត់នូវភ្លើងទុក្ខគឺទោសៈ១ ឲ្យធ្វើភាវនា ដើម្បីរំលត់នូវភ្លើងទុក្ខគឺមោហៈ១ នេះព្រះពុទ្ធសាសនាទ្រង់ទូន្មាន ឲ្យចេះធ្វើទានដើម្បី

រំលត់ទុក្ខ ឲ្យចេះធ្វើសីលដើម្បីរំលត់ទុក្ខ ឲ្យចេះធ្វើភាវនាដើម្បីរំលត់ទុក្ខដូច្នេះ ។ បើកាន់យក មិនទៀង-ទុក្ខ មកជាអារម្មណ៍ ហើយធ្វើទាន-សីល-ភាវនា យ៉ាងនេះហៅថា ធម្មាធិបតេយ្យ គឺធ្វើទាន កាន់យកធម៌ជាធំ ។ បើធ្វើទានកាន់យកធម៌ជាធំ ទើបបានមហាកុសល៨ ទាននោះហៅថា មជ្ឈិមាបដិបទាទាន រាប់ចូលក្នុងនាវាត្រៃលក្ខណ៍ ។ នែសញ្ញា និងវិញ្ញាណ! អ្នកស្តាប់ចូលចិត្តច្បាស់ហើយឬនៅទេ? សាធុៗ ប្រពៃណាស់ៗ ខ្ញុំទាំងពីរនាក់នេះ ដាច់ចាកការសង្ស័យអស់ហើយលោកម្ចាស់ ខ្ញុំឃើញច្បាស់ភ្លឺច្បាស់ណាស់ ថាបើនឹងធ្វើទាន ត្រូវប្រារព្ធយក អនិច្ចំ ទុក្ខំ អនត្តា មកជាអារម្មណ៍ នេះហៅថាធម្មាធិបតេយ្យ យកធម៌ជាធំ តាមឱវាទដែលព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មាននោះ ពិតប្រាកដមែន ព្រោះញាណសម្បយុត្តជាប់នៅក្នុងចិត្ត ឃើញច្បាស់នូវធម៌ ទុក្ខ មិនទៀង អនត្តា ហើយមានសទ្ធាជ្រះថ្លា បរិច្ចាគទ្រព្យសម្បត្តិ ធ្វើទានចំពោះបុគ្គលដែលគួរឲ្យ ញ៉ាំងមហាកុសល៨ឲ្យកើតឡើង ឥតអាក់ ហើយបានសម្រេចជាព្រះសោតាបត្តិមគ្គញាណ លះបង់នូវ លោភមូលជាទិដ្ឋិសម្បយុត្ត៤ គឺ លោភមូលជាសោមនស្សទិដ្ឋិសម្បយុត្ត៤ លោភមូលជាឧបេក្ខាទិដ្ឋិសម្បយុត្ត២ លះបង់នូវសក្កាយទិដ្ឋិ២០ លះបង់នូវវិចិកិច្ឆា១៦ លះបង់នូវសីលព្វតបរាមាសៈដាច់ស្រឡះ ឥតមានសង្ស័យក្នុងជីវិត ។ លែងទៅកាន់អបាយភូមិ ព្រោះលះដាច់លោភចិត្តជាទិដ្ឋិសម្បយុត្ត៤ ហើយចិត្តក៏សម្បយុត្តទៅលើមគ្គនិងផល ។

អើសញ្ញា វិញ្ញាណ! ធម្មចក្ខុញាណ ករណីញាណ កើតឡើងហើយដល់ភ្នែករបស់អ្នក អ្នកឃើញធម៌ច្បាស់ទៅតាមសភាវធម៌ពិតៗ ឥតមានឃ្លាតឡើយ ។ បើធ្វើទាន ស្តាប់ធម៌ ធ្វើអ្វីៗក៏ដោយ បើមិនកាន់យក

ធម្មាធិបតេយ្យជាអារម្មណ៍ទេ ក៏មិនអាចញ៉ាំងមហាកុសល៨ ឲ្យកើតឡើងបានឡើយ លោកុត្តរៈ មគ្គ ផល ព្រះនិព្វាន ក៏មិនអាចកើតឡើងបានដែរ ។ មហាកុសល៨នេះជាធម៌អាចញ៉ាំងលោកុត្តរៈ ឲ្យកើតឡើងបាន សម្រេចជាសោតា-សកទា-អនាគា-អរហត្ត នោះក៏មកតែអំពី មហាកុសលជាលោកិយនេះឲ្យសម្រេចទៅជាលោកុត្តរៈបាន ។ តែមហាកុសលទាំង៨នេះ ចែកចេញជាពីរយ៉ាងគឺ កុសលប្រកបដោយញាណសម្បយុត្តម៉្យាង កុសលប្រកបដោយញាណវិប្បយុត្តម៉្យាង ។ ឯមហាកុសលដែលប្រកបដោយញាណសម្បយុត្តនោះ មានកម្លាំង៥យ៉ាងកើតឡើងគឺសទ្ធា សតិ វិរិយៈ សមាធិ បញ្ញា មានកម្លាំងពេញបរិបូណ៌ហើយ អាចញ៉ាំងលោកុត្តរកុសលឲ្យកើតឡើង កំចាត់បង់នូវអាសវធម៌ឲ្យដាច់ជាសមុច្ឆេទប្បហាន តាមជាន់ថ្នាក់ដែលបានសម្រេចជាសោតា-បន្នក្តី ជាសកទាគាមិក្តី ជាអនាគាមិក្តី ជាអរហត្តក្តី ។ ជួនកាលក៏សម្រេចដល់អរហត្តតែម្តងក៏មាន ដោយអំណាចកម្លាំងឥន្ទ្រីយទាំង៥ កំចាត់បង់នូវសំយោជនៈ៥ខាងក្រោមអស់ ដោយសមុច្ឆេទប្បហាន ។

ចំណែកមហាកុសលដែលប្រកបដោយញាណវិប្បយុត្ត មិនអាចញ៉ាំងឲ្យលោកុត្តរៈកើតបានឡើយ ព្រោះកុសលនេះមិនប្រកបដោយញាណ មិនមានឥន្ទ្រីយជាកម្លាំង ។ ក្នុងមហាកុសល៨នេះ មានកុសលដែលប្រាសចាកញាណនោះ៤គឺ ខាងសោមនស្សញាណវិប្បយុត្ត២ ខាងឧបេក្ខាញាណវិប្បយុត្ត២ ត្រូវជា៤ ។ កុសលទាំង៤នេះមិនឆ្លងទៅលោកុត្តរៈបានឡើយ ។ ព្រោះថាមហាកុសលទាំង៨នេះ កើតឡើងក្នុងសន្តានបុថុជ្ជន និងសេក្ខបុគ្គលតាំងពីសោតាបត្តិមគ្គ ដល់អរហត្តមគ្គអស់ត្រឹមប៉ុណ្ណោះ ។ មិនទូទៅដល់អរហត្តផលទេ ព្រោះលោកឈប់

ធ្វើកម្មក្នុងទីកម្បាំងនោះអស់ហើយ ។ តែមហាកុសលដែលកើតឡើងក្នុងសន្តានសេក្ខបុគ្គលនោះ គ្រាន់តែផ្លាស់ឈ្មោះថា មគ្គ ផល ដូច្នេះវិញ ព្រោះថាមគ្គជាកុសល ផលជាវិបាកដូច្នេះ ។

សួរថា ចុះបើមហាកុសលនេះ កើតបានតែអំពីធ្វើទានឬក៏បានមកអំពីធ្វើអ្វីខ្លះ? តបថា កុសលនេះបានមកអំពីធ្វើទាន សីល ភាវនា និងស្តាប់ធម៌ ហើយធ្វើទិដ្ឋិឲ្យត្រង់ទៅតាមធម៌ កំចាត់បង់លោភៈ ទោសៈ មោហៈ ដែលកំពុងធ្វើទាន សីល ភាវនានោះឲ្យទៅជាសម្មាវិសុទ្ធ ។ ត្រង់បញ្ញាដែលបរិសុទ្ធហើយជាមហាកុសល កុសលនេះចែកចេញជា៣ ថ្នាក់គឺ ថ្នាក់ទី១ លះរាគៈ ទោសៈ មោហៈ ជាតទង្គប្បហាន ។ ទិដ្ឋិបរិសុទ្ធមួយពេលៗ ហៅថា កាមាវចរកុសល ។ ថ្នាក់ទី២ លះរាគៈ ទោសៈ មោហៈ ជា វិក្ខម្ភនប្បហាន ។ បញ្ញាបរិសុទ្ធបាននៅយូរៗ ហៅថា មហាកុសល ។ ថ្នាក់ទី៣ លះរាគៈ ទោសៈ មោហៈដាច់ស្រឡះ ហៅថា សមុច្ឆេទប្បហាន ។ មហាកុសលនោះបានឈ្មោះថា មគ្គជាកុសលវិញ ព្រោះចិត្តសម្បយុត្តជាប់នឹងមគ្គផល ។ វិញ្ញាណសួរថា បើកុសលនេះញុាំងលោកុត្តរៈ ឲ្យកើតឡើងបានហើយ ចាំបាច់ចំរើនកម្មដ្ឋាន ចូលកាន់ បឋមជ្ឈាន-ទុតិយជ្ឈាន-តតិយជ្ឈាន-ចតុត្ថជ្ឈានធ្វើអ្វីទៀត?

បញ្ញាឆ្លើយថា បើទុកជាចំរើនរូបសមាបត្តិ៤ក្តី អរូបសមាបត្តិ៤ក្តី ក៏គង់មកពិចារណាឲ្យកើតឡើងនូវមហាកុសលទាំង៨នេះដែរ ទើបចូលទៅកាន់លោកុត្តរៈបាន ។ ព្រោះហេតុអ្វី? ព្រោះថាឈានសមាបត្តិ

ទាំង៨នេះ ប្រាសចាកសម្មាទិដ្ឋិ និងសម្មាសង្កប្បោ បានជាថារូបាវចរ និងអរូបាវចរទាំងពីរនេះមិនបានឆ្លងទៅកាន់លោកុត្តរៈទេ ។

វិញ្ញាណសួរថា ហេតុដូចម្តេចបានជារូបាវចរកុសល និងអរូបាវចរកុសលប្រាសចាកបញ្ញា? ។ បានជាថាប្រាសចាកបញ្ញានោះ កាលដែលចូលកាន់ចតុត្ថជ្ឈានក្តី បញ្ចមជ្ឈានក្តី មានតែអង្គ២គឺ ឯកគ្គតា១ ឧបេក្ខា១ ចិត្តកាន់យកឯកគ្គតាជាអារម្មណ៍ខ្លះ យកឧបេក្ខាជាអារម្មណ៍ខ្លះ ហើយក៏ព្រងើយកន្តើយទៅ ព្រោះថាចិត្តដែលចូលកាន់ឈានទាំងអស់នោះ ឥតបានពិចារណាអ្វីកើតទេ ជាចិត្តដែលប្រកបដោយរូបាវចរវិបាក គឺថាចិត្តប្រាសចាកហេតុ មិនអាចនឹងពិចារណាខន្ធ៥នោះបានឡើយ បានជាថាប្រាសចាកសម្មាទិដ្ឋិនិងសម្មាសង្កប្បោ ។ បើអដ្ឋង្គិកមគ្គ មិនមានហើយលោកុត្តរៈក៏មិនមានដែរ ។

វិញ្ញាណសួរថា ចុះសម្មាទិដ្ឋិសេចក្តីបរិសុទ្ធនៃទិដ្ឋិនោះ តើដូច ម្តេច? បញ្ញាតបថា ទិដ្ឋិនោះមាន២គឺ មិច្ឆាទិដ្ឋិ១ សម្មាទិដ្ឋិ១ ។ ឯមិច្ឆាទិដ្ឋិនោះគឺ យល់ថាទៀងក្នុងរបស់ដែលមិនទៀង១ យល់ថាសុខ ក្នុងរបស់ដែលមានទុក្ខ១ យល់ថាខ្លួនអញក្នុងរបស់ដែលមិនមែនខ្លួនអញ១ យល់ថាស្អាតក្នុងរបស់ដែលមិនស្អាត១ យល់ថាស្រី-ប្រុសក្នុងអាការៈដែលគ្មានស្រី-ប្រុស១ គំនិតដែលយល់ខុសទាំងអស់នេះ មកអំពីអវិជ្ជានិងមោហៈ យល់តាមធម៌ ហីនោ គាមោ ជាធម៌ថោកទាប ជាធម៌របស់អ្នកនិគម មិនមែនជាធម៌របស់ព្រះពុទ្ធទេ ។ បើយល់ទៅតាមគំនិតទាំង៤យ៉ាងនេះ តែងឲ្យផលមកជាទុក្ខធ្ងន់ ទុក្ខហើយទុក្ខទៀតក្នុងភពទាំង៣ ព្រោះតែទិដ្ឋិយល់ផ្កាប់មុខ ធ្លាក់ទៅក្នុងអន្លង់ទាំង៤ គឺអន្លង់កាមោឃៈ១ ភវោឃៈ១ ទិដ្ឋោឃៈ១ អវិជ្ជោឃៈ១ ចិត្តដែលធ្លាក់ចុះ

ទៅក្នុងអន្លង់ទាំង៤នេះ ដូចជាទឹកទន្លេហូរចូលទៅកាន់មហាសមុទ្រ មានតែរសជាតិប្រៃម្យ៉ាងប៉ុណ្ណោះ ។ ចិត្តដែលទៅនៅក្នុងអន្លង់ទាំង៤ នោះ មានតែកងទុក្ខម្យ៉ាងឥតមានសុខទេ បង្ហូរមកនូវទុក្ខនិងទោសច្រើន អនេករាប់មិនអស់ ដូចជាទឹកប្រៃក្នុងមហាសមុទ្រដូច្នោះឯង ។

សញ្ញា វិញ្ញាណថា ខ្ញុំទាំងពីរនាក់នេះ ធ្លាប់យល់ថាទៀងក្នុង ខន្ធទាំង៥ក្នុងភពទាំង៣ ធ្លាប់យល់ថាសុខក្នុងខន្ធទាំង៥ ក្នុងភពទាំង៣ ធ្លាប់យល់ថាខ្លួនអញ យល់ថាស្អាត ថាស្រី ថាប្រុស ខ្ញុំទាំងពីរនាក់ នេះយល់ទៅតាមធម៌ថោកទាប ជាធម៌របស់អ្នកនិគម តាំងតែអំពីកើត មក ឃើញថាខុសច្រើនណាស់ បើយល់ខុសដូច្នេះហើយហៅថា មិច្ឆា-ទិដ្ឋិពិតមែន ត្រង់យល់ថាសុខក្នុងរបស់ដែលមានទុក្ខ១ យល់ថាទៀង ក្នុងរបស់ដែលមិនទៀង១ យល់ថាស្អាតក្នុងរបស់ដែលមិនស្អាត១ យល់ ថាខ្លួនអញក្នុងរបស់ដែលមិនមែនខ្លួនអញ១ តួចិត្តដែលយល់ថាខ្លួនអញ នេះ ជាតួទិដ្ឋោឃៈ ។ ត្រង់ខន្ធ៥ដែលគ្មានអញ គ្មានសុខ គ្មានស្រី គ្មាន ប្រុសសោះ ហើយយល់ថា អញ ថាសុខ ថាស្រី ថាប្រុស តួចិត្តនេះជាតួ អវិជ្ជោឃៈ អន្លង់គឺអវិជ្ជា ។ ត្រង់តួចិត្តដែលត្រេកអរទៅតាមទិដ្ឋិដែល ឃើញថាអញៗ សុខៗ ថាស្រីៗ ថាប្រុសៗនោះ តួចិត្តនេះហៅថា កាមោឃៈ ។ តួចិត្តដែលប្រកាន់យកសុខៗ ប្រកាន់យកអញៗ ស្រីៗ ប្រុសៗនោះ មិនព្រមលែងតួចិត្តនោះហៅថា ភវោឃៈ ។

វិញ្ញាណថា ខ្ញុំគ្រាន់តែយល់ថា អញៗ ថាសុខៗ ថាស្រីៗ ថាប្រុសៗ ថាស្អាតៗប៉ុណ្ណោះ តើវាខុសអ្វីខ្លះ? បានជាធ្លាក់ទៅក្នុង អន្លង់ឱឃៈទាំង៤ សោយតែសេចក្តីទុក្ខច្រើនជាអនេក ដូច្នេះ? ។ តបថា ខុសក្នុងកម្មបថ១០ ត្រូវទោសអភិជ្ឈាផង ព្យាបាទផង មិច្ឆាទិដ្ឋិផង

ត្រូវទោសនោះដូច្នេះគឺ **អភិជ្ឈាកាយគន្ថ:** ចិត្តរំពឹងរំពៃយកទ្រព្យគឺ អាការៈ៣២ទាំងមូលនេះ ថាជាទ្រព្យមានតាំងអំពីសក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម ។ល។ យល់ថារបស់ទាំងនេះសំគាល់ថាជារបស់ខ្លួន បើសំគាល់ឃើញដូច្នេះត្រូវទោសអភិជ្ឈា បើប្រទូសរ៉ាយខឹងនឹងសក់ស្កូវ ខឹងនឹងធ្មេញឈឺ ឬនឹងជម្ងឺណាមួយក្នុងកាយទាំងមូលនេះ ត្រូវទោស ព្យាបាទកាយគន្ថ: ។ **ឥទំសច្ចាភិនិវេសកាយគន្ថ:** ប្រកាន់ថា ឲ្យកាយនៅទៀងៗ វេទនានៅទៀងៗ សញ្ញា-សង្ខារ-វិញ្ញាណ នៅទៀងៗ អាការៈណាមួយឲ្យតែប្រកាន់ថា ឲ្យនៅតែទៀងៗដូច្នេះ ត្រូវទោស មិច្ឆាទិដ្ឋិ ទាំងអស់ ។ ខុសក្នុងកម្មបថដូច្នេះហើយ បានជាធ្លាក់ទៅក្នុង អន្លង់ឱឃ:ទាំង៤ ដូចជាទឹកទន្លេដែលហូរទៅកាន់មហាសមុទ្រហើយ ក្លាយរសជាតិទៅជាប្រៃតែម៉្យាងប៉ុណ្ណោះ ចិត្តដែលនៅក្នុងអន្លង់ទាំង៤ នេះ មានតែទុក្ខនិងទោសច្រើន ដូចជាទឹកប្រៃនោះដែរ ។

ពិតមែនហើយបញ្ញា ខ្ញុំអស់សង្ស័យហើយ ព្រោះថាមនុស្ស-សត្វ កើតស្លាប់ ស្លាប់កើតមានតែទុក្ខនិងទោសច្រើនជាអនេក ព្រោះតែ ត្រូវទោសក្នុងកម្មបថនេះ ។

សញ្ញា វិញ្ញាណសួរថា ចុះធ្វើដូចម្ដេច យល់ដូចម្ដេចទើបនឹងរួចផុត ពីអកុសល មិច្ឆាទិដ្ឋិនេះ ។ តបថា សញ្ញា វិញ្ញាណ អ្នកចាំស្ដាប់ឲ្យច្បាស់ តាមអត្ថរសអំពីអភិធម្មចុះ អភិធម្មប្រែថា ធម៌មានសេចក្ដីចំរើន ធម៌គួរ កំណត់ ធម៌គួរបូជា ធម៌មិនច្រឡំគ្នា ធម៌ដ៏ក្រៃលែង ។

អធិប្បាយថា ធម៌មានសេចក្ដីចំរើននោះ គឺចំរើនចំពោះនាមរូប ឲ្យឃើញនូវសភាវធម្មរសរបស់ធម៌តាមមែនតាមពិត ឲ្យឃើញបញ្ញា សទ្ធា សតិ វិរិយ: សមាធិ កើតឡើងហើយ កំណត់នូវសភាវៈនោះ មកជា

អារម្មណ៍ហើយ ធ្វើទុកក្នុងចិត្តឲ្យមូលហើយ បូជាចំពោះធម្មរសនោះ ដែលមានសភាវៈមែនៗពិតៗនោះ ។ ធម៌ដ៏ក្រៃលែងគឺសេក្ខធម៌និង អសេក្ខធម៌ កើតឡើងចំពោះព្រះយោគាវចរនោះ កាលបើធម៌នោះកើត ឡើងហើយ ជាធម៌មិនច្រឡំគ្នា តាំងពីដើមរៀងទៅដល់ទីបំផុត ជាធម៌ ឥតច្រឡំគ្នាឡើយ ។ ពាក្យថាយល់ ឬកំណត់សំគាល់ទៅតាមសភាវៈ តាមមែនតាមពិតរបស់ធម៌នោះៗ បើយល់ខុស កំណត់ក៏ខុស សំគាល់ ក៏ខុស ហៅថា មិច្ឆាទិដ្ឋិ ។ បើយល់ត្រូវ កំណត់ក៏ត្រូវ សំគាល់ ក៏ត្រូវ ហៅថា សម្មាទិដ្ឋិ ។ ឯមិច្ឆាទិដ្ឋិនេះជាគូសត្រូវនឹងគ្នា ឥឡូវនេះ នឹងសំដែងអំពីមិច្ឆាទិដ្ឋិជាមុន ចូរអ្នកតាំងចិត្តស្តាប់នូវទិដ្ឋិទាំងពីរនេះចុះ។

| | |
|---|---|
| យល់ថាទៀង | ក្នុងរបស់ដែលមិនទៀង១ |
| យល់ថាសុខ | ក្នុងរបស់ដែលជាទុក្ខ១ |
| យល់ថាខ្លួនអញ | ក្នុងរបស់ដែលមិនមែនខ្លួនអញ១ |
| យល់ថាស្អាត | ក្នុងរបស់ដែលមិនស្អាត១ |

គំនិតដែលយល់ខុសទាំង៤យ៉ាងនេះ ហៅថា អវិជ្ជា ។ ចិត្តដែលស្ទុះចូល ទៅតាមគំនិតដែលយល់ខុសនោះ ឆេះឡើងជាភ្លើងកិលេសគឺត្រេកអរ ស្រឡាញ់, ឆេះឡើងជាភ្លើងកិលេសគឺខឹងស្អប់, ឆេះឡើងជាភ្លើង កិលេសគឺភ័យខ្លាច, ឆេះឡើងជាភ្លើងកិលេសគឺសោកស្តាយ ។ ភ្លើងកិលេសទាំងអស់នេះដុតបំពក់ចិត្តឲ្យក្តៅទាំងយប់ទាំងថ្ងៃ តែងនាំ ចិត្តឲ្យទៅកើតក្នុងប្រេត នរក សត្វតិរច្ឆានគ្រប់ៗជាតិ មិនចេះអស់ នូវភ្លើងកិលេសទាំងនោះឡើយ ។ ភ្លើងកិលេសនេះដុត បំផ្លាញចិត្ត ។ ភ្លើងទុក្ខសម្រាប់ដុតបំផ្លាញរូប ។ ភ្លើងទាំងពីរភ្នក់នេះ ឆេះមិនឈប់ ទាំងថ្ងៃទាំងយប់ រាប់សែនជាតិ រាប់កប្បក៏មិនអស់ អំពីភ្លើងទុក្ខភ្លើង

កិលេសទាំងនេះ ។ បើចង់រំលត់ភ្លើងនោះឲ្យអស់ចេញ តើត្រូវរំលត់ដោយអ្វី? ត្រូវរំលត់ដោយបញ្ញាជាសម្មាទិដ្ឋិ គឺបញ្ញាឃើញច្បាស់នូវភ្នក់ភ្លើងទាំងពីរនេះ ហើយព្យាយាមកំចាត់បង់នូវអ្នកដែលដុតឲ្យឆេះនោះចេញ គឺមោហៈអវិជ្ជានេះដុតឲ្យឆេះ ។ បើដូច្នេះមោហៈអវិជ្ជានោះតើដូចម្តេច? មោហៈថាវង្វេងភ័ន្ត សំគាល់របស់មិនពិតថាពិត អវិជ្ជាថាមិនដឹងដូចជាមិនដឹងផ្លូវ ។

យល់ថាទៀង ក្នុងរបស់មិនទៀង១,
យល់ថាសុខ ក្នុងរបស់ដែលមានទុក្ខ១,
យល់ថាខ្លួន-អញ ក្នុងរបស់ដែល មិនមែនខ្លួន-អញ១,
យល់ថាស្អាត ក្នុងរបស់ដែលមិនស្អាត១ ។

មោហៈអវិជ្ជាដែលយល់ខុសទាំង៤យ៉ាងនេះ ហើយមិនដឹងជាខុសផងក៏ឆេះជាភ្លើង គឺត្រេកអរ ស្រឡាញ់ ឆេះជាភ្លើងគឺខឹង ស្អប់ ឆេះជាភ្លើងគឺភ័យខ្លាច ឆេះជាភ្លើងគឺសោកស្តាយ ។ បើរំលត់មោហៈអវិជ្ជាអស់ភ្លើងទាំងនោះក៏រលត់អស់ដែរ ។ នែសញ្ញា វិញ្ញាណ! ខ្ញុំសំដែងមកអំពីមិច្ឆាទិដ្ឋិដែលយល់ខុស សំគាល់ខុស កំណត់ខុស តែប៉ុណ្ណោះ នឹងសំដែងអំពីសម្មាទិដ្ឋិដែលយល់ត្រូវ កំណត់ត្រូវ សំគាល់ត្រូវ ដូចមានសេចក្តីតទៅនេះ៖

**១-អនិច្ចសញ្ញា** គឺសញ្ញាដែលសំគាល់ថាមិនទៀងក្នុងខន្ធ៥ គឺរូបមិនទៀងតែងប្រែប្រួល ប្រព្រឹត្តទៅកាន់ចាស់-ឈឺ-ស្លាប់ជាធម្មតា ។ វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារមិនទៀង វិញ្ញាណមិនទៀង ។ កាលបើឃើញថាមិនទៀងហើយ គួរលះបង់សញ្ញាដែលសំគាល់ថាទៀងចេញ កាន់យកសញ្ញាដែលសំគាល់ថាមិនទៀងនោះមកជាអារម្មណ៍

ប្រព្រឹត្តទៅតាមទ្វារទាំង៦ មានទ្វារភ្នែកជាដើម រំលត់បង់នូវនិមិត្ត ដែលឃើញថាទៀងៗនោះចេញ កាន់យកនូវអសង្ខតនិមិត្ត គឺមិនមែននិមិត្តនោះមកជាអារម្មណ៍ក្នុងទ្វារទាំង៦ ឈ្មោះថា **អនិមិត្តវិមោក្ខ** រួចស្រឡះពីខន្ធ៥ ។

**២-អាទីនវសញ្ញា** គឺសញ្ញាសំគាល់ឃើញទោសទុក្ខក្នុងខន្ធ៥ថា ភ្នែកក៏មានរោគ ទោសទុក្ខនឹងភ្នែក ។ ត្រចៀកក៏មានរោគ ទោសទុក្ខនឹងត្រចៀក ច្រមុះក៏មានរោគ ទោសទុក្ខនឹងច្រមុះ អណ្តាតក៏មានរោគ ទោសទុក្ខនឹងអណ្តាត កាយក៏មានរោគ ទោសទុក្ខនឹងកាយ ។ រោគនោះគឺ រោគធ្វើឲ្យចិត្តក្តៅ កាលបើសំគាល់ឃើញថាភ្នែក-ត្រចៀក-ច្រមុះ-អណ្តាត-កាយនោះជាទុក្ខទោសហើយ គួរលះបង់នូវសញ្ញាដែលសំគាល់ថាសុខចេញ កាន់យកនូវទោសនោះមកជាអារម្មណ៍ ប្រព្រឹត្តទៅក្នុងទ្វារទាំង៦ រំលត់នូវសង្ខតនិមិត្ត គឺនិមិត្តដែលឃើញថាសុខក្នុងភ្នែក-ត្រចៀក-ច្រមុះ-អណ្តាត-កាយនោះចេញ កាន់យកនូវ អសង្ខត-និមិត្ត គឺមិនមាននិមិត្តក្នុងភ្នែក-ត្រចៀក-ច្រមុះ-អណ្តាត-កាយ ហៅថា **អប្បណិហិតវិមោក្ខ** ឬហៅថា ព្រះនិព្វាន ដូច្នេះក៏បាន ។

**៣-អនត្តសញ្ញា** គឺសញ្ញាដែលសំគាល់ថា មិនមែនខ្លួន មិនមែនអញ រូប១ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១ ទាំងអស់នេះសុទ្ធតែមិនមែនខ្លួន មិនមែនអញ ។ កាលបើឃើញ ថាមិនមែនហើយ លះបង់នូវអត្តសញ្ញា កាន់យកនូវអនត្តសញ្ញា ដែលឃើញថាមិនមែននោះមកជាអារម្មណ៍ ប្រព្រឹត្តទៅក្នុងទ្វារទាំង៦ ឈ្មោះថា **សុញ្ញតវិមោក្ខ** រួចស្រឡះពីខន្ធ៥ រំលត់បង់នូវសង្ខតនិមិត្ត គឺនិមិត្ត

ដែលឃើញថាអញៗនោះចេញ កាន់យកនូវអសង្ខតនិមិត្ត គឺមិនមែននិមិត្ត ប្រព្រឹត្តទៅក្នុងទ្វារទាំង៦ ។

**៤-អសុភសញ្ញា** គឺសញ្ញាសំគាល់ឃើញថាមិនស្អាត សក់មិនស្អាតព្រោះជាអសុភ រោមមិនស្អាតព្រោះជាអសុភ ក្រចកមិនស្អាតព្រោះជាអសុភ ធ្មេញមិនស្អាតព្រោះជាអសុភ ស្បែកមិនស្អាតព្រោះជាអសុភ ។ កាលពិចារណាឃើញថាមិនស្អាត កាន់យកនូវវត្ថុដែលមិនស្អាតនោះមកជាអារម្មណ៍ ប្រព្រឹត្តទៅក្នុងទ្វារទាំង៦ លះបង់នូវសង្ខតនិមិត្ត គឺនិមិត្តដែលឃើញថាល្អនោះចេញ កាន់យកនូវ អសង្ខត-និមិត្ត គឺមិនមាននិមិត្តនោះមកជាអារម្មណ៍ ហើយប្រព្រឹត្តទៅក្នុងឥរិយាបថទាំង៤ ។ ពាក្យថា សង្ខតនិមិត្ត កើតមកអំពីអវិជ្ជា ។ ពាក្យថា អសង្ខតនិមិត្ត មិនមានអវិជ្ជាជាបច្ច័យ ឬហៅថា អសង្ខតធម៌ក៏បាន ។

**៥-បហានសញ្ញា** គឺសញ្ញាសំគាល់ឃើញទោសក្នុងកាមគុណទាំង៥ ថារូប សម្លេង ក្លិន រស សម្ផស្ស ជារបស់សោះសូន្យទទេៗ ហើយនាំចិត្តឲ្យជាប់នៅជេកត្រាំនៅក្នុងអន្លង់ ដូចសត្វជង្គ្វរនៅក្នុងបង្គន់ កើតស្លាប់ជាធម្មតា ។ សញ្ញាសំគាល់ទោសក្នុងព្យាបាទនេះ ធ្វើចិត្តឲ្យក្តៅក្រហល់ក្រហាយ តែងតែឲ្យហេតុទោសចងពៀរវេរា ។ សញ្ញាសំគាល់ឃើញទោសក្នុងការបៀតបៀនសត្វនិងសង្ខារ ហើយមិនព្រមត្រិះរិះ ប្រកបដោយកាមគុណ មិនត្រិះរិះដោយព្យាបាទ មិនព្រមត្រិះរិះដោយការបៀតបៀនសត្វនិងសង្ខារ គំនិតដែលត្រិះរិះក្នុងកាមហើយត្រេកអរ ត្រិះរិះក្នុងព្យាបាទហើយខឹង ត្រិះរិះក្នុងការបៀតបៀនហើយត្រេកអរ គំនិតទាំង៣នេះជាគំនិតអាក្រក់ដឹកនាំឲ្យលិចលង់នៅក្នុងសង្សារវដ្ត រកទីបំផុតគ្មាន ។

សញ្ញាគឺសញ្ញាសំគាល់ឃើញទោសក្នុងកាមគុណទាំង៥ ឃើញទោសព្យាបាទ ឃើញទោសបៀតបៀនសត្វនិងសង្ខារ កាលឃើញទោសដូច្នេះហើយ ក៏មិនព្រមត្រិះរិះក្នុងកាម មិនព្រមឲ្យចិត្តជាប់នៅក្នុងកាម ចិត្តដែលស្រូបយកជាតិកាមនោះ ដូចជាសត្វរុយជញ្ជក់យកជាតិសំអុយដែលហូរចេញអំពីអសុភសាកសព ហើយញៀនញ៉ាមជាប់ចិត្តនៅក្នុងសំអុយ ចិត្តដែលត្រិះរិះក្នុងកាមដូចរុយពណ៌ខៀវ ត្រេកអរតែក្នុងសំអុយ កាមគុណនេះមានទោសឲ្យក្តៅជានិច្ច ហើយឥតអំពើនឹងនាំចិត្តឲ្យលិចលង់កើតស្លាប់រាប់មិនអស់ក្នុងភព៣ ។ សញ្ញាសំគាល់ឃើញទោសក្នុងព្យាបាទ ថាព្យាបាទនេះធ្វើចិត្តឲ្យក្តៅក្រហាយ ធ្វើចិត្តរបស់ខ្លួនឲ្យក្តៅជាមុនហើយ ញុំាងចិត្តអ្នកដទៃឲ្យក្តៅបង្កហេតុ ហើយគំនុំគុំគួនចងពៀរវេរានឹងគ្នាទៅខាងមុខ ជៀសវាងមិនរួចពីភព៣ ។ សញ្ញាសំគាល់ឃើញទោសបៀតបៀនសត្វនិងសង្ខារនេះ ជាអំពើថោក-ទាប នាំឲ្យធ្លាក់ទៅនរករៀងរាល់ជាតិ កាលបើសំគាល់ឃើញទោសក្នុងកាម ក្នុងព្យាបាទ ក្នុងបៀតបៀនដូច្នេះហើយ មិនព្រមត្រិះរិះមិនធ្វើចិត្តឲ្យជាប់ជំពាក់ឡើយ នេះហៅថា **បហានសញ្ញា** ។ ។

**៦-វិរាគសញ្ញា** គឺសញ្ញាសំគាល់ឃើញនូវធម៌ ដែលមិនមានតម្រេកនឹងរូប មិនមានតម្រេកនឹងសម្លេង មិនមានតម្រេកនឹងក្លិន មិនមានតម្រេកនឹងរស មិនមានតម្រេកនឹងសម្ផស្ស មិនមានតម្រេកនឹងធម៌ គឺអារម្មណ៍ដែលនៅក្នុងចិត្ត ធម៌ដែលប្រាសចាកតម្រេកនេះជាគុណជាតិស្អាត ស្ងប់រម្ងាប់ជាសុខ ហៅថា **វិរាគសញ្ញា** ។

៧-និរោធសញ្ញា គឺសញ្ញា សំគាល់ឃើញនូវព្រះនិព្វាន ជាធម៌រំលត់បង់នូវកងទុក្ខ ឬថាជាគុណជាតិស្អាត ផុតអំពីតណ្ហាទាំងអស់ពុំមានសេសសល់ឡើយ ។ ព្រះនិព្វានមិនមានសង្ខតនិមិត្ត គឺនិមិត្តដែលកើតអំពីអវិជ្ជាជាបច្ច័យនោះទេ មានតែអសង្ខតនិមិត្ត គឺមិនមាននិមិត្ត ប្រាសចាកសង្ខារធម៌ជាអារម្មណ៍ ស្ងប់រម្ងាប់ជាសុខក្សេមក្សាន្ត គឺផលញាណនេះ ហៅថា និរោធសញ្ញា ។

៨-សព្វលោកេអនភិរតសញ្ញា គឺសញ្ញាសំគាល់ឃើញ ច្បាស់ថាតណ្ហាទាំង៣ ឧបាទានទាំង៥ សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ទាំង២ និងអនុសយធម៌ទាំង៧នេះ ចងសត្វឲ្យជាប់នៅក្នុងភព៣ ដោះចេញពុំរួចឡើយ ។ សត្វបើជាប់ចំណងយ៉ាងនេះហើយ ស្ដេច មច្ចុរាជធ្វើទោសបំបាត់ជីវិត ពុំមានសេសសល់ឡើយ កើតហើយស្លាប់ ស្លាប់ហើយកើតវិញរកទីបំផុតគ្មាន រាប់កើតមិនអស់ រាប់ស្លាប់មិនអស់ រាប់សោកខ្សឹកខ្សួលក៏មិនអស់ ទុក្ខនេះជាទម្ងន់ក្រៃលែង ។ ផែនដីផែនអាកាសធំមែន ប៉ុន្តែធំមិនស្មើនឹងទុក្ខរបស់សត្វដែលកើតស្លាប់ នោះទេ ទុក្ខទាំងអស់នេះមិនងាយសត្វណាលះបង់បាន គួរចង់ដឹងថា ទុក្ខនេះមកអំពីណាក៏ច្រើនម៉្លេះ? មកអំពីតណ្ហាជាហេតុឲ្យកើតទុក្ខ ។ បើរំលត់តណ្ហាបាន ទុក្ខនោះក៏អស់ទៅដែរ ។ ចុះតណ្ហានោះដូចម្ដេច? តណ្ហានេះមាន៣ គឺកាមតណ្ហា ត្រេកអរនឹងកាមគុណ៥ ភវតណ្ហាជាប់ចិត្តនឹងរូបកាមគុណ៥ វិភវតណ្ហាមិនចង់ឲ្យជួបនឹងរូបព្រាត់ប្រាសរូបចាស់-ឈឺ-ស្លាប់ ក្នុងកាមគុណ៥ ប្រកបដោយសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិទាំង២ ឧបាទានប្រកាន់យកនូវកាមគុណទាំង៥ ចងជាប់នឹងស្អឹង គឺសស្សតទិដ្ឋិ-ឧច្ឆេទទិដ្ឋិ ។ តណ្ហាទាំង៣នេះ ជាខ្សែអនុសយ

ធម៌ទាំង៧នេះ ដេកត្រាំនឹងខ្សែ ត្រេកអរនឹងខ្សែ លក់នឹងខ្សែ ដេកត្រាំនឹងស្ទឹង ត្រេកអរនឹងស្ទឹង លក់ក្នុងស្ទឹង ដេកត្រាំនឹងចំណង ត្រេកអរនឹងចំណង លក់ក្នុងចំណងខន្ធ៥ដូចជាគោ ។ បើសត្វជាប់ចំណងយ៉ាងនេះស្រាយមិនរួចហើយ នៅវិលវល់ក្នុងភពទាំង៣ កើតស្លាប់ៗនៅក្នុងលោកនេះ ហៅថា *សព្វលោកេអនភិរតសញ្ញា* ។

៩-*សព្វសង្ខារេសុអនិច្ចសញ្ញា* គឺសញ្ញាសំគាល់ឃើញទុក្ខទោសរបស់រូប ហើយនឿយណាយក្នុងរូប សំគាល់ឃើញទុក្ខទោសក្នុងវេទនា ហើយនឿយណាយនឹងវេទនា សំគាល់ឃើញទុក្ខទោសក្នុងសញ្ញា ហើយនឿយណាយនឹងសញ្ញា សំគាល់ឃើញទុក្ខទោសក្នុងសង្ខារ ហើយនឿយណាយនឹងសង្ខារ ឃើញទុក្ខទោសរបស់វិញ្ញាណ ហើយនឿយណាយនឹងវិញ្ញាណ ។ នឿយណាយធុញទ្រាន់នេះជានិព្វិទាញាណហៅថា *សព្វសង្ខារេសុអនិច្ចសញ្ញា* ។

១០-*អានាបានស្សតិ*

| | |
|---|---|
| ខ្យល់ដកដង្ហើមចេញ | ដឹងច្បាស់ថាខ្យល់ដកដង្ហើមចេញ |
| ខ្យល់ដកដង្ហើមចូល | ដឹងច្បាស់ថាខ្យល់ដកដង្ហើមចូល |
| ខ្យល់ដកដង្ហើមចេញវែង | ដឹងច្បាស់ថាខ្យល់ដកដង្ហើមចេញវែង |
| ខ្យល់ដកដង្ហើមចូលវែង | ដឹងច្បាស់ថាខ្យល់ដកដង្ហើមចូលវែង |
| ខ្យល់ដកដង្ហើមចេញខ្លី | ដឹងច្បាស់ថាខ្យល់ដកដង្ហើមចេញខ្លី |
| ខ្យល់ដកដង្ហើមចូលខ្លី | ដឹងច្បាស់ថាខ្យល់ដកដង្ហើមចូលខ្លី |
| ដឹងច្បាស់នូវកាយសង្ខារ | ទើបដកដង្ហើមចេញ |
| ដឹងច្បាស់នូវកាយសង្ខារ | ទើបដកដង្ហើមចូល |

រម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ
រម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល
ដឹងច្បាស់នូវកាយ ទើបដកដង្ហើមចេញ
ដឹងច្បាស់នូវកាយ ទើបដកដង្ហើមចូល
ដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចេញ
ដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចូល
ដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចេញ
ដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចូល
ដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ
ដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល
រម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ
រម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល
ដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចេញ
ដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចូល
ធ្វើចិត្តឲ្យរីករាយ ទើបដកដង្ហើមចេញ
ធ្វើចិត្តឲ្យរីករាយ ទើបដកដង្ហើមចូល
ដំកល់ចិត្តឲ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចេញ
ដំកល់ចិត្តឲ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចូល
ដោះចិត្តឲ្យរួចចាកនីវរណធម៌ ទើបដកដង្ហើមចេញ
ដោះចិត្តឲ្យរួចចាកនីវរណធម៌ ទើបដកដង្ហើមចូល
ឃើញរឿយៗនូវបញ្ចក្ខន្ធថាមិនទៀង ទើបដកដង្ហើមចេញ
ឃើញរឿយៗនូវបញ្ចក្ខន្ធថាមិនទៀង ទើបដកដង្ហើមចូល

ឃើញរឿយៗនូវធម៌ដែលប្រាសចាករាគៈ ទើបដកដង្ហើមចេញ
ឃើញរឿយៗនូវធម៌ដែលប្រាសចាករាគៈ ទើបដកដង្ហើមចូល
ឃើញរឿយៗនូវធម៌ដែលរំលត់បង់នូវកងទុក្ខ ទើបដកដង្ហើមចេញ
ឃើញរឿយៗនូវធម៌ដែលរំលត់បង់នូវកងទុក្ខ ទើបដកដង្ហើមចូល
ឃើញរឿយៗនូវធម៌ដែលលះបង់ចោលនូវកិលេស ទើបដកដង្ហើមចេញ
ឃើញរឿយៗនូវធម៌ដែលលះបង់ចោលនូវកិលេស ទើបដកដង្ហើមចូល។

នែសញ្ញា វិញ្ញាណ! ការចំរើននូវអានាបានស្សតិ ជាប្រយោជន៍ឲ្យកើតឡើងនូវពលៈ ទាំង៥ គឺ សទ្ធាពលៈ១ សតិពលៈ១ វិរិយពលៈ១ សមាធិពលៈ១ និង បញ្ញាពលៈ១ ។ ពលៈទាំង៥នេះ ដែលមានកម្លាំងហើយ ស្ទាត់ជំនាញគ្រប់ក្រសួងទាំង៥នោះ មកអំពីការហាត់ ចំរើននូវអានាបានស្សតិនេះឯង ដូចយ៉ាងហាត់ចំរើនថា ឃើញរឿយៗនូវបញ្ចក្ខន្ធថាមិនទៀង-ទុក្ខ-អនត្តា ទើបដកដង្ហើមចេញ ឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង-ទុក្ខ-អនត្តា ទើបដកដង្ហើមចូល ។ ត្រង់ដែលឃើញថាខ្យល់ចេញចូលផង ឃើញអនិច្ចំ ទុក្ខំ អនត្តា ក្នុងនាមនិងរូបផង នេះហៅថា បញ្ញាពលៈ ។ ត្រង់ដែលជឿទៅតាមអនិច្ចំ ទុក្ខំ អនត្តា ដែលបញ្ញាឃើញហើយ មានជំរៅទៅយ៉ាងណាក៏ជឿទៅយ៉ាងនោះ មិនកំរើក មិនញាប់ញ័រ ហៅថា សទ្ធាពលៈ ។ ត្រង់ដែលរលឹកឃើញរឿយៗនូវអនិច្ចំ ទុក្ខំ អនត្តា ទៅតាមកំរិតរបស់សទ្ធានោះ ហៅថា សតិពលៈ ។ ត្រង់ដែលកំណត់យក អនិច្ចំ ទុក្ខំ អនត្តា មកជាអារម្មណ៍ រំលត់បង់នូវនិមិត្ត ដែលឃើញថាទៀងៗថាសុខៗ ថាអញៗនោះ ឲ្យអស់ហើយ ហៅថា សមាធិពលៈ ។ ត្រង់ដែល

ព្យាយាមថែរក្សាទុកនូវបញ្ញាផង ថែរក្សាទុកនូវសមាធិផង ហៅថា វិរិយពលៈ ។

សមាធិនេះមាន៣យ៉ាងគឺ អនិមិត្តសមាធិ១ អប្បណិហិតសមាធិ១ សុញ្ញត្តសមាធិ១ ។

បើកាន់យកទុក្ខមកកំណត់ ហៅថា អប្បណិហិតសមាធិ ។

បើកាន់យកមិនទៀងមកកំណត់ ហៅថា អនិមិត្តសមាធិ ។

បើកាន់យកអនត្តាមកកំណត់ ហៅថា សុញ្ញត្តសមាធិ ។

ពលៈទាំង៥នេះ កាលដែលព្រះពុទ្ធអង្គ ទ្រង់ចំរើនបង្ហាត់បង្វឹកដោយអានាបនស្សតិកម្មដ្ឋាន ក្រោមម្លប់ពោធិព្រឹក្ស ពេលនោះព្រះអង្គបង្ហាត់ពលៈទាំង៥នេះ ឲ្យបានស្ទាត់ជំនាញហើយ ទើបលើកយកសមាធិពលៈមកកំណត់ក្នុង អនិច្ចំ ទុក្ខំ អនត្តា ហើយទើបយកបញ្ញាពលៈ ឆ្លុះបញ្ចាំងមើលសង្ខារ ដែលប្រព្រឹត្តទៅក្នុងភូមិទាំង៣ ឃើញសុទ្ធតែសឹកសត្រូវ ជាមារទាំងអស់គឺ កិលេសមារ១ ខន្ធមារ១ អភិសង្ខារមារ១ មច្ចុមារ១ ទេវបុត្តមារ១ ។ ព្រះអង្គទ្រង់ ឆ្លុះបញ្ចាំងមើលទៀតថា មារទាំង៥នេះ ដែលអាស្រ័យនៅបានដោយ ហេតុណា ទ្រង់ក៏ឃើញច្បាស់ថាមារទាំង៥នេះ អាស្រ័យនៅបាន ដោយអារម្មណ៍ គឺកាមារម្មណ៍៦ រូបារម្មណ៍៦ អរូបារម្មណ៍៦ អារម្មណ៍ទាំងនេះហើយ ដែលមារទាំង៥ប្រព្រឹត្តទៅបាន នៅក្នុងភូមិទាំង៣នេះ ។ ព្រះអង្គក៏ទ្រង់កំណត់នូវសមាធិន្ទ្រិយដោយអប្បណិហិតសមាធិន្ទ្រិយ ទើបទ្រង់ផ្តាច់នូវអារម្មណ៍ជាធម្មតាចោលចេញអស់ ឥតមាននៅសេសសល់ឡើយ ដោយអំណាចនៃការកំណត់កាន់យកទុក្ខជាអារម្មណ៍ ក្នុងពេលនោះ

បញ្ញាក៏ត្រាស់ដឹងនូវពោធិបក្ខិយធម៌ ជាសម្ពោធិញ្ញាណ ទើបបានទ្រង់ព្រះនាមថា ពុទ្ធោ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឈ្នះ សឹកសត្រូវ គឺ កិលេសមារ ខន្ធមារ អភិសង្ខារមារ មច្ចុមារ ទេវបុត្តមារ គឺមារទាំង៥នេះឯង ។

នែសញ្ញា វិញ្ញាណ! អ្នកស្ដាប់ហើយកំណត់នូវធម៌ ដូចមានសំដែងតទៅខាងមុខនេះទៀតចុះ ការកើតក៏មិនទៀង ចាស់ក៏មិនទៀង ឈឺក៏មិនទៀង ស្លាប់ក៏មិនទៀង ។ ការកើតជាទុក្ខ ការចាស់ជាទុក្ខ ការឈឺក៏ជាទុក្ខ ការស្លាប់ក៏ជាទុក្ខ ។

-ការកើតក៏មិនមែនជារបស់អញ អញក៏មិនមែនជារបស់ការកើត
-ចាស់ក៏មិនមែនជារបស់អញ អញក៏មិនមែនជារបស់ចាស់
-ឈឺក៏មិនមែនជារបស់អញ អញក៏មិនមែនជារបស់ឈឺ
-ស្លាប់ក៏មិនមែនជារបស់អញ អញក៏មិនមែនជារបស់ស្លាប់ ។
-ចិត្តកុំត្រេកអរនឹងភ្នែកកុំខឹងនឹងភ្នែក ព្រោះភ្នែកមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងត្រចៀកកុំខឹងនឹងត្រចៀក ព្រោះត្រចៀកមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងច្រមុះ កុំខឹងនឹងច្រមុះ ព្រោះច្រមុះមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងអណ្ដាត កុំខឹងនឹងអណ្ដាត ព្រោះអណ្ដាតមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងកាយ កុំខឹងនឹងកាយ ព្រោះកាយមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងចិត្ត កុំខឹងនឹងចិត្ត ព្រោះចិត្តមិនមែនរបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងរូប កុំខឹងនឹងរូប ព្រោះរូបមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងសម្លេង កុំខឹងនឹងសម្លេង
ព្រោះសម្លេងមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងក្លិន កុំខឹងនឹងក្លិន ព្រោះក្លិនមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងរស កុំខឹងនឹងរស ព្រោះរសមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងសម្ផស្ស កុំខឹងនឹងសម្ផស្ស
ព្រោះសម្ផស្សមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងអារម្មណ៍ផ្សេងៗ កុំខឹងនឹងអារម្មណ៍ផ្សេងៗ
ព្រោះអារម្មណ៍ផ្សេងៗមិនមែនរបស់ខ្លួន ។
-ចិត្តកុំត្រេកអរនឹងរូប កុំខឹងនឹងរូប ព្រោះរូបមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងវេទនា កុំខឹងនឹងវេទនា
ព្រោះវេទនាមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងសញ្ញា កុំខឹងនឹងសញ្ញា
ព្រោះសញ្ញាមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងសង្ខារ កុំខឹងនឹងសង្ខារ
ព្រោះសង្ខារមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរនឹងវិញ្ញាណ កុំខឹងនឹងវិញ្ញាណ
ព្រោះវិញ្ញាណមិនមែនរបស់ខ្លួន
-ចិត្តកុំត្រេកអរ ចិត្តកុំខឹង ចិត្តកុំស្អប់ ចិត្តកុំស្រឡាញ់ ចិត្តកុំខ្លាច ចិត្តកុំភ័យ ចិត្តកុំសោកស្តាយនឹងអារម្មណ៍ដែលចេញចូលតាមភ្នែក ព្រោះអារម្មណ៍ដែលចេញចូលតាមភ្នែកនោះមិនមែនជារបស់ខ្លួនទេ ។ល។

-ចិត្តកុំត្រេកអរ ចិត្តកុំខឹង ចិត្តកុំស្អប់ ចិត្តកុំស្រឡាញ់ ចិត្តកុំខ្លាច ចិត្តកុំភ័យ ចិត្តកុំសោកស្តាយនឹងអារម្មណ៍ដែលចេញចូលតាមចិត្ត ព្រោះអារម្មណ៍ដែលចេញចូលតាមចិត្តនោះមិនមែនជារបស់ខ្លួនទេ ។

-ចិត្តកុំត្រេកអរនឹងសុខ ព្រោះសុខមិនមែនជារបស់ខ្លួន ។

-ចិត្តកុំខឹងនឹងទុក្ខ ព្រោះទុក្ខមិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងពាក្យសរសើរ

ព្រោះពាក្យសរសើរ មិនមែនជារបស់ខ្លួន ។

-ចិត្តកុំខឹងនឹងពាក្យតិះដៀល

ព្រោះពាក្យតិះដៀល មិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងមានលាភ ព្រោះមានលាភ មិនមែនជារបស់ខ្លួន ។

-ចិត្តកុំខឹងនឹងមិនមានលាភ ព្រោះមិនមានលាភ មិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងសក្តិយស ព្រោះសក្តិយសមិនមែនជារបស់ខ្លួន ។

-ចិត្តកុំខឹងនឹងមិនមានសក្តិយស

ព្រោះមិនមានសក្តិយស មិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងស្រី កុំខឹងនឹងស្រី ព្រោះស្រីមិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងប្រុស,កុំខឹងនឹងប្រុស

ព្រោះប្រុសមិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងសត្វ កុំខឹងនឹងសត្វ

ព្រោះសត្វមិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងជីវិត កុំខឹងនឹងជីវិត

ព្រោះជីវិត មិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងបុគ្គល កុំខឹងនឹងបុគ្គល

ព្រោះបុគ្គលមិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងរូបកើត កុំខឹងនឹងរូបកើត

ព្រោះរូបកើតមិនមែនជារបស់ខ្លួន ។

-ចិត្តកុំត្រេកអរនឹងរូបក្មេង កុំខឹងនឹងរូបក្មេង

ព្រោះរូបក្មេងមិនមែនជារបស់ខ្លួន ។

-ចិត្តកុំទទឹងទាស់នឹងរូបចាស់ កុំខឹងនឹងរូបចាស់

ព្រោះរូបចាស់មិនមែនជារបស់ខ្លួន ។

-ចិត្តកុំទទឹងទាស់នឹងរូបឈឺ កុំខឹងនឹងរូបឈឺ

ព្រោះរូបឈឺមិនមែនជារបស់ខ្លួន ។

-ចិត្តកុំទទឹងទាស់នឹងរូបស្លាប់ កុំខឹងនឹងរូបស្លាប់

ព្រោះរូបស្លាប់មិនមែនជារបស់ខ្លួន ។

នៃសញ្ញា វិញ្ញាណ! **អនិច្ចេទុក្ខសញ្ញា** នេះ អ្នកគប្បីចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ បើចិត្តសន្សំ អនិច្ចេទុក្ខសញ្ញា រឿយៗហើយ សេចក្តីសំគាល់ក្នុងការខ្ជិលច្រអូស ទំរន់ធ្វេសប្រហែសមិនព្យាយាម មិនពិចារណាឲ្យឃើញថាជារបស់គួរខ្លាចដ៏ពន្លឹក រមែងតាំងឡើង ហាក់ដូចជាពេជ្ឈឃាដដែលឃារដារឡើងបំរុងនឹងប្រហារជីវិតដូច្នោះឯង ។ ប្រសិនបើចិត្តសន្សំ អនិច្ចេទុក្ខសញ្ញារឿយៗហើយ សេចក្តីសំគាល់ក្នុងការខ្ជិលច្រអូសទំរន់ប្រហែសធ្វេស មិនព្យាយាម មិនពិចារណា ឲ្យឃើញថាជារបស់គួរខ្លាចដ៏ពន្លឹក មិនដូចជាពេជ្ឈឃាដដែលឃារដារឡើងបំរុងនឹងប្រហារជីវិតដូច្នោះទេ គប្បីដឹងថាអនិច្ចេទុក្ខសញ្ញា អញ

ចំរើនមិនទាន់បានទេ កាលខាងដើមនិងកាលខាងចុងរបស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការចំរើនរបស់អាត្មាអញមិនទាន់បានសម្រេចទេ ។

**ទុក្ខេអនត្តសញ្ញា** ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ បើចិត្តសន្សំ **ទុក្ខេអនត្តសញ្ញា** រឿយៗ ហើយ ចិត្តរមែងប្រាសចាកអហង្ការ មមង្ការនិងមានៈ ក្នុងកាយដែលមានវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង ជាចិត្តកន្លងបង់ នូវ **អទ្ធានៈ**៣ប្រការ ស្ងប់រម្ងាប់ចាកសឹកសត្រូវ ពោលគឺកិលេសរមែង ផុតស្រឡះដោយប្រពៃ ចាកមិច្ឆាវិមុត្តិ ។ ប្រសិនបើចិត្តសន្សំ **ទុក្ខេអនត្តសញ្ញា** រឿយៗហើយ តែចិត្តមិនប្រាសចាកអហង្ការ មមង្ការ និងមានៈ ក្នុងកាយដែលមានវិញ្ញាណនោះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង ជាចិត្តមិនកន្លងបង់ នូវអទ្ធានៈ៣ប្រការ មិនស្ងប់រម្ងាប់ មិនផុតទុក្ខស្រឡះដោយប្រពៃ គប្បីដឹងថា ទុក្ខេអនត្តសញ្ញា អញចំរើនមិនទាន់បានទេ កាលខាងដើមនិងកាលខាងចុងរបស់អញមិនទាន់ប្លែកគ្នាទេ ផលនៃការចំរើន របស់អាត្មាអញ មិនទាន់បានសម្រេចទេ ។ បើចិត្តសន្សំ ទុក្ខេអនត្តសញ្ញា រឿយៗហើយ ចិត្តក៏រួចចាកអហង្ការ មមង្ការនិងមានៈ ក្នុងកាយដែលមានវិញ្ញាណនោះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង ជាចិត្តកន្លងបង់នូវអទ្ធានៈ៣ប្រការ ស្ងប់រម្ងាប់ ផុតស្រឡះដោយប្រពៃ រមែងបានផលច្រើន បានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។

នៃសញ្ញា វិញ្ញាណ! ចូរអ្នករក្សានូវធម៌ស្ងប់រម្ងាប់ មិនឲ្យកំរើកបាន អាស្រ័យដោយធម៌៧យ៉ាងគឺៈ

១-មិនត្រេកអរ មិនខឹងនឹងបក្សពួក,

២-មិនត្រេកអរ មិនខឹងនឹងការងារ,

៣-មិនត្រេកអរ មិនខឹងនឹងពាក្យប៉ប៉ាច់ប៉ប៉ោច តិរច្ឆានកថា,

៤-មិនត្រេកអរ មិនខឹងនឹងស៊ីច្រើន,

៥-មិនត្រេកអរ មិនខឹងនឹងងក់ងុយដេក,

៦-ភាពជាអ្នកដឹងប្រមាណក្នុងភោជន,

៧-មានសីលជាទីសង្រួម ។

បើមានធម៌ទាំង៧យ៉ាងនេះ ទើបអាចរក្សានូវធម៌ស្ងប់រម្ងាប់បាន ។ តែថាធម៌ស្ងប់រម្ងាប់នេះមាន២យ៉ាងគឺ ស្ងប់រម្ងាប់ក្នុងនិរោធសមាបត្តិម៉្យាង ស្ងប់រម្ងាប់ក្នុងនិរោធអរិយសច្ចម៉្យាង ។ ឯស្ងប់រម្ងាប់ក្នុង និរោធសមាបត្តិ៨នេះ មិនមែនជាធម៌រំលត់ទុក្ខបានទេ ។ បើស្ងប់រម្ងាប់ ក្នុងនិរោធអរិយសច្ចគឺមគ្គ៤-ផល៤ នេះទើបរំលត់ទុក្ខបាន ។ បុគ្គលដែលរំលត់ទុក្ខបាននេះ ហៅថាអរិយបុគ្គល គឺបុគ្គលដ៏ប្រសើរ បុគ្គលត្រឹមត្រូវ បុគ្គលមានសភាពរាបសារ បុគ្គលរៀបរយល្អ និងជាបុគ្គលតាំងនៅក្នុងអរិយធម៌ជានិច្ច ។ ព្រះអរិយបុគ្គលទាំងនោះមាន៨ពួកគឺ ៖

| | |
|---|---|
| សោតាបត្តិមគ្គ១ | សោតាបត្តិផល១ |
| សកទាគាមិមគ្គ១ | សកទាគាមិផល១ |
| អនាគាមិមគ្គ១ | អនាគាមិផល១ |
| អរហត្តមគ្គ១ | អរហត្តផល១ ។ |

ត្រូវជា៨ពួក ។

សោតាបន្នបុគ្គល ដែលសម្រេចសោតាហើយ លះបានអកុសលចិត្តជាទិដ្ឋិសម្បយុត្ត៤ វិចិកិច្ឆាសម្បយុត្ត១ រួមជា៥ លះបានសំយោជនៈ៣គឺ សក្កាយទិដ្ឋិសំយោជនៈ១ វិចិកិច្ឆាសំយោជនៈ១ សីលព្វតបរាមាសសំយោជនៈ១ រួមជា៣ លះបានអនុសយៈ២គឺ ទិដ្ឋានុសយៈ១ វិចិកិច្ឆានុសយៈ១ រួមជា២ លះបានកាមឆន្ទៈនិងព្យាបាទៈជាចំណែកគ្រោតគ្រាតដែលឲ្យកើតទុច្ចរិត៣ ជាអបាយគាមិ ។

បច្ចវេក្ខណៈ ការពិចារណារបស់សោតាបន្នបុគ្គលមាន៥យ៉ាងគឺ

-មគ្គំបច្ចវេក្ខតិ ព្រះសោតាបន្នបុគ្គលរមែងពិចារណានូវមគ្គ១

-ផលំបច្ចវេក្ខតិ ពិចារណានូវផល១

-បហីនកិលេសេ បច្ចវេក្ខតិ

ពិចារណានូវកិលេសដែលលោក លះបង់បានហើយ១

-អវសិដ្ឋកិលេសេ បច្ចវេក្ខតិ

ពិចារណានូវកិលេសដែលនៅសល់១

-និព្វានំ បច្ចវេក្ខតិ ពិចារណានូវអមតៈមហានិព្វាន១

រួមត្រូវជាបច្ចវេក្ខណៈរបស់សោតាបន្នបុគ្គលមាន៥ ។

សោតាបន្នបុគ្គលនោះចែកចេញជា៣ពួកគឺ

ឯកពីជិ១

កោលំកោលៈ១

## សត្តក្ខត្តុំបរមៈ១ ។

-ឯកពីជិ លោកដែលមានពូជគឺភពតែ១ គឺនៅកើតក្នុងមនុស្សលោកតែ១ជាតិទៀត ហើយធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល លែងមានកំណើតទៅមុខទៀត ។

-កោលំកោលៈ លោកដែលទៅពីត្រកូល១ទៅកាន់ត្រកូល១ទៀត គឺលោកដែលនៅកើតទៀត២ជាតិឬ៣ជាតិទៀត ទើបបានធ្វើ ឲ្យជាក់-ច្បាស់នូវអរហត្តផល ។

-សត្តក្ខត្តុំបរមៈ លោកដែលត្រាច់រង្គាត់ទៅកើតក្នុងមនុស្សលោកនិងទេវលោកយ៉ាងច្រើនបំផុតត្រឹម៧ជាតិទៀត ទើបបានធ្វើឲ្យជាក់-ច្បាស់នូវអរហត្តផលដោយខន្ធនិព្វាន ក្នុងជាតិជាគំរប់៧ពិតប្រាកដ ។

ហេតុអ្វីបានជាសោតាបន្នបុគ្គលមានប្រភេទផ្សេងគ្នា អង្គខ្លះជាឯកពីជិ អង្គខ្លះជាកោលំកោលៈ អង្គខ្លះជាសត្តក្ខត្តុំបរមៈ? តបថាបានជាមានប្រភេទផ្សេងគ្នាដូច្នេះ ពីព្រោះមានវិបស្សនាផ្សេងគ្នា គឺ

| | |
|---|---|
| ឯកពីជិ | មានវិបស្សនាក្លៀវក្លាបំផុត |
| កោលំកោលៈ | មានវិបស្សនាក្លៀវក្លាយ៉ាងកណ្ដាល |
| សត្តក្ខត្តុំបរមៈ | មានវិបស្សនាទន់ខ្សោយបំផុត ។ |

សោតាបន្នបុគ្គលទាំងនោះ លោកបរិបូណ៌ដោយសីល ។

សោតាបន្នបុគ្គលនៅមានចែកចេញទៅទៀត បើចែកចេញតាមឈ្មោះដើមមានតែ៣ដូចពោលមកហើយ តែបើចែកតាមខណៈចិត្ត ដែលលះ

កិលេសបានផ្សេងគ្នាមាន២៤ដូច្នេះគឺ យកបដិបទា៤និងធុរៈ២មកគុណ

ឯកពីជិមានបដិបទា៤

កោលំកោលៈមានបដិបទា៤

សត្តក្ខត្តុំបរមៈមានបដិបទា៤ រួមត្រូវជា១២ ចែកជាសទ្ធាធុរៈ១២ បញ្ញាធុរៈ១២ រួមបានជា២៤ ។

**សកទាគាមិបុគ្គល** លះបានអកុសលចិត្តជាទិដ្ឋិវិប្បយុត្ត៤ ទោមនស្សសហគតចិត្ត២ រួមជា៦ ។ លះបានសំយោជនៈ២គឺ កាមរាគៈសំយោជនៈ១ ព្យាបាទៈសំយោជនៈ១ ត្រូវជា២ ។ លះបានអនុសយៈ២គឺ កាមរាគានុសយៈ១ បដិឃានុសយៈ១ រួមជា២ ។ លះរាគៈ ទោសៈ មោហៈ បានដោយស្រាលស្តើង ។ សកទាគាមិបុគ្គលនេះ រមែងមកកើតក្នុងកាមភពនេះម្តងទៀត ទើបធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលជាទីបំផុតនៃទុក្ខហើយទើបបានរំលត់ខន្ធចូលកាន់និព្វាន ។ ឯបច្ចវេក្ខណៈរបស់សកទាគាមិបុគ្គល ក៏មាន៥ដូចសោតាបន្នបុគ្គលដែរ ហើយលោកបរិបូណ៌ដោយសីលដូចគ្នា ។ សកទាគាមិបុគ្គលបើចែកតាមខណៈចិត្តដែលលះកិលេសបានមាន១២គឺ ក្នុងសកទាគាមិបុគ្គលមួយៗ មានវិមោក្ខ៣ ក្នុងវិមោក្ខមួយៗ មានបដិបទា៤ ត្រូវជា១២ ។

**អនាគាមិបុគ្គល** លះបានអកុសលចិត្តជាទិដ្ឋិវិប្បយុត្ត៤ ទោមនស្សសហគតចិត្ត២ លះបានសំយោជនៈ២គឺ កាមរាគៈ១ ព្យាបាទៈ១ និងអនុសយៈចិត្ត២គឺ កាមរាគានុសយៈ១ បដិឃានុសយៈ១ ដោយដាច់ស្រឡះ ។ ឯបច្ចវេក្ខណៈរបស់អនាគាមិបុគ្គលនេះ ចែកចេញជា៥ពួកគឺ

អន្តរាបរិនិព្វាយីកា

ឧបហច្ចបរិនិព្វាយីកា

អសង្ខារបរិនិព្វាយីកា

សសង្ខារបរិនិព្វាយីកា

ឧទ្ធំសោតោអកនិដ្ឋគាមីកា ។

អន្តរាបរិនិព្វាយី លោករំលត់ក្នុងចន្លោះ គឺលោកដែលកើតក្នុងសុទ្ធាវាសព្រហ្មលោកហើយ នៅមិនទាន់បានពាក់កណ្តាលអាយុ ក៏ញុំាងអរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈខាងលើបាន ។

ឧបហច្ចបរិនិព្វាយី លោកកន្លងពីថ្នាក់នោះបន្តិចទៅទៀត គឺលោកដែលមានអាយុជាងពាក់កណ្តាលឡើងទៅ ដល់កាលទៀបនឹងអស់អាយុ ទើបញុំាងអរហត្តមគ្គឲ្យកើតឡើងដើម្បីលះសំយោជនៈ ខាងលើទាំង៥ ។

អសង្ខារបរិនិព្វាយី លោករំលត់ដោយអសង្ខារ គឺលោកដែលញុំាង អរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈទាំង៥ខាងលើបានដោយងាយ មិនបាច់ប្រកបព្យាយាមតឹងតែងពេក ។

សសង្ខារបរិនិព្វាយី លោកជាអ្នករំលត់ដោយសង្ខារ គឺលោកដែលញុំាងអរហត្តមគ្គឲ្យកើតឡើងបានដោយកម្រ ទាល់តែប្រកបដោយសេចក្តីព្យាយាមយ៉ាងធំ ។

ឧទ្ធំសោតោអកនិដ្ឋគាមី លោកជាអ្នកមានខ្សែឮដ៏ខាងលើទៅកាន់ភពអកនិដ្ឋ គឺច្យុតចាកព្រហ្មលោកឈ្មោះអវិហាហើយ ទៅកាន់

អតប្បាព្រហ្មលោកទៀត លុះច្យុតចាកអតប្បាព្រហ្មលោកហើយ ទៅកាន់សុទស្សាព្រហ្មលោកទៀត លុះច្យុតចាកព្រហ្មលោកឈ្មោះសុទស្សាហើយ ទៅកាន់សុទស្សីព្រហ្មលោកទៀត លុះច្យុតចាកសុទស្សីព្រហ្មលោកហើយ ទៅកាន់អកនិដ្ឋព្រហ្មលោកទៀត ទើបញ៉ាំងអរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈខាងលើក្នុងព្រហ្មលោកនោះរួមគ្នាផង ត្រូវជាអនាគាមិបុគ្គល៥ពួក ។ ក្នុងស្ថានអវិហា៥ អតប្បា៥ សុទស្សា៥ សុទស្សី៥ អកនិដ្ឋៈ៤ លើកឧទ្ធំសោតៈ១ចេញ រួមជាអនាគាមិបុគ្គលមាន២៤ គុណទៅទៀតជាសទ្ធាធុរៈ២៤ បញ្ញាធុរៈ២៤ ទើបបានជាអនាគាមិបុគ្គលមាន៤៨ ។ ព្រះអនាគាមិបុគ្គល លោកបរិបូណ៌ដោយសមាធិ ។

ព្រះអរហត្ត លះបានអកុសលចិត្តជាទិដ្ឋិគតវិប្បយុត្ត៤ ឧទ្ធច្ចសហគតចិត្ត១ ជា៥ លះបានសំយោជនៈគឺ រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និង មានានុស័យ រាគានុស័យ អវិជ្ជានុស័យ ដាច់ស្រឡះពីខន្ធសន្តាន ។ បច្ចវេក្ខណ (ការពិចារណា) របស់ព្រះអរហន្តមាន៤យ៉ាងគឺ មគ្គំ បច្ចវេក្ខតិ លោកពិចារណានូវមគ្គ១ ផលំ បច្ចវេក្ខតិ ពិចារណានូវផល១ បហីនកិលេស បច្ចវេក្ខតិ ពិចារណា នូវកិលេសដែលលះបានហើយ១ និព្វានំ បច្ចវេក្ខតិ ពិចារណានូវព្រះនិព្វាន១ រួមត្រូវជា៤ ។

**ព្រះអរហត្តទាំងនោះ ចែកចេញ ជា៤ពួកគឺ ៖**

សុខវិបស្សកោ លោកអ្នកមានវិបស្សនារឹងស្ងួត ព្រោះមិន មានជ័រ គឺសមថភាវនា បានចំរើនវិបស្សនាលុះដល់ព្រះអរហត្ត មិនប្រកបដោយ ឫទ្ធិវិសេសឯណានិមួយឡើយ មួយពួក ។

តេវិជ្ជោ លោកដែលបានវិជ្ជា៣មួយពួក ។

ឆឡភិញ្ញោ លោកដែលបានអភិញ្ញា៦ មួយពួក ។

បដិសម្ភិទប្បត្តោ លោកដែលបានដល់បដិសម្ភិទា៤ មួយពួក ត្រូវជាព្រះអរហន្តមាន៤ពួក ។ ព្រះអរហន្តទាំង៤ពួកនេះ រួមមកជា២គឺ សុខវិបស្សកោ១ ហើយនិងខាងចុង៣រួមមកហៅថា សមថ-យានិកៈ តែម៉្យាង១ ។ ចាត់ទៅតាមវិមោក្ខ៣គឺ ក្នុងវិមោក្ខ១ៗ មានបដិបទា៤ រួមត្រូវជា១២ជាសុខវិបស្សកៈ១២ សមថយានិកៈ១២ រួមត្រូវជា ព្រះអរហន្ត២៤ ។ ព្រះអរហន្តលោកបរិបូណ៌ដោយបញ្ញា ។ រួមព្រះអរិយបុគ្គលទាំងអស់ត្រូវជា១០៨ គឺ សោតាបន្នបុគ្គល២៤ សកទាគាមិ១២ អនាគាមិ៤៨ ព្រះអរហន្ត២៤ ។ ពុទ្ធដីកាព្រមទាំង អដ្ឋកថា ថាៈ យេ បុគ្គលា អដ្ឋសតំ បសដ្ឋាតិ ឥមិស្សា គាថាយ វណ្ណនាយំ អដ្ឋុត្តរសតំ អរិយា វុត្តា ។ ព្រះអរិយបុគ្គលទាំង ១០៨នេះ ចែកជាមគ្គ៥៤ ផល៥៤ ត្រូវជាព្រះអរិយបុគ្គល១០៨ដដែល ។

បដិបទាទាំង៤យ៉ាងនោះគឺ

ទុក្ខាបដិបទាទន្ធាភិញ្ញា កាលប្រតិបត្តិលំបាក ដល់បានត្រាស់ដឹង ក៏លំបាក១ សុខាបដិបទាទន្ធាភិញ្ញា កាលប្រតិបត្តិងាយ ត្រាស់ដឹង យឺតយូរវិញ១ ទុក្ខាបដិបទាខិប្បាភិញ្ញា កាលប្រតិបត្តិលំបាក

ត្រាស់ដឹងឆាប់១ សុខាបដិបទាខិប្បាភិញ្ញា កាលប្រតិបត្តិងាយ ត្រាស់ដឹងឆាប់១ ។ បដិបទាផ្សេងគ្នាដោយយឺតយូរ និងឆាប់រហ័ស យ៉ាងនេះ ព្រោះបុគ្គលដែលប្រតិបត្តិនោះ មានឥន្ទ្រិយនិងកិលេស ផ្សេងគ្នា គឺ

១- បុគ្គលដែលប្រតិបត្តិយឺតយូរ ព្រោះកិលេសក្លៀវក្លា បាន ត្រាស់ដឹងយឺតយូរ ព្រោះឥន្ទ្រិយទន់ ប្រៀបឧបមាដូចជាអ្នក មានជម្ងឺ ជាទម្ងន់ ដើរទៅផ្ទះគ្រូពេទ្យ ដំណើរដែលដើរទៅនោះ រមែងយឺតយូរ ព្រោះខ្លួនឈឺធ្ងន់ បានដល់ផ្ទះពេទ្យហើយ ទៅរកថ្នាំ ថ្នាំនោះក៏បានតិច ម្ល៉ោះហើយជម្ងឺនោះ ក៏ទៅជាសះស្បើយបានដោយយឺតយូរ យ៉ាង ណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

២- ប្រតិបត្តិងាយ ត្រាស់ដឹងយឺតយូរ ព្រោះកិលេសតិច ឥន្ទ្រិយ ក៏ទន់ ឧបមាដូចជាអ្នកមានជម្ងឺស្រាលដើរទៅរកផ្ទះពេទ្យឆាប់ដល់ តែ ព្យាបាលរោគយូរ ព្រោះមានថ្នាំតិច យ៉ាងណាមិញ សុខាបដិបទា-ទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៣- ប្រតិបត្តិលំបាក ត្រាស់ដឹងឆាប់ ព្រោះកិលេសក្លៀវក្លា ឥន្ទ្រិយ ក៏ក្លៀវក្លាដែរ ឧបមាដូចជាអ្នកមានជម្ងឺធ្ងន់ ដើរទៅរកផ្ទះពេទ្យយឺតយូរ តែបានសះជារោគឆាប់រហ័ស ព្រោះមានថ្នាំច្រើន យ៉ាងណាមិញ ទុក្ខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៤- ប្រតិបត្តិងាយ ត្រាស់ដឹងឆាប់ ព្រោះកិលេសទន់ ឥន្ទ្រិយ ក្លៀវក្លា ឧបមាដូចជាអ្នកមានជម្ងឺស្រាល ដើរទៅរកផ្ទះពេទ្យឆាប់ដល់ រក្សារោគ ក៏ឆាប់សះជា ព្រោះមានថ្នាំច្រើនយ៉ាងណាមិញ សុខាបដិ-បទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

នៃសញ្ញា វិញ្ញាណ! តួកិលេសទុកដូចជារោគ ឥន្ទ្រិយទាំង៥ ទុកដូចជាថ្នាំសម្រាប់កែរោគ ម្យ៉ាងទៀតឧបមាដូចជាបុរស៤រូប ស្វែងរកគោ បុរសទី១ដើរទៅក្នុងព្រៃ ដល់វេលាឃើញគោ ក៏ឃើញក្នុងព្រៃយ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី២ ដើរទៅរកគោតាមផ្លូវធ្លាស្រួល ដល់ឃើញគោបែរជាឃើញក្នុងព្រៃវិញ យ៉ាងណាមិញ សុខាបដិបទាទន្ធាភិញ្ញាបុគ្គលក៏យ៉ាងនោះដែរ ។ បុរសទី៣ស្វែងរកគោ ដើរកាត់ព្រៃ ដល់ឃើញគោបែរជាឃើញក្នុងទីវាលវិញ យ៉ាងណាមិញ ទុក្ខាបដិបទាខិប្បាភិញ្ញាបុគ្គលក៏យ៉ាងនោះដែរ ។ បុរសទី៤ ដើរទៅរកគោតាមផ្លូវធ្លា ដល់ឃើញគោក៏ឃើញក្នុងទីវាល យ៉ាងណាមិញ សុខាបដិបទាខិប្បាភិញ្ញាបុគ្គលក៏យ៉ាងនោះដែរ ។

បុរសគឺព្រះយោគាវចរកុលបុត្តដែលស្វែងរកអរិយមគ្គ គោគឺអរិយមគ្គ ព្រៃគឺកិលេស ផ្លូវធ្លាគឺកិលេសដ៏ស្តើង ។ បុគ្គលដែលបានមគ្គ-ផលផ្សេងគ្នា ព្រោះប្រតិបត្តិខុសគ្នា ដូចបានសម្តែងមកនេះ ។

**(សំដែងមកក្នុងវិបស្សនាបញ្ហាព្រះត្រៃលក្ខណ៍ ចប់តែប៉ុណ្ណេះ)**

លុះព្រះបញ្ញាសំដែងធម៌ចប់ហើយ សញ្ញានិងវិញ្ញាណថា យើងខ្ញុំទាំងពីរនាក់នេះ សូមសម្តែងអំណរគុណចំពោះព្រះបញ្ញា ដូចមានសេចក្តីតទៅខាងមុខនេះថា ខ្ញុំព្រះករុណាទាំងពីរនាក់នេះ បានស្តាប់ធម៌របស់ព្រះបញ្ញា សំដែងតាំងអំពីខាងដើម រហូតដល់ខាងចុងបញ្ចប់នេះ ឃើញថាមានពន្លឺភ្លឺស្វាងរុងរឿង ត្រចះត្រចង់ជាអតិបរមា និងរកពន្លឺអ្វីមួយមកប្រៀបផ្ទឹមឲ្យស្មើពុំបានឡើយ នេះជាពន្លឺទី១ ។ ពន្លឺទី២ ថា

ចាប់ដើមតាំងតែអំពីខ្ញុំបានថ្វាយខ្លួនមក បានឡើងជិះលើ នាវាត្រៃ-លក្ខណ៍ស៊ប់ហើយ ពិនិត្យមើលទៅឃើញនូវធម៌ទាំង១៦ ដែលនៅក្នុងនាវានេះដោយឥតមានសេចក្តីងឿងឆ្ងល់ អ្វីបន្តិចបន្តួចសោះឡើយ ភ្លឺច្បាស់ណាស់ៗ ហើយថែមទាំងបានសះជារោគឆ្កួតទាំង៨យ៉ាង ទៀតផង តាំងពី កាមុម្មត្តកោ កោធុម្មត្តកោ ទិដ្ឋុម្មត្តកោ ។ល។ ចិត្តរបស់ខ្ញុំទាំងពីរនាក់នេះ ចូលស៊ប់ដល់ធម៌ដែលធ្វើឲ្យត្រជាក់រំងាប់បង់នូវភ្លើងទុក្ខ និងភ្លើងកិលេស ដែលជាធម៌ដ៏ឧត្តម ជាគុណគឺព្រះនិព្វាន ដោយពន្លឺភ្លឺស្វាង នេះជាពន្លឺទី២ ។ ពន្លឺទី៣ ថាខ្ញុំមើលទៅឃើញច្បាស់នាវាព្រះត្រៃលក្ខណ៍ ដែលជាអតីតកាល គឺកាលដែលព្រះពុទ្ធទ្រង់គង់ធរមាននៅឡើយនោះ ព្រះអង្គតែងប្រោសសត្វដឹកនាំសត្វ ឲ្យចូលទៅក្នុងនាវាព្រះត្រៃលក្ខណ៍ បានច្រើនជាអនេក ។ ចាប់ទាំងអំពីព្រះសម្ពុទ្ធបរិនិព្វានទៅ ព្រះអរហន្ត ព្រះអនាគាមិ សកទាមិ សោតាបន្ន ក៏អស់ទៅ នាវាត្រៃលក្ខណ៍ក៏នៅទំនេរ ឥតមានមនុស្សជិះ ឬមានខ្លះដែរ ម្នាក់ៗ ព្រោះហេតុអ្វី? ព្រោះខ្វះអ្នកដឹកនាំ ។ ឥឡូវនេះ នាវាត្រៃលក្ខណ៍ ភ្លឺរុងរឿងត្រចះត្រចង់ដូចកាលដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ គង់ធរមាននៅនោះដែរ នេះជាពន្លឺទី៣ ។

វិញ្ញាណសួរសញ្ញាថា យើងបានស្តាប់ធម៌ឃើញថា មានធម្មរសភ្លឺស្វាងក្នុងដួងចិត្ត ប្រសើរពន់ពេកណាស់ហើយ តើយើងបានវត្ថុអ្វីបូជាដល់គុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ?

សញ្ញាឆ្លើយថា បើតាមសេចក្តីយល់របស់ខ្ញុំថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យើងបូជានូវវត្ថុអ្វីៗក៏មិនស្មើនឹងបូជាកាយ វាចា ចិត្ត បដិបត្តិទៅតាមព្រះឱវាទ ដែលទ្រង់ទូន្មានថា នេះមិនមែន នោះមិនមែន

ដូចបានអធិប្បាយក្នុងព្រះត្រៃលក្ខណ៍សព្វគ្រប់ស្រាប់ ។ បូជាយ៉ាងនេះ ហៅថា បូជាយ៉ាងប្រសើបំផុត នៅក្នុងព្រះពុទ្ធសាសនា ។

វិញ្ញាណថា ប្រសើរហើយៗ ចុះសញ្ញាអ្នកមានយោបល់ ជួយដឹកនាំឲ្យមនុស្ស ដែលជាអ្នកមានឧបនិស្ស័យ ចូលទៅនៅក្នុងនាវាត្រៃលក្ខណ៍ បានដែរឬដូចម្ដេច?

ខ្ញុំជួយមិនបានទេអ្នក ព្រោះយើងទាំង២នាក់នេះ គ្មានបុណ្យខាងដឹកនាំ ដូចព្រះពុទ្ធជាម្ចាស់នោះទេ បើដូច្នោះមានតែយើងទាំង២នាក់នេះ ជួយទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យបានរុងរឿងទៅអនាគត យើងត្រូវតែស្រឡាញ់រាប់អាន ព្រះពុទ្ធសាសនា ដោយសទ្ធាពិតៗ តែថាឲ្យខ្ញុំដឹកនាំចូលមកនៅក្នុងនាវាត្រៃលក្ខណ៍នោះពុំបានទេ ព្រោះការដែលដឹកនាំអំពី នាវាត្រៃលោក ហើយដឹកនាំឲ្យចូលមកនាវាត្រៃលក្ខណ៍វិញ នេះទៀតតឹងណាស់ ព្រោះធម៌ដែលមានក្នុងនាវាត្រៃលោកនោះមិនត្រូវគ្នា នឹងធម៌ដែលមានមក ក្នុងនាវាត្រៃ-លក្ខណ៍ទេ ។

ត្រៃលោក៣ ពរ៤ លោកធម៌៨ សមាបត្តិ៨ អាកាសធាតុ១ នេះជាធម៌ត្រៃលោក ។

ត្រៃលក្ខណ៍៣ អរិយសច្ចៈ៤ អង្គមគ្គ៨ មគ្គផល៨ និព្វានធាតុ១ នេះជាពួកត្រៃលក្ខណ៍ ។

ត្រៃលោក៣ មិនត្រូវគ្នានឹងត្រៃលក្ខណ៍៣

ពរ៤មិនត្រូវគ្នានឹងអរិយសច្ចៈ៤

លោកធម៌៨ មិនត្រូវនឹងអង្គមគ្គ៨

សមាបត្តិ៨ មិនត្រូវគ្នានឹងមគ្គផល៨

អាកាសធាតុ១ មិនត្រូវនឹងនិព្វានធាតុ១ ធម៌មិនត្រូវគ្នាដូច្នេះឯង ។

វិញ្ញាណសួរសញ្ញាថា ចុះនាវាត្រៃលោក ហេតុដូចម្ដេចបានជាមនុស្សជិះច្រើនម្ល៉េះ?

បានជាមនុស្សជិះច្រើន ព្រោះក្នុងនាវានេះ មានមារ៥ជាអ្នកដឹកនាំចងទាញ កៀរគរប្រមូលមនុស្សសត្វតូចធំ ឲ្យចូលទៅនៅក្នុងនាវាត្រៃលោកទាំងអស់ មិនឲ្យសេសសល់ឡើយ ។

ចុះមារទាំង៥នោះ តើដូចម្ដេច?

មារ៥នោះគឺ ខន្ធមារ១ កិលេសមារ១ អភិសង្ខារមារ១ ទេវ- បុត្តមារ១ មច្ចុមារ១ ។

ឯខន្ធមារនោះគឺ រូប១ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១ ។

កិលេសមារនោះគឺ លោភៈ១ ទោសៈ១ មោហៈ១ មារទាំង៣នេះមានខ្សែចងសត្វ ឲ្យជាប់នៅក្នុងនាវាត្រៃលោកទាំង៣ ដោយចំណងមារទាំង៣នេះ នៅក្នុងអកុសលចិត្ត១២ ហើយនាំទៅទុកក្នុងនាវាត្រៃលោក មិនឲ្យទៅណាបាន ។ មារនេះមានគ្នាច្រើនណាស់ដើរប្រមូលសត្វតូចធំ មិនឲ្យសល់ម្នាក់ ឲ្យជាប់ចំណងគ្រប់ៗគ្នា ហើយនាំយកទៅចងទុកក្នុងនាវាត្រៃលោក ។ ឯកិលេសមារនោះក៏បញ្ជូនសត្វទាំងអស់នោះប្រគល់ឲ្យទៅអភិសង្ខារមារ ។

អភិសង្ខារមារនេះមាន៣គឺ បុញ្ញាភិសង្ខារមារ១ អបុញ្ញាភិសង្ខារ-មារ១ អនេញ្ជាភិសង្ខារមារ១ ។ មារទាំង៣នេះ ជាអ្នកតាក់តែងចាត់ចែងឲ្យសត្វដែលជាប់ចំណងទាំងអស់ ដែលនៅក្នុងនាវាត្រៃលោកនេះ ឲ្យរៀបរយគ្នាទៅតាមឋានៈរបស់សត្វ ដែលមានទោសធ្ងន់ស្រាល ព្រោះ

ក្នុងនារានេះមានពជាន់ ក្នុងជាន់ទី១ បើចែកជាថ្នាក់មាន១១ថ្នាក់ ក្នុងជាន់ទី២ បើចែកជាថ្នាក់មាន១៦ថ្នាក់ ក្នុងជាន់ទី៣ បើចែកជាថ្នាក់មាន៤ថ្នាក់ ។

ការដែលរៀបរយសត្វអ្នកនៅក្នុងនារានេះ ឲ្យសត្វនេះទៅនៅត្រង់ទីនេះ សត្វនោះទៅនៅត្រង់ទីនោះ សត្វនេះមកនៅឯណេះ សត្វនោះទៅនៅឯណោះ ត្រង់រៀបរយសត្វឲ្យនៅគ្រប់ថ្នាក់គ្រប់ជាន់នេះ ស្រេចតែលើអភិសង្ខារមារទាំង៣ ។ លុះមារនេះរៀបរយស្រេចហើយ បញ្ជូនសត្វទាំងអស់នេះប្រគល់ឲ្យទៅទេវបុត្តមារ ។ ទេវបុត្តមារមាន៣គឺ សស្សតទិដ្ឋិទេវបុត្តមារ១ ឧច្ឆេទទិដ្ឋិទេវបុត្តមារ១ អនត្ថគាហិកទិដ្ឋិ-ទេវបុត្តមារ១ ។ ទិដ្ឋិទាំង៣នេះ ជាស្តេចគ្រប់គ្រងត្រួតត្រាលើមារទាំងអស់ គឺខន្ធមារក្តី កិលេសមារក្តី អភិសង្ខារមារក្តី មច្ចុមារក្តី មារទាំងអស់នេះលុះក្នុងអំណាចទេវបុត្តមារទាំងអស់ ។ ដូចយ៉ាងទេវបុត្តមារទី១ គឺ**សស្សតទិដ្ឋិ** ទិដ្ឋិនេះឃើញថាសម្លាប់សត្វ លួចទ្រព្យគេ សេពមេថុនធម្ម មុសាវាទ ផឹកទឹកស្រវឹង ឃើញថាបើរកបានច្រើនមកស្រួលប្រសើរសុខណាស់ ហើយប្រកាន់យកតែស្រួលៗសុខៗ ។ ទេវបុត្តមារគ្រាន់តែឃើញប៉ុណ្ណេះ មារទាំងអស់ក៏ប្រព្រឹត្តធ្វើនូវអំពើនោះតាមទេវបុត្តមារពុំហ៊ានខានម្នាក់ ។ ទេវបុត្តមារឃើញថារូបល្អ សម្លេងពិរោះ ក្លិនក្រអូប រសឆ្ងាញ់ ទេវបុត្តមារគ្រាន់តែឃើញប៉ុណ្ណេះ មារទាំងអស់ក៏ខំស្វែងទៅរករូប សម្លេង ក្លិននោះៗ ឥតហ៊ានខានម្នាក់ បានហើយប្រកាន់ឲ្យតែនៅស្រួលៗ ត្រង់កិលេសមារ ដែលធ្វើចិត្តឲ្យត្រេកអរនឹងសុខៗ ស្រួលៗនោះ មារនេះចងសត្វឲ្យនៅក្នុងនារាគឺកាមលោក ឬកាមភពក៏បាន កិលេសមារដែលធ្វើចិត្តឲ្យជាប់នឹង

សុខៗស្រួលៗនេះ ចងសត្វឲ្យជាប់នៅក្នុងនាវាគឺរូបលោក ឬហៅថា រូបភព ដូច្នេះវិញក៏បាន ។ ទេវបុត្តមារនេះគាត់ចូលចិត្តតែនឹងឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលកើតមកអំពីផលបុណ្យ ហើយគាត់ដឹកនាំពួកពលមារទាំងអស់ឲ្យចូលចិត្តតាមគាត់ផង ។ ពួកមារទាំងអស់ក៏ជឿតាមទេវបុត្តមារ ហើយប្រមូលគ្នាមកជួបជុំរឹតរុំសត្វតូចធំ នាំយកទៅចងទុកក្នុងនាវាត្រៃលោកទាំងអស់ ។ ទេវបុត្តមារទី១ រឹតរុំចងសត្វបានតែប៉ុណ្ណោះ ។

ទេវបុត្តមារទី២ គឺ**ឧច្ឆេទទិដ្ឋិ** ។ ទេវបុត្តមារនេះ គាត់ចូលចិត្តនឹងអនិដ្ឋារម្មណ៍ គឺអារម្មណ៍ដែលកើតមកអំពីផលអកុសល គឺរូប១ សម្លេង១ ក្លិន១ រស១ ផោដ្ឋព្វៈ១ គាត់មិនចង់ឲ្យរូបចាស់ ឈឺ ស្លាប់ ព្រោះថាបើស្លាប់ហើយលែងកើតទៀតសូន្យ មិនចង់ឲ្យរូបសម្លេង ក្លិន រស សម្ផស្ស ព្រាត់ប្រាស់ ព្រោះថាបើព្រាត់ប្រាស់ហើយសូន្យលែងបានទៀត ម្ល៉ោះហើយគាត់ប្រាប់ពួកមារទាំងអស់ថា ពួកយើងទាំងអស់គ្នាប្រុងប្រយ័ត្ន កុំឲ្យចាស់ ឈឺ ស្លាប់ ព្រោះតែស្លាប់ហើយសូន្យ ។ ម្ល៉ោះហើយពួកមារទាំងអស់ ក៏ភិតភ័យដោយទេវបុត្តមារថាឲ្យប្រុងប្រយ័ត្ន ។ ពួកមារទាំងអស់ជំនុំគ្នាថា យើងធ្វើដូចម្តេចកុំឲ្យចាស់ឈឺស្លាប់បាន? ថាយើងត្រូវអប់រំរូបនេះដោយគ្រឿងអាហារណា ដែលមានរសឆ្ងាញ់ៗ បរិភោគឲ្យបានច្រើនៗ ហើយតាក់តែងគ្រឿងដេក គ្រឿងអង្គុយ សំលៀកបំពាក់ឲ្យល្អៗ ដើម្បីការពារកុំឲ្យចាស់ឈឺស្លាប់ ។ មារទាំងអស់ក៏នាំគ្នាប្រព្រឹត្តធ្វើដូចពាក្យជំនុំនោះ មិនយូរប៉ុន្មានក៏សក់ ស្កូវព្រោងធ្មេញបាក់គ្រហុប ភ្នែកឡើងស្លេ ត្រចៀកក៏ទៅជាថ្លង់ ។ មារទាំងអស់ទៅជំនុំនឹងទេវបុត្តមារ ថាឲ្យខ្ញុំប្រយ័ត្នកុំឲ្យចាស់នោះប្រយ័ត្នមិនបានទេ។

ទេវបុត្តមារថា បើប្រយ័ត្នមិនឈ្នះទេ ឲ្យចាស់ចុះតែត្រូវប្រយ័ត្នកុំឲ្យឈឺ ។ ពលមារទាំងអស់ក៏ប្រយ័ត្នកុំឲ្យឈឺ ។ មិនយូរ ប៉ុន្មានក៏ឈឺមកទៀត ពួកមារទាំងអស់ក៏ទៅទូលទេវបុត្តមារថា ឥឡូវនេះ ឈឺទៀតហើយ ។ ទេវបុត្តមារថា បើឈឺក៏ឈឺចុះ ប៉ុន្តែប្រយ័ត្នកុំឲ្យស្លាប់។ កិលេសមារមានគ្នាច្រើនចំនួន១៥០០នាក់ មកជួយការពារកុំឲ្យស្លាប់។ មារទាំងអស់ជំនុំគ្នាថា យើងគិតធ្វើដូចម្តេចកុំឲ្យស្លាប់? កិលេសមារថា យើងយកជម្ងឺនេះទៅឲ្យពេទ្យពិនិត្យមើលតើឈឺនេះវាខ្វះអ្វី? ពេទ្យថាឈឺនេះវាខ្វះឈាម ពេទ្យនោះក៏មើលមិនជា ។ កិលេសមារថា យើងយកជម្ងឺនេះទៅឲ្យអារក្សដូនម៉ុកដូនម៉ីមើលទៀត អារក្សនោះថាខុសខាងខ្មោចវាធ្វើ ។ អារក្សនោះក៏មើលមិនជា ក៏ស្លាប់ទៅ ។ ទេវបុត្តមារទី២នេះចងសត្វឲ្យជាប់នៅក្នុងនាវាត្រៃលោក ដោយគំនិតយល់ខុសដូច្នេះទៀត។

ទេវបុត្តមារទី៣នោះ គឺ **អន្តគាហិកមិច្ឆាទិដ្ឋិ** គាត់ចូលចិត្តនឹងឥដ្ឋារម្មណ៍ ដូចទេវបុត្តមារទី១ដែរ ។ អន្តគាហិកទិដ្ឋិនេះឃើញថា ធ្វើទានសីល ភាវនា បានបុណ្យកុសល បុណ្យកុសលនេះនឹងឲ្យទៅកើតជាព្រះឥន្ទ្រ ព្រះព្រហ្ម ហើយមានសម្បត្តិក៏ច្រើន អាយុក៏វែង សេចក្តីសុខក៏ច្រើន ។ ទេវបុត្តមារនេះ គ្រាន់តែឃើញដូច្នោះហើយខន្ធមារក្តី កិលេសមារក្តី អភិសង្ខារមារក្តី ក៏នាំគ្នាធ្វើទាន សីល ភាវនាតាមទេវបុត្តមារឃើញនោះ ខំធ្វើទានសីល បានកុសលមកហៅថាកាមាវចរកុសល៨ មារខំចំរើនកម្មដ្ឋាន ចូលកាន់បឋមជ្ឈាន ទុតិយជ្ឈានតតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន បានរូបាវចរកុសល៥ ។ មារខំចំរើនទៀត ចូលកាន់ អរូបាវចរកុសល៤ កុសលទាំងនេះ

កើតឡើងដោយសារទេវបុត្តមារឈ្មោះ **អន្តគាហិកមិច្ឆាទិដ្ឋិផង តណ្ហា**ផង អាស្រ័យជាមួយគ្នា កុសលទាំង៣នេះឈ្មោះថា **វដ្តគាមិនីកុសល** ព្រោះកុសលនេះជាតួមារ កាមាវចរកុសល៨ រូបាវចរកុសល៥ ឈ្មោះថា **បុញ្ញាភិសង្ខារមារ** មារនេះនាំសត្វទៅចងក្រៀកទុកក្នុងនាវាគឺ **កាម-លោក១ រូបលោក១** ។ អរូបាវចរកុសល៤នេះឈ្មោះថា **អនេញ្ជា-ភិសង្ខារមារ** មារនេះនាំសត្វទៅចងក្រៀកទុកក្នុងនាវាគឺ អរូបលោក កន្លែងដែលគ្មានរូប ។ រួមសេចក្តីមកថា ទេវបុត្តមារ ទាំង៣នេះ ខ្ទប់សត្វឲ្យនៅតែក្នុងនាវាត្រៃលោក បិទសោតា បិទព្រះនិព្វាន មិនឲ្យសត្វឃើញជាដាច់ខាត ។

កាលបើអភិសង្ខារមារទាំង៣ រៀបចំចងសត្វឲ្យជាប់នៅក្នុងនាវាត្រៃលោក រួចស្រេចហើយ ក៏នាំសត្វទាំងអស់នោះទៅប្រគល់ឲ្យទេវបុត្តមារ ។ ទេវបុត្តមារបានទទួលហើយ នាំសត្វទាំងអស់ទៅប្រគល់ឲ្យមច្ចុមារ មច្ចុមារនេះមាន៣គឺ ចាស់១ ឈឺ១ ស្លាប់១ ។ មច្ចុមារទាំង៣នេះក្រសួងគាត់ខាងឯសម្លាប់សត្វតូចធំ នៅក្នុងនាវាត្រៃលោកទាំង៣នេះ ។ ទោះសត្វនោះមានបុណ្យសក្តិធំយ៉ាងណាក្តី ឥតមានបុណ្យសក្តិក្តី មានទ្រព្យច្រើនក្តី ឥតទ្រព្យក្តី មានកូនច្រើនក្តី ឥតកូនក្តី សត្វធំក្តី សត្វតូចក្តី ត្រូវគាត់សម្លាប់ទាំងអស់ ឥតមានអ្នកណាមួយទៅអង្វរករបានឡើយ ។ ហេតុដូចម្តេចបានជាមច្ចុមារចេះតែសម្លាប់ដូច្នេះ? បានជាសម្លាប់នោះ ព្រោះសត្វនៅក្នុងនាវាត្រៃលោកទាំង៣នេះ ជាសត្វជាប់ដោយចំណងមារទាំងអស់គ្នា ហើយលោកទាំង៣នេះ មានអាកាសធាតុជាមេធាតុលើសធាតុទាំងពួង ។ មច្ចុមារសម្លាប់រូបឲ្យអស់ចេញទៅ ឲ្យទៅនៅត្រង់ចន្លោះសោះសូន្យទទេៗ ។

ត្រង់ទទេៗ នេះហើយហៅថា **អាកាសធាតុ** ។ ហេតុដែលមនុស្សសត្វចូលចិត្តជិះនាវាត្រៃលោកច្រើននោះ មកអំពីមារទាំង៥នេះ ជាអ្នកទាក់ចងសត្វទុក ដូចសញ្ញាបានអធិប្បាយរួចមកហើយ ។

វិញ្ញាណ អើគួរសង្វេគដល់រូបរាងកាយម្នាក់ៗនេះ ដែលបានកើតមកហើយ ស្លាប់ទៅវិញគ្មានរួចម្នាក់សោះ កើតហើយស្លាប់ ស្លាប់ហើយកើត រាប់មិនអស់ ។ សេចក្ដីស្លាប់កើតនេះ ទុក្ខហើយទុក្ខទៀតត្រួតៗលើគ្នា ទុក្ខព្រោះព្រាត់ប្រាសឪពុកម្ដាយ ទុក្ខព្រោះព្រាត់ប្រាសកូនចៅ ទុក្ខព្រោះព្រាត់ប្រាសបងប្អូន ទុក្ខព្រោះព្រាត់ប្រាសទ្រព្យសម្បត្តិ ទុក្ខព្រោះព្រាត់ប្រាសប្ដីប្រពន្ធ ទុក្ខហើយទុក្ខទៀត ទុក្ខហើយទុក្ខខ្លាំងពន់ប្រមាណ ពីតូចដល់ធំ ទុក្ខទំក្នុងប្រាណ ទុក្ខឥតស្រាកស្រាន្ត ទុក្ខដលខ្លួនក្ស័យ ។ អនិច្ចំពុំស្ថិត ពុំស្ថេរនៅនិត្យយឺនយូរឡើយនៃ ស្លាប់ទៅជាខ្មោច អាសោច៏អប្រិយ ឆ្អឹងសាច់សរសៃជាព្រះធរណី ។ វិញ្ញាណថា គួរអាណោចអធម្មសង្វេគដល់រូបមរណៈព្រោះស្លាប់ទៅគេយកទៅដុត ក្នុងភ្នក់ភ្លើងចោល ឥតបានប្រយោជន៍អ្វីៗជារបស់សោះសូន្យទទេៗ ទុក្ខទោសទាំងអស់នេះ មកតែអំពីមារទាំង៥ ដូចសញ្ញាបានសំដែងរួចមកហើយ ។ សញ្ញាសួរវិញថា បើទុក្ខទោសនោះច្រើនយ៉ាងនេះ ធ្វើដូចម្ដេចទើបនឹងរំលត់ទុក្ខទោសនោះបាន? ងាយណាស់! ឲ្យតែឡើងជិះលើនាវាត្រៃលក្ខណ៍បាន ទុក្ខទាំងនោះក៏រលត់អស់ ព្រោះក្នុងនាវាត្រៃលក្ខណ៍នេះ មានពល៥យ៉ាងគឺ **សទ្ធាពល១ សតិពល១ វិរិយពល១ សមាធិពល១ បញ្ញាពល១** ។ បើពលទាំង៥នេះមានកម្លាំងស្មើគ្នាហើយ ទេវបុត្តមារក៏វិនាសខ្ចាត់ខ្ចាយ

អស់ ចុះចាញ់ហើយមារទាំងអស់នោះក៏វិនាសបាត់បង់ទៅ ទុក្ខទាំងអស់ក៏រលត់ដែរ ដោយអំណាចបានជិះនាវាត្រៃលក្ខណ៍នេះឯង ។

រឿងធម៌រំលត់ទុក្ខនេះ ព្រះបញ្ញាបានសំដែងរួចហើយពីខាងដើមស្រាប់ ក្នុងទីនេះយើងទាំងពីរនាក់សង្ឃឹមទុកជាមុនថា ព្រះពុទ្ធសាសនាដែលមាននៅក្នុងផ្ទៃនៃសៀវភៅ វិបស្សនាបញ្ហា ព្រះត្រៃលក្ខណ-ញាណាធិប្បាយនេះ សូមតាំងនៅឲ្យបានស្ថិតស្ថេរចិរកាល កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ ៕

នាវាត្រៃលក្ខណ៍ចប់តែប៉ុណ្ណេះ

សិរិបញ្ញាភិក្ខុ ឱក-ណៃម
ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៦៥

